

ការសំភាសន៍ស្ដីពីផលប៉ះពាល់នៃការរៀបការដោយបង្ខំក្នុងរបបខ្មែរក្រហម

# "ដូចខ្មោចប្តូរកាយ"


*ដូចបានប្រាប់ទៅកាន់ និងបកប្រែដោយ Thida KIM*

*កែសំរួលដោយ Theresa DE LANGIS, PhD*



កម្មវិធីសុខភាពផ្លូវចិត្ត

TPO

អង្គការចិត្តសង្គម អន្តរវប្បធម៌

Transcultural Psychosocial Organization

Community Mental Health Programme

**អង្គការចិត្តសង្គមអន្តរវប្បធម៌កម្ពុជា**
អគារលេខ ២និង៤ ផ្លូវឧកញ៉ាវាំង( ១៩៥២ ) សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ
ប៉ុស្តិ៍ប្រៃសណីយ៍ប្រអប់សំបុត្រ ១១២៤ ភ្នំពេញ កម្ពុជា
ទូរស័ព្ទ៖ +855 (0) 23 63 66 992
អ៊ីម៉ែល៖ admin@tpocambodia.org
គេហទំព័រ៖ www.tpocambodia.org
ហ្វេសប៊ុក៖ www.facebook.com/tpocambodia

"ដូចខ្មោចប្តូរកាយ" – ការសំភាសន៍ស្តីពីផលប៉ះពាល់នៃការរៀបការដោយបង្ខំក្នុងរបបខ្មែរក្រហម

**ដូចបានប្រាប់ទៅកាន់ និងបកប្រែដោយ** Thida KIM
**កែសំរួលដោយ** Theresa DE LANGIS, PhD

**សូមថ្លែងអំណរគុណដល់** កិច្ចសហប្រត្តិបត្តិការអាឡឺម៉ង់ប្រចាំនៅកម្ពុជា ( GIZ )

ទស្សនៈសំដែងក្នុងសៀវភៅនេះ គឺជាទស្សនៈរបស់ជនរងគ្រោះ សិល្បៈករ រួមនិងអ្នកនិពន្ធប៉ុណ្ណោះ។

រក្សាសិទ្ធិ © 2015 ដោយអង្គការចិត្តសង្គមអន្តរវប្បធម៌កម្ពុជា។ សិទ្ធិទាំងឡាយត្រូវបានរក្សា។ គ្មានផ្នែកណាមួយនៃការបោះពុម្ពនេះ អាចត្រូវគេផលិតសារជាថ្មី ឬប្រើប្រាស់ក្នុងទំរង់ណាមួយ ឬដោយមធ្យោបាយណាមួយ ដោយគ្មានការអនុញ្ញាតពីម្ចាស់ចេញផ្សាយ( ធីភីអូកម្ពុជា )បានឡើយ ទោះជាបច្ចេកវិទ្យាអេឡិចត្រូនិកក្តី ឬមេកានិកក្តី រួមទាំងការថតចម្លង ព្រមទាំងការកត់ត្រា។

**ពិនិត្យអក្ខរាវិរុទ្ធដោយ** ឡុក មាស

**ក្របខាងក្រៅ និង រចនាបទសៀវភៅ**
គំនិតសិល្បៈ និងការរចនាទំព័រ © 2015 ដោយ ជឹម ចំរើន

**លំអរូបភាពនៅក្របខាងក្រៅ**
សិល្បៈកម្មដើម៖ គំនូរ "អាពាហ៍ពិពាហ៍" © 2015 ដោយសិល្បករគំនូរ ឆាត ភាសាត ។ គំនូរក្របក្រៅនេះត្រូវបានប្រើឡើងវិញនិងកែសម្រួលឲ្យប្រើប្រាស់ក្រោមការអនុញ្ញាតិពីសិល្បករ ឆាត ភាសាត។

បោះពុម្ពនៅប្រទេសកម្ពុជាដោយ JSRC Printing House ភ្នំពេញ

ISBN: 978-99963-97-04-2
9 789996 397042

# "ដូចខ្មោចប្តូរកាយ"

## ការសំភាសន៍ស្តីពីផលប៉ះពាល់នៃការរៀបការដោយបង្ខំក្នុងរបបខ្មែរក្រហម

ខែមិថុនា ឆ្នាំ២០១៥

**អង្គការចិត្តសង្គមអន្តរវប្បធម៌ កម្ពុជា**

ដូចបានប្រាប់ទៅកាន់ និងបកប្រែដោយ Thida KIM

កែសំរួលដោយ Theresa DE LANGIS, PhD

## "ដូចខ្មោចប្តូរកាយ"–ការសំភាសន៍ស្តីអំពីផលប៉ះពាល់នៃការរៀបការដោយបង្ខំក្នុងរបបខ្មែរក្រហម

ការសំភាសន៍ទៅលើករណីសិក្សាចំនួនប្រាំបី ដែលបង្កើតនូវទិន្នន័យបែបគុណភាពនៃការសិក្សាស្រាវជ្រាវដោយប្រើប្រាស់វិធីសាស្រ្តចម្រុះស្តីពី "ដូចខ្មោចប្តូរកាយ" ជាការសិក្សាមួយស្តីពីផលប៉ះពាល់នៃការរៀបការដោយបង្ខំក្រោមរបបខ្មែរក្រហមដែលធ្វើការសិក្សាដោយ Theresa de Langis, Judith Strasser, Thida Kim និង Sopheap Taing ដែលបានរៀបចំដោយអង្គការចិត្តសង្គមអន្តរវប្បធម៌កម្ពុជា និងបានចេញផ្សាយកាលពីខែតុលា ឆ្នាំ២០១៤។ ឯកសារបច្ចុប្បន្នគឺជាឯកសារបន្ថែមចំពោះរបាយការណ៍ស្រាវជ្រាវ ដោយប្រើប្រាស់វិធីសាស្រ្តចំរុះ។ ឯកសារនេះត្រូវបានគាំទ្រថវិកាដោយផ្នែកសេវាកម្មសន្តិភាពស៊ីវិលនៃអង្គការកិច្ចសហប្រតិបត្តិការអាល្លឺម៉ង់ ( Civil Peace Service of the Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH.)។ វាត្រូវបានផលិតឡើងក្នុងបរិបទគំរោង "Women in Transitional Justice" របស់ធីភីអូ ដែលគាំទ្រដោយ United Nations Trust Fund to End Violence Against Women។

### អង្គការចិត្តសង្គមអន្តរវប្បធម៌ ( ធីភីអូ ) កម្ពុជា

អង្គការចិត្តសង្គមអន្តរវប្បធម៌កម្ពុជាបានបង្កើតឡើងក្នុងឆ្នាំ១៩៩៥ ដែលជាអង្គការមិនមែន រដ្ឋាភិបាលឈានមុខមួយក្នុងប្រទេសកម្ពុជាខាងផ្នែកថែទាំសុខភាពផ្លូវចិត្ត និងការគាំទ្រផ្នែកចិត្តសង្គម។ ធីភីអូ ជាអង្គការផ្នែកចិត្តសង្គមតែមួយគត់នៅក្នុងប្រទេសកម្ពុជា ដែលពាក់ពន្ធ័នឹងសកម្មភាពស្វែងរកយុត្តិធម៌អន្តរកាលក្នុងបរិបទនៃអង្គជំនុំជម្រះ វិសាមញ្ញក្នុងតុលាការកម្ពុជា( អវតក )។ ចាប់តាំងពីឆ្នាំ២០០៧ និងដោយផ្អែកលើ អនុស្សរណៈនៃការយោគយល់ជាមួយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ អង្គការចិត្តសង្គមអន្តរវប្បធម៌បាននឹងកំពុងផ្តល់នូវសេវាកម្មផ្នែកសេវាចិត្តសង្គមដ៏ទូលំទូលាយចំពោះដើមបណ្តឹងរដ្ឋប្បវេណីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ សេវាកម្មទាំងនេះមានចាប់តាំងពីការគាំទ្រនៅនឹងកន្លែងនៅសាលាក្តីខ្មែរក្រហម ការព្យាបាល ការប៉ះទង្គិចដែលមានលក្ខណៈបែបវប្បធម៌សាសនា និងក្រុមជួយខ្លួនឯង រហូតដល់សកម្មភាពនៃការប្រាប់ការពិត និងគម្រោងសិក្សាស្រាវជ្រាវ។ ធីភីអូ មានបទពិសោធន៍ជាច្រើនឆ្នាំក្នុងការតាក់តែង និងអនុវត្តកម្មវិធីតាមសហគមន៍ដែលមានគោលបំណងក្នុងការប្រយុទ្ធប្រឆាំង និងការពារមិនអោយមានអំពើហិង្សាយេនឌ័រក្នុងប្រទេសកម្ពុជា។

### អំពើហិង្សាយេនឌ័រក្នុងរបបខ្មែរក្រហម

ឯកសារនេះអាចទទួលបានជាភាសាអង់គ្លេស និងភាសាខ្មែរពីវេបសាយ http://gbvkr.org/gender-based-violence-under-khmer-rouge/។ វេបសាយទាំង នេះមានផ្ទុកនូវអត្ថបទសិក្សាស្រាវជ្រាវ និងធនធានស្តីពីអំពើហិង្សាផ្លូវភេទ និង យេនឌ័រក្នុងរបបខ្មែរក្រហមដែលមានទាំង ឯកសារសំលេង និងភាពយន្ត។

### អ្នកនិពន្ធ

ការសំភាសន៍ត្រូវបានកែសំរួលដោយលោកស្រីបណ្ឌិត Theresa de Langis អ្នកឯកទេសជាន់ខ្ពស់ខាងសិទ្ធិនារីស្ត្រីពេលមានជម្លោះនិងសេណារីយ៉ូអន្តរកាល។ គាត់រស់នៅក្នុងប្រទេសកម្ពុជាតាំងពីឆ្នាំ ២០១២ ដើម្បីធ្វើការស្រាវជ្រាវពីអំពើហិង្សាផ្លូវភេទក្នុងរបបខ្មែរក្រហម។

ការសំភាសន៍ត្រូវបានរៀបចំឡើងដោយកញ្ញា Thida Kim ដែលគាត់មាននាទីជាជំនួយការបច្ចេកទេសនៃគំរោងស្តីពីអំពើហិង្សាយេនឌ័ររបស់អង្គការចិត្តសង្គមអន្តរវប្បធម៌កម្ពុជា។ កញ្ញា Thida បានផ្តល់ការបកប្រែទាំងភាសាខ្មែរ និងភាសាអង់គ្លេស និងការផ្ទៀងផ្ទាត់ដ៏យកចិត្តទុកដាក់នៃការសំភាសន៍ដែលបានកែសម្រួលរួចជាមួយនឹងការថតសំលេងច្បាប់ដើម។ សព្វថ្ងៃនេះគាត់គឺជាអ្នកចិត្តវិទ្យាក្នុងដេប៉ាតឺម៉ង់ចិត្តវិទ្យានៃសកលវិទ្យាល័យភូមិន្ទភ្នំពេញ។

# ឧទ្ទិសកថា

ឯកសារនេះសូមឧទ្ទិសជូនចំពោះស្ត្រីនិងបុរសទាំងឡាយដែលត្រូវបានបង្ខំអោយរៀបការក្នុងរបបខ្មែរក្រហមនិងចំពោះអ្នកដែលបានតវ៉ាហើយត្រូវទទួលរងទណ្ឌកម្ម។

ភាពរឹងមាំក្នុងការយកឈ្នះទៅលើរឿងសោនាដកម្មនិងការប៉ះទង្គិច—ដូចបានបញ្ជាក់នៅក្នុងភាពរស់រវើកនៃយុវជនកម្ពុជាសម័យបច្ចុប្បន្ន—គឺជាសក្ខីភាពមួយបញ្ជាក់នូវស្មារតីជាមនុស្សដ៏ខ្លាំងក្លាដែលមិនអាចបំបាក់បាន។

# មាតិកា


អារម្ភកថា 1

សេចក្តីផ្តើម 3

ករណីសិក្សា

ករណីសិក្សាត្រូវបានរៀបចំតាមលំដាប់ ដើម្បីឆ្លើយតបទៅនឹងការដកស្រង់ពីរបាយការណ៍បន្ថែម "ដូចខ្មោចប្តូរកាយ"៖ ការសិក្សាស្រាវជ្រាវស្តីពីការប៉ះពាល់នៃការរៀបការដោយបង្ខំក្នុងរបបខ្មែរក្រហម (ធីភីអូកម្ពុជា ខែតុលា ឆ្នាំ ២០១៤)

ករណីសិក្សាទី ១

ស.ប.ឈ. ប្រុស អាយុ៦០ 7

ករណីសិក្សាទី ២

ច.ផ. ស្រី អាយុ៦៥ 19

ករណីសិក្សាទី ៣

អ.ប.ឈ. ប្រុស អាយុ៥៨ និង ស.ច. ស្រី អាយុ៥៤ 29

ករណីសិក្សាទី ៤

ហ.អ. ស្រី អាយុ៥២ 45

ករណីសិក្សាទី ៥

ប.ស. ស្រី អាយុ៥៣ 57

ករណីសិក្សាទី ៦

ហ.គ. ស្រី អាយុ៥៨ 67

ករណីសិក្សាទី ៧

ម.ស.អ. ស្រី អាយុ៦៥ 79

ករណីសិក្សាទី ៨

គ.ណ. ស្រី អាយុ៥៧, ខ្មែរចាម (អ៊ីស្លាម) 88

សទ្ទានុក្រម 93

# អារម្ភកថា

គិតមកដល់សព្វថ្ងៃនេះការបំផ្លិចបំផ្លាញប្រទេសកម្ពុជាដោយរបបខ្មែរក្រហមបានកន្លងផុតជិត៤ទស្សវតមកហើយ ប៉ុន្តែប្រជាជនកម្ពុជាបានបន្តរងទុក្ខពីរបួសផ្លូវចិត្តដ៏ច្រើនលើសលប់ពីរបបដ៏ឃោឃៅនេះតាំងពីកំរិតបុគ្គលរហូតដល់កំរិតសង្គមទាំងមូល។

អ្វីៗដែលបានកើតឡើង ក្នុងអំឡុងពេលកាន់កាប់ពីរបបខ្មែរក្រហមនេះបានត្រូវគ្របដណ្តប់ក្នុងភាពស្ងៀមស្ងាត់ និងអាថ៌កំបាំងអស់ពេលជាច្រើនឆ្នាំមកហើយ។ ទោះជាយ៉ាងណាក៏ដោយ ដំណើរការផ្លូវច្បាប់ទៅលើអតីតមេដឹកនាំជាន់ខ្ពស់នៃរបបនេះកំពុងដំណើរការនៅក្នុងអង្គជំនុំជំរះវិសាមញ្ញក្នុងតុលាការកម្ពុជា (អវតក) ដែលគេស្គាល់ថា សាលាក្តីខ្មែរក្រហមបានកំពុងដំណើរការ ទោះបីជាមានជំហានយឺតៗក៏ដោយ។ ដោយសារសេចក្តីក្លាហានរបស់ជនរងគ្រោះ និងអ្នករស់រានមានជីវិតដែលហ៊ានចេញមុខធ្វើសាក្ខីកម្មក្នុងនាមជាអ្នកដើមបណ្តឹងរដ្ឋប្បវេណីនៅអវតក និងដោយសារមានប្រជាជនកម្ពុជាជាច្រើនចង់ចែករំលែករឿងរ៉ាវឈឺចាប់របស់ខ្លួន។ ប្រទេសកម្ពុជា និងពិភពលោក បានមើលឃើញនូវភស្តុតាងកាន់តែច្រើនឡើងស្តីពីរបៀបដែលមនោគមន៍វិជ្ជានៃរបបនេះ បានអនុវត្តដោយបង្ខំមកលើប្រជាជនកម្ពុជា ដែលវាបានបន្សល់នូវផលវិបាកដ៏ធ្ងន់ធ្ងរមកលើសង្គមកម្ពុជាសព្វថ្ងៃនេះ។

នៅចុងឆ្នាំ២០១៤ អង្គការចិត្តសង្គមអន្តរវប្បធម៌( ធីភីអូកម្ពុជា )បានបោះពុម្ពរបាយការណ៍ នៃការស្រាវជ្រាវរបស់ខ្លួនស្តីពីអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងសម័យខ្មែរក្រហម ក្រោមចំណងជើងថា“**ដូចខ្មោចប្តូរកាយ**” ជាការសិក្សាស្តីពីផលប៉ះពាល់នៃការបង្ខំអោយរៀបការក្នុងសម័យខ្មែរក្រហម ដោយបណ្ឌិត Theresa de Langis, Judith Strasser, Thida Kim និង Sopheap Taing។

ការបោះពុម្ពលើកនេះជារបាយការណ៍បន្ថែមទៅលើការបោះពុម្ពនាឆ្នាំ២០១៤។ យើងសង្ឃឹមថា ការបោះពុម្ពទាំងស្រុងនូវករណីសិក្សាដែលបានសម្ភាសន៍ក្នុងកំឡុងពេលស្រាវជ្រាវស្តីពីការរៀបការដោយបង្ខំនោះអាចអោយអ្នកបានយល់កាន់តែស៊ីជំរៅថែមទៀតស្តីពីធម្មជាតិ និងផលប៉ះពាល់ដោយសារការរៀបការដោយបង្ខំនេះក្នុងរយៈពេលខ្លី និងរយៈពេលវែង។ លទ្ធផលនេះ ក៏បានបង្ហាញបន្ថែមទៀតនូវភាពខុសគ្នារវាងអ្វីដែលបានរៀបរាប់នៅក្នុងការសិក្សាស្តីពីការរៀបការដោយបង្ខំ មានតាំងពីករណីអ្នកដែលបានរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ហើយបានរស់នៅជាមួយគ្នាជាប្តីប្រពន្ធ និង បង្កើតគ្រួសារជាមួយគ្នា រហូតដល់អ្នកដែលត្រូវបានគេដាក់ទណ្ឌកម្មយ៉ាងដំណំដោយ ពួកគេប្រកែកមិនព្រមទទួលយកតាមការបង្ខំអោយរៀបការនេះ។ ក្នុងគ្រប់ករណីទាំងអស់  ភាពមិនទ្រុឌទ្រោមទន់ខ្សោយនៃស្មារតីរបស់មនុស្សបានកើតឡើងជាអនុភាព និងកំលាំងចលករមួយដ៏ខ្លាំង។

អង្គការឌីភីអូកម្ពុជា និងអ្នកដែលចូលរួមក្នុងការសិក្សានេះបានយល់ឃើញថាការផ្សព្វផ្សាយលទ្ធផលនៃការសិក្សានាពេលនេះគឺមានលក្ខណៈសមស្រប និងចំពេលវេលាល្អ ដោយសារអង្គហេតុនៃការរៀបការដោយបង្ខំ និងការរំលោភផ្លូវភេទដែលកើតឡើងក្នុងអាពាហ៍ពិពាហ៍នោះត្រូវបានគេលើកយកមកកាត់ទោសក្នុងករណី ០០២-០២ នៅឯ អវតក (និងជាផ្នែកមួយនៃទំងន់ទោសដែលបានចែងក្នុងករណី ០៤)។

តាមរយៈការបោះពុម្ពករណីសិក្សាទាំងនេះ  យើងចង់អោយមានការសន្ទនានៅតាមសហគមន៍ដោយបើកចំហរស្ត្រីអំពីបញ្ហាអតីតកាលជាវិថីសំរាប់ការសាងសង់អនាគត ដ៏ប្រសើរមួយហើយអនាគតគឺផ្អែកលើការគោរព និងភាពស្មើរគ្នាក្នុងគ្រួសារ និងសង្គម។

**បណ្ឌិត ឈឹម សុធារ៉ា**
នាយកប្រតិបត្តិ
អង្គការចិត្តសង្គមអន្តរវប្បធម៌កម្ពុជា

# សេចក្ដីផ្ដើម

កម្ពុជាប្រជាធិបតេយ្យ (ត្រូវបានស្គាល់ជាទូទៅថាជា"របបខ្មែរក្រហម") បានគ្រប់គ្រងប្រទេសកម្ពុជាពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។ សរុបទៅមានរយៈពេលបីឆ្នាំ ប្រាំបីខែ និងម្ភៃថ្ងៃ បានធ្វើឲ្យប្រជាជនជិតមួយភាគបួនស្លាប់ដោយសារការអត់ឃ្លាន អស់កម្លាំង ជំងឺ ការធ្វើទារុណកម្ម និងការកាប់សម្លាប់ និងដោយសារមូលហេតុផ្សេងៗទៀត។ របបគ្រប់គ្រងនេះគឺជារបបប្រល័យពូជសាសន៍ដ៏ឃោរឃៅជាងគេបំផុតក្នុងប្រវត្តិសាស្ត្រមនុស្សជាតិ។

បច្ចុប្បន្ននេះអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(អវតក)ដែលជាសាលាក្ដីកូនកាត់ដែលគាំទ្រដោយអង្គការសហប្រជាជាតិ កំពុងតែដំណើរការកាត់ក្ដីករណីចោទប្រកាន់មេដឹកនាំជាន់ខ្ពស់ដែលនៅរស់រានមានជីវិតនៃរបបខ្មែរក្រហមពីបទឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងអំពើប្រល័យពូជសាសន៍។ ចំនុចខុសប្លែកពិសេសមួយរបស់ អវតក គឺជនរងគ្រោះនិងអ្នករស់រានមានជីវិតអាចមានតួនាទីជាដើមបណ្ដឹងរដ្ឋប្បវេណីទៅឡើងបំភ្លឺនៅតុលាការអំពីបទពិសោធន៍របស់ពួកគេ និងទាមទារសំណងនិងវិធានការណ៍ក្រៅប្រពន្ធ័តុលាការចំពោះការរងគ្រោះដែលបានកើតឡើង។ ក្នុងចំណោមក្រុមធំបំផុតនៃបណ្ដឹងរដ្ឋប្បវេណី គឺជាក្រុមដែលទាក់ទិននឹងករណីរៀបការដោយបង្ខំដែលត្រូវបានកំណត់ដោយតុលាការក្នុងសំណុំរឿង០០២-០២នាពេលថ្មីៗ នេះ ថាជាគោលការណ៍មួយក្នុងចំណោមគោលការណ៍ទាំងប្រាំដែលត្រូវបានប្រើដោយរបបនោះដើម្បីសម្រេចគោលដៅមនោគមវិជ្ជារបស់ខ្លួន និងបង្កើតសង្គមមួយដែលមានលក្ខណៈសមូហភាព។

ការសំភាសន៍ចំនួនប្រាំបីត្រូវបានបញ្ចូលក្នុងអត្ថបទនេះ ដែលជាការបំពេញបន្ថែមទៅនឹងការស្រាវជ្រាវដោយវិធីសាស្ត្រចម្រុះ "ដូចខ្មោចប្ដូរកាយ"៖ ការសិក្សាអំពីផលប៉ះពាល់នៃការរៀបការដោយបង្ខំក្រោម

របបខ្មែរក្រហម" ដែលធ្វើឡើងដោយអង្គការចិត្តសង្គមអន្តរវប្បធម៌
(ធីភីអូ) បានចេញផ្សាយនៅក្នុងខែតុលា ឆ្នាំ២០១៤ ។ ការសិក្សានេះ
បានសំភាសន៍ដើមបណ្តឹងរដ្ឋប្បវេណីចំនួន១០៦នាក់នៅក្នុងសំណុំរឿង
០០២-០២ តាមរយៈការស្ទង់មតិដែលប្រើទម្រង់បរិមាណ ហើយនិង
អ្នកតបសំភាសន៍ចំនួនប្រាំបួននាក់ ដែលសំភាសន៍ដោយប្រើប្រាស់
កម្រងសំនួរបើកដើម្បីបង្កើតមូលដ្ឋានគ្រឹះ នៃករណីសិក្សាបែបគុណភាព
ចំនួនប្រាំបី(រួមទាំងប្តីប្រពន្ធដែលបានសំភាសន៍រួមគ្នា)។ នេះជាការ
សំភាសន៍ករណីសិក្សាទាំងបុរស និងស្ត្រីដែលជាអ្នករស់រានមានជីវិត
ដែលត្រូវបានបង្ហាញពេញលេញនៅក្នុងរបាយការណ៍នេះ គ្រប់ដណ្តប់
ទៅលើព្រឹត្តិការណ៍ ដែលបានកើតឡើងនៅរាជធានីភ្នំពេញ តាកែវ
សៀមរាប បាត់ដំបង ពោធិ៍សាត់ កំពង់ ឆ្នាំង កំពត និងក្នុងចំណោម
បណ្តាខេត្តដទៃទៀត។

កញ្ញា Thida KIM អតីតអ្នកជំនួយបច្ចេកទេសគម្រោងអំពើហិង្សា
យេនឌ័រនៃអង្គការចិត្តសង្គមអន្តរវប្បធម៌(ធីភីអូ)បានធ្វើការសំភាសន៍
ប្រាំបីករណីហើយអ្នកតបសំភាសន៍ បានទទួលការគាំទ្រផ្លូវចិត្តដើម្បី
កាត់បន្ថយការរើឡើងវិញនូវការប៉ះទង្គិចផ្លូវចិត្ត។ ការសំភាសន៍នេះត្រូវ
បានធ្វើឡើងជាភាសាខ្មែរ ចំណែកឯការថតសម្លេងត្រូវបានធ្វើការកត់
ត្រាជាអត្ថបទទៅជាភាសាអង់គ្លេសដោយផ្ទាល់។ លោកស្រី Theresa
DE LANGIS អ្នកឯកទេសជាន់ខ្ពស់ស្តីពីអំពើហិង្សាផ្លូវភេទនៅក្នុងជម្លោះ
បានធ្វើការកែសម្រួលកំណត់ត្រារៀបរៀងចងក្រងជាករណីសិក្សា ហើយ
បន្ទាប់មកត្រូវបានគេបកប្រែត្រឡប់មកវិញជាភាសាខ្មែរដោយមានការ
ផ្ទៀងផ្ទាត់ជាមួយសម្លេងថតដើម។ នៅក្នុងការកែសម្រួលករណីសិក្សា
យើងបានរក្សាការសំងាត់ដោយដកចេញព័ត៌មានអត្តសញ្ញាណលម្អិត
(ឈ្មោះមនុស្សបានជំនួសដោយអក្សរកាត់ ឈ្មោះ កន្លែងត្រូវបានជំនួស
ដោយអក្សរ xx)។ ទោះបីជាយើងបានខិតខំប្រឹងប្រែងអស់ពីលទ្ធភាព
ក្នុងការរក្សាសំឡេងរបស់អ្នកតបសំភាសន៍ ពេលខ្លះយើងក៏មានការកែ
សំរួលដើម្បីអោយសាច់រឿងមានភាពច្បាស់លាស់ និងពាក់ព័ន្ធគ្នា។
សំណួរសំភាសន៍បានសង្ខេបខ្លីៗដើម្បីកំណត់អាទិភាពចម្លើយ។

សទ្ទានុក្រមត្រូវបានរួមបញ្ចូលនៅទំហំខាងក្រោយសម្រាប់ពាក្យខ្មែរនៅក្នុងអត្ថបទដែលបានកត់ត្រាជាអក្សរទ្រេត។ អ្នកអានក៏ត្រូវបានលើកទឹកចិត្តឲ្យពិនិត្យឡើងវិញនូវការសិក្សាស្រាវជ្រាវដោយប្រើវិធីសាស្ត្រចម្រុះសម្រាប់ការពិភាក្សាកាន់តែទូលំទូលាយអំពីវិធីសាស្ត្រ លិខិតយល់ព្រមតបសំភាសន៍ បរិបទប្រវត្តិសាស្ត្រ និងការរកឃើញ។

ប្រាប់បញ្ចូលគ្នានៃរូបភាពនៃភាពផ្សេងគ្នា និងភាពមិនផ្លាស់ប្តូរនៃការអនុវត្តគោលនយោបាយអាពាហ៍ពិពាហ៍នៃខ្មែរក្រហមបានទទួលការចាប់អារម្មណ៍យ៉ាងខ្លាំង។ ការសំភាសន៍ជាច្រើនបានឆ្លុះអំពីភាពខុសប្លែកគ្នារវាងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ក្នុងជំនាន់ខ្មែរក្រហមហើយនិងការរៀបការបែបប្រពៃណីដ៏សម្បូរណ៍ហ៊ឺហា រួមទាំងការរៀបការដោយមានការរៀបចំពីចាស់ទុំនៅសម័យមុនរបបខ្មែរក្រហម។ សារៈសំខាន់នៃវប្បធម៌នៃការរៀបការចំពោះបុគ្គលម្នាក់ៗជាពិសេសសម្រាប់ស្ត្រី ត្រូវបានពិពណ៌នាជានិមិត្តរូបសំខាន់ដូចទៅនឹង "ដូចខ្មោចប្តូរកាយ"។ ប៉ុន្តែអាពាហ៍ពិពាហ៍ដ៏មានខ្លឹមសារសំខាន់សម្រាប់ជីវិត ត្រូវបានគោលនយោបាយខ្មែរក្រហមដណ្តើមយក ដែលជាញឹកញាប់បានចាត់តាំងជនចម្លែករៀបការអោយនៅជាមួយគ្នា បន្ទាប់មកបានបញ្ជាឱ្យពួកគេបំពេញមុខងារប្តីប្រពន្ធតាមរយៈការរួមភេទ ដែលស្ថិតនៅក្រោមការឃ្លាំមើលរបស់កងចល័តស៊ើបការណ៍ខ្មែរក្រហម។ ការអនុវត្តន៍នេះបានរៀបរាប់ដោយអ្នកតបសំភាសន៍ ម្នាក់ថាជាការប្រមាថដល់សេចក្តីថ្លៃថ្នូរជាមនុស្ស ដែលបុរសនិងស្ត្រីត្រូវបានចាប់ផ្ទឹមគ្នាដូចជា "សត្វឆ្មានិងឆ្កែ"។ ផ្ទុយទៅវិញ អ្នកដែលបានបដិសេធត្រូវបានរងការគំរាមកំហែងឬទទួលរងការដាក់ទណ្ឌកម្មដ៏ធ្ងន់ធ្ងររួមទាំងការធ្វើទារុណកម្មផ្លូវភេទផងដែរ។ ដូចនេះ មិនចាំបាច់ឆ្ងល់ទេដែលថា អ្នកតបសំភាសន៍ភាគច្រើនបានរៀបរាប់ថា កត្តាជំរុញក្នុងការយល់ព្រមតាមការបង្ខំរៀបការគឺដើម្បីរក្សាជីវិតតែប៉ុណ្ណោះ។

ការរៀបការដោយបង្ខំត្រូវបានពិពណ៌នានៅក្នុងកិច្ចសំភាសន៍ ថាជាទម្រង់នៃអំពើហិង្សាផ្លូវភេទ និងអំពើហិង្សាយេនឌ័រទៅលើបុរស និងស្ត្រីហើយលទ្ធផលមានភាពស្មុគស្មាញនិងខុសៗគ្នា។ ផលប៉ះពាល់យូរ

អង្វែងនៃការរៀបការដោយបង្ខំដូចដែលបានពិពណ៌នារួមមាន៖ ភាពក្រីក្រ ការរើសអើង ស្លាកស្នាមទុរយិស និងភាពអាម៉ាស ហើយផលប៉ះពាល់ទាំងនេះបានបន្តដល់ច្រើនជំនាន់ក្រោយៗទៀត។ ប៉ុន្តែនៅពល់ករណីសិក្សា ឪពុកម្តាយប្រាប់នូវរឿងដែលពោរពេញដោយការស្រឡាញ់ដ៏ជ្រាលជ្រៅ និងការលះបង់ដ៏ធំធេងចំពោះកូនរបស់ពួកគេ ហើយនេះជាការបង្ហាញនូវសារដែលពិសេសមួយសំរាប់អនាគតនៃក្មេងជំនាន់ក្រោយនៃក្តីសង្ឃឹមដែលវាលប់ទៅលើសោកនាដកម្មទាំងនោះ។

ក្នុងការចែករំលែករឿងរ៉ាវផ្ទាល់ខ្លួនអំពីការរំលោភបំពានទាំងនោះ វាទាមទារឱ្យមានសេចក្តីក្លាហានដ៏ពិសេសមួយ—មនុស្សដែលហ៊ានបំបែកនូវភាពស្ងាត់ស្ងៀមទៅលើប្រធានបទមួយដែលកម្រនឹងយកមកនិយាយពិភាក្សាជាសាធារណៈ ដោយសារតែអ្នករស់រានមានជីវិតនិងក្រុមគ្រួសារជាច្រើនគិតថាជារឿងផ្ទាល់ខ្លួន។ យើងខ្ញុំមានការដឹងគុណចំពោះអ្នកដែលបានយល់ព្រមអោយសំភាសន៍ ហើយនេះជាកិត្តិយស និងជាបុព្វសិទ្ធិពិសេសដែលយើងខ្ញុំនាំយកការសំភាសន៍ទាំងនេះឱ្យទស្សនិកជនកាន់តែច្រើនបានយល់ដឹង និងរក្សាទុកជាប្រវត្តិសាស្ត្រ។ យើងខ្ញុំមានសេចក្តីអំណរអរគុណចំពោះគម្រោង Civil Peace Service នៃ Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) for GmbH ផងដែរដែលបានគាំទ្រក្នុងការបោះពុម្ពផ្សាយឯកសារទាំងនេះ និងអង្គការចិត្តសង្គមអន្តរវប្បធម៌ (ធីភីអូ) កម្ពុជា ព្រមទាំងអង្គការ United Nations Trust Fund to End Violence Against Women ចំពោះធន្ទះដ៏មុតមាំក្នុងការជួយគាំទ្រដល់ជនរងគ្រោះនៃអំពើហិង្សាផ្លូវភេទនិងយេនឌ័រក្នុងសម័យខ្មែរក្រហម។ យើងខ្ញុំជឿជាក់ថារឿងរ៉ាវផ្ទាល់ខ្លួនទាំងនេះនឹងជួយរួមចំណែកដល់ការយល់ដឹងកាន់តែប្រសើរឡើងទាក់ទិនទៅនឹងការរៀបការដោយបង្ខំ និងទម្រង់រំលោភបំពានយេនឌ័រផ្សេងទៀតក្នុងគ្រាមានជម្លោះ និងសោកនាដកម្ម ដើម្បីធានាថាអំពើបែបនេះនឹងមិនកើតឡើងជាថ្មីម្តងទៀតឡើយ។

កញ្ញា Thida KIM និង លោកស្រី Theresa DE LANGIS
រាជធានីភ្នំពេញ ប្រទេសកម្ពុជា ខែមេសា ឆ្នាំ២០១៥

# ករណីសិក្សា ១

សបឈ អាយុ ៦០ឆ្នាំ
សំភាសន៍នៅថ្ងៃទី ២៩ មេសា ២០១៤
នៅទីក្រុងភ្នំពេញ នៅអង្គការចិត្តសង្គមអន្តរវប្បធម៌កម្ពុជា។

**ពូខ្ញុំមានចំណាប់អារម្មណ៍ចង់ដឹងពីប្រវត្តិរបស់ពូ និងពីការរៀបការរបស់ពូក្នុងរបបខ្មែរក្រហម។ តើពូមានបានរៀបការមុនរបបខ្មែរក្រហមដែរឬទេ?**

ទេ ខ្ញុំមិនទាន់រៀបការទេមុនរបបខ្មែរក្រហម។ ខ្ញុំមានអាយុប្រហែល២១ឆ្នាំពេលខ្មែរក្រហមចូលកាន់អំណាច។ ខ្ញុំបានជំលៀសទៅឃុំ xx ស្រុក xx ខេត្ត xx។ ឪពុកម្តាយរបស់ខ្ញុំត្រូវបានគេចាប់ខ្លួនក្នុងឆ្នាំ១៩៧៣ ហើយពួកគាត់ត្រូវបានគេធ្វើទារុណកម្មរហូតដល់ឆ្នាំ១៩៧៦។ ខ្ញុំបានរើទៅរស់នៅផ្ទះរបស់ពូជាមួយប្អូនប្រុសខ្ញុំ។ ខ្ញុំមានតែប្អូនប្រុសម្នាក់ ហើយខ្ញុំជាកូនបង យើងបានទៅគ្រប់ទីកន្លែងជាមួយគ្នា ហើយពេលខ្ញុំទៅដល់ឃុំ xx ខ្ញុំចាំថាមានឪពុកមាម្នាក់ដែលរស់នៅក្បែរនោះ។ គាត់ជាអ្នកមូលដ្ឋាន។[១] ដូច្នេះខ្ញុំជិះរទេះគោទៅរកកន្លែងដែលឪពុកមាខ្ញុំរស់នៅ។ អ្នកភូមិជាច្រើនដែលរស់នៅក្នុងភូមិខ្ញុំក៏បានគេចទៅរស់នៅក្នុងភូមិរបស់ឪពុកមាខ្ញុំដែរ។ នៅតាមផ្លូវ ខ្មែរក្រហមបានឃាត់ប្អូនប្រុសខ្ញុំនិងខ្ញុំ។ ពួកគេសង្ស័យថាយើងកំពុងព្យាយាមគេចមិនធ្វើទាហានពីព្រោះពួកយើងគឺធំល្មមនឹងធ្វើជាកងទ័ពបាន។ បន្ទាប់មកគេក៏ឈប់សង្ស័យយើង ពីព្រោះឪពុកមារបស់ខ្ញុំជាអ្នកមូលដ្ឋាន ហើយពួកយើងបានរស់នៅជាមួយគាត់។ ខ្ញុំមិនមែនជាទាហាន ពីព្រោះខ្ញុំបានបួសជាព្រះសង្ឃនៅក្នុងវត្តមុនរបបខ្មែរក្រហម។ ខ្ញុំបានរស់នៅជាមួយឪពុកមាមួយរយៈ កាប់ដើមឈើ និងជួយគាត់ធ្វើស្រែ។ បន្ទាប់មក ខ្ញុំត្រូវបានគេឱ្យទៅចូលកងចល័តនៅទំនប់ xx។

**តើនៅពេលណាដែលពូបានដឹងថាពូនឹងត្រូវរៀបការ?**

ខ្ញុំរៀបការនៅឆ្នាំ១៩៧៦ ខ្ញុំមិនដឹងថាខ្ញុំនឹងត្រូវរៀបការទេ។ មេខ្មែរក្រហមម្នាក់បានប្រាប់ខ្ញុំថា "មិត្តឯងរៀបចំរបស់របរមិត្តឯងរួចទៅនៅ

១ សូមមើលសទ្ទានុក្រម "អ្នកមូលដ្ឋាន"

សមរភូមិមួយទៀត”។ គាត់ប្រាប់ខ្ញុំ ពេលព្រលប់ៗ ហើយក៏នាំខ្ញុំទាំងយប់ទៅសហករថ្មី។ តាមពិតខ្ញុំ មិនបានដឹងថាតើអ្វី បានកើតឡើងនាពេលនោះទេ ពេលខ្ញុំទៅដល់សហកររួចហើយ—សមាជិកខ្មែរក្រហមបានរៀបចំពិធីរៀបការសំរាប់ខ្ញុំ។ ពេលទៅដល់ មានមនុស្សខ្លះបានរៀបការរួចស្រេចទៅហើយ។ ដំបូងខ្ញុំគិតថាខ្ញុំត្រូវបានគេនាំមកដើម្បីអបអរសាទរប្តីប្រពន្ធថ្មីថ្មោង។ តាមពិតទៅ ខ្ញុំត្រូវបានគេហៅមកឱ្យប្តេជ្ញាជាប្តីប្រពន្ធសោះ ខ្ញុំត្រូវយកផ្កាឱ្យទៅកូនក្រមុំ ហើយទទួលផ្កាពីកូនក្រមុំមកវិញ។ ខ្ញុំមានអារម្មណ៍ភ្ញាក់ផ្អើលពេលខ្ញុំបានដឹងពីអ្វីដែលបានកើតឡើង និងបានឃើញពិធីរៀបការចំឡែកបែបនេះដែលខ្ញុំមិនដែលបានជួបពីមុន។

ខ្ញុំរៀបការពេលព្រឹកប្រហែលជាម៉ោង៧ព្រឹក ទាហានខ្មែរក្រហមបានបង្ខំខ្ញុំអោយប្តេជ្ញាហើយខ្ញុំនិយាយមិនចេញនោះទេ តក់ស្លុតហួសនឹងនិយាយ។ ខ្ញុំសួរឈ្លប “តើអ្នកឯងនាំខ្ញុំមកនេះដើម្បីរៀបការមែនទេ ?” គាត់ក៏ឆ្លើយថា មែន ខ្ញុំត្រូវតែរៀបការ។ ខ្ញុំ ប្រកែកថាខ្ញុំមិនស្គាល់នាងហើយឈ្លបនោះឆ្លើយថា៖ “ទោះបីមិត្តឯងមិនស្គាល់មិត្តនារីនេះ *អង្គការ* បានរៀបចំការរៀបការឱ្យមិត្តឯង ដូច្នេះមិត្តឯងត្រូវតែទទួលយក។” ខ្ញុំមានអារម្មណ៍ថាចិត្តរបស់ខ្ញុំបានហោះចេញពាក់កណ្តាលពីខ្លួនខ្ញុំពីព្រោះវាចំឡែក និងកើតឡើងរហ័សពេក។ ខ្ញុំមិនទាន់ចង់រៀបការទេ។

[ពិធី] ធ្វើនៅកន្លែងប្រជុំសំខាន់មួយដែលនៅក្បែរសហករផ្សេងៗ។ នៅកន្លែងប្រជុំមាន មេឃុំ មេក្រុម ឈ្លប និងមនុស្ស៦នាក់ទៀត [ជាប់ទាក់ទងនឹងខ្មែរក្រហមដែរ]។ មានមនុស្សសរុបប្រហែលជា២០ទៅ៣០នាក់។ គេបានរៀបចំកៅអីនិងតុសំរាប់ពិធីនោះ។ មានប្តីប្រពន្ធប្រហែលជា៧គូ។ មេក្រុមនិងមេឃុំអង្គុយលើកៅអីហើយគេហៅយើងឡើងមកប្តេជ្ញាទទួលនិងប្រគល់ផ្កាឱ្យគ្នាទៅវិញទៅមក។ ខ្ញុំយល់ព្រមយកផ្កាដោយសារតែវាជាគោលការណ៍របស់អង្គការ។

## តើពូមានអារម្មណ៍បែបណាដែរ ពេលពូបានឃើញប្រពន្ធរបស់ពូ?

> “ ខ្ញុំមានអារម្មណ៍ថា ចិត្តរបស់ខ្ញុំបានហោះចេញពាក់កណ្តាលពីខ្លួនខ្ញុំ ពីព្រោះវាចំឡែក និងកើតឡើងរហ័សពេក។ ខ្ញុំមិនទាន់ចង់រៀបការទេ។

ខ្ញុំបានស្គាល់គាត់ [ប្រពន្ធដែលគេរៀបចំឱ្យ] ប៉ុន្តែខ្ញុំមិនបានស្រឡាញ់នាងទេ បានត្រឹមតែស្គាល់នាងជាអ្នកជិតខាងរួសរាយម្នាក់។ យើងរស់នៅជាអ្នកជិតខាងក្នុងភូមិ មុនរបបខ្មែរក្រហម។ ក្នុងរបបខ្មែរក្រហម យើងរស់នៅក្នុងសហករផ្សេងគ្នា ប៉ុន្តែនាងនៅក្នុងកងចល័តដែរ។ ខ្ញុំក៏ធ្វើការនៅកងចល័តដែរ។ ខ្ញុំជីកប្រឡាយ រែកដី ដាំពោត និងកាប់ឈើជាមួយមនុស្សផ្សេងទៀតដោយមិនរអ៊ូរទាំទេ។ បន្ទាប់មក ថ្ងៃមួយពេលត្រឡប់មកពីធ្វើការវិញ ខ្ញុំត្រូវបានគេនាំទៅសហករមួយទៀតហើយត្រូវបានរៀបការនៅព្រឹកបន្ទាប់។

និយាយត្រង់ទៅ ខ្ញុំមិនបានគិតថាខ្ញុំពិតជារៀបការទេនាពេលនោះពីព្រោះវាហាក់ដូចជាខ្ញុំត្រូវបានជួបជនចំឡែកអញ្ចឹង។ បន្ទាប់ពីពិធីរៀបការ យើងត្រូវបានគេបង្ខំអោយរស់នៅជាមួយគ្នាក្នុងផ្ទះតូចមួយដែលគេបានរៀបចំអោយពួកយើង។ ខ្ញុំមានអារម្មណ៍ចំឡែកនៅពេលដែលប្រពន្ធខ្ញុំដើរតាមខ្ញុំនៅយប់នោះបន្ទាប់ពីពិធីរៀបការរួច ពីព្រោះខ្ញុំគិតថាវាមិនសក្តិសមដែលខ្ញុំរៀបការជាមួយនាង។ ខ្ញុំគ្រាន់តែនិយាយជាមួយនាងប៉ុណ្ណោះនាយប់នោះ [ជាលើកដំបូង]។

ខ្ញុំសួរនាង "មិត្ត តើមិត្តបានដឹងថាមិត្តនឹងរៀបការជាមួយខ្ញុំទេ?" នាងប្រាប់ខ្ញុំថានាងមិនបានដឹងដូចគ្នាថាគេនឹងបង្ខំនាងឱ្យរៀបការ។ ខ្ញុំសួរនាង "តើមិត្តគិតយ៉ាងណាដែរឥឡូវនេះពេលយើងបានរៀបការអញ្ចឹង?" នាងឆ្លើយថា នាងមិនទាន់ចង់រៀបការនៅឡើយទេ។ នាសម័យនោះយើងធ្វើការហត់ណាស់ ហើយយើងមិនមានកំលាំងនោះទេ។ ខ្ញុំក៏ប្រាប់នាងថា "ឥឡូវនេះយើងបានរៀបការហើយ យើងត្រូវតែនៅជាមួយគ្នា។ ប្រសិនបើយើងមិនរស់នៅជាមួយគ្នាយើងនឹងត្រូវគេសង្ស័យថាមិនដើរតាម*អង្គការ*។

**ពេលពូនិយាយប្រាប់គាត់អញ្ចឹង តើគាត់មានប្រតិកម្មបែបណាដែរ?**

នាងអៀនណាស់ ក្នុងពេលនោះ យើងមិនបានឃើញគ្នានោះទេពីព្រោះយើងទៅធ្វើការផ្សេងៗគ្នាក្នុងកងចល័ត។ នាងតែងតែក្រោកពីដំណេកពីព្រលឹម ដែលខ្ញុំមិនអាចដឹងថានាងក្រោកម៉ោងប៉ុន្មានទេ។ ពេលយប់យើងគ្រាន់តែដេកនៅជិតគ្នារយៈពេលមួយខែ យើងគ្រាន់តែដេកនៅក្បែរៗគ្នា។ យើងទាំងពីរនាក់ជាអ្នកយល់ស្របធ្វើបែបនេះ។

បន្ទាប់មក មេកងក៏បានព្រមានខ្ញុំពីព្រោះយើងមិនទាន់រួមដំណេកនឹងគ្នា [មានទំនាក់ទំនងផ្លូវភេទ] ច្រើនខែមកហើយ [បន្ទាប់ពីពិធីរៀបការរួច]។ មេកងព្រមានខ្ញុំថា "ខ្ញុំដឹងថាមិត្តឯងមិនស្រឡាញ់ប្រពន្ធទេ។"[២] ខ្ញុំតបថា "ខ្ញុំស្រឡាញ់។" គាត់បន្តថា "ខ្ញុំឃើញមិត្តឯងបង្កើតកំហុសច្រើនណាស់។ ប្រសិនបើមិត្តមិនគោរពតាមគោលការណ៍អង្គការទេប្រយ័ត្ន"។ ខ្ញុំបារម្ភខ្លាំងណាស់ ខ្ញុំបារម្ភខ្លាចគេដឹង។ ប្រពន្ធរបស់ខ្ញុំកាន់តែរន្ធត់ថែមទៀត។ ពេលគាត់ដេកនៅក្បែរខ្ញុំខណៈដែលឈ្លបតាមលបស្តាប់យើងពេលយប់។ គេព្រមានខ្ញុំម្តង ហើយបន្ទាប់មកយើងបានរៀបចំការនិយាយទុកជាមុនក្នុងករណីដែលយើងត្រូវគេសួរម្តងទៀត។ យើងមានគំរោងថាប្រសិនបើខ្មែរក្រហមសួរយើង យើងនឹងឆ្លើយថាយើងបានរួមដំណេកជាមួយគ្នាហើយ។ តាមពិតទៅយើងមិនបានដេកជាមួយគ្នាទេ។[៣] នោះគឺជាគំនិតរបស់ខ្ញុំ។ ខ្ញុំគិតថាប្រពន្ធរបស់ខ្ញុំនឹងមិនរួមដំណេកជាមួយខ្ញុំទេលុះត្រាណាតែនាងស្រឡាញ់ខ្ញុំ ហើយវាអាចមានបញ្ហានាពេលខាងមុខ។ ខ្ញុំមិនមានចំណង់ផ្លូវភេទជាមួយនាងទេឬក៏រក្សានាងទុកជាប្រពន្ធទេ ពីព្រោះខ្ញុំមិនបានស្រឡាញ់នាងទាល់តែសោះ។

បន្ទាប់មកគេក៏បញ្ជូនយើងឱ្យទៅនៅជិតទន្លេ ហើយនៅទីនោះយើងដាំបន្លែ។ យើងត្រូវបានគេបញ្ជូនទៅនៅឆ្ងាយពីសហកររបស់ពូខ្ញុំ កុំឲ្យប្រពន្ធរបស់ខ្ញុំនឹងរត់ទៅដេកផ្ទះពូរបស់ខ្ញុំក្នុងសហករនោះ[ជាផ្នែកមួយនៃកងចល័តរបស់យើង]។ ពួកយើងបានរួមដំណេក[៤] ជាមួយគ្នាបន្ទាប់ពីយើងត្រូវបានគេបញ្ជូនទៅមាត់ទន្លេស្ទើរតែមួយឆ្នាំបន្ទាប់ពីរៀបការរួច។

## ពេលពូមកដល់មាត់ទន្លេ តើនៅទីនោះយ៉ាងដូចម្តេចដែរ?

យើងរស់នៅឆ្ងាយពីសហករ [ពីពូរបស់ខ្ញុំ] ហើយខ្ញុំគិតថាយើងងាយនឹងត្រូវគេយកទៅឆ្ងាយឬសំលាប់ណាស់។ ប្រសិនបើយើងរស់នៅសហករ គេនឹងមិនហ៊ានទេពីព្រោះពូរបស់ខ្ញុំជាប្រជាជនមូលដ្ឋានហើយគាត់ជាអ្នកដឹកនាំឈ្លប។ គាត់ចាស់ ហើយគាត់ឈប់ធ្វើការទៀត ផ្ទុយទៅវិញសមាជិកខ្មែរក្រហមនៅតែគោរពគាត់ និងអញ្ជើញគាត់ឱ្យជួយក្នុងពិធីផ្សេងៗ។ គាត់បានព្រមានខ្ញុំដែរថាឱ្យប្រយ័ត្នពីព្រោះខ្ញុំមិនបានរួមដំណេកជាមួយប្រពន្ធ។ ដូច្នេះខ្ញុំបានអង្វរប្រពន្ធដោយត្រង់ៗឱ្យរួមដំណេកជាមួយគ្នា[៥] ពីព្រោះថាប្រសិនបើមិនធ្វើដូចនេះ យើងនឹងត្រូវគេបំបែកហើយសំលាប់។ ខ្ញុំបានសុំនាង២ទៅ៣ដង ហើយនាងក៏យល់ព្រមបន្ទាប់ពី៦ខែក្រោយ ហើយយើងបានរួមដំណេកជាមួយគ្នាពេលយើងរស់នៅមាត់ទន្លេ ហើយយើងមានភាពឯកជនគ្រប់គ្រាន់ដើម្បីសង្គ្រោះជីវិតរបស់ពួកយើង។

ឆាប់ៗបន្ទាប់ពីនោះមក យើងត្រូវបានគេបំបែកពីគ្នា។ ខ្ញុំទៅធ្វើការនៅកងចល័ត ហើយប្រពន្ធរបស់ខ្ញុំធ្វើការនៅសហករ។ យើងត្រូវបានគេអនុញ្ញាតឱ្យមកផ្ទះ៣ទៅ៤ខែម្តងដើម្បីអោយជួបគ្នា។ ពេលប្រពន្ធរបស់ខ្ញុំមានផ្ទៃពោះ គេអនុញ្ញាតឱ្យខ្ញុំទៅលេងនាងញឹកញាប់។ ប៉ុន្តែខ្ញុំមិនបាននៅយូរទេពីព្រោះខ្ញុំធ្វើការគ្រប់ទីកន្លែងនៅកងចល័ត។ បន្ទាប់មក របបខ្មែរក្រហមដួលរលំ ២ខែក្រោយមកខ្ញុំនិងប្រពន្ធខ្ញុំបានត្រឡប់ទៅភូមិរបស់យើង។

## តើមូលហេតុអ្វីបានជាពូបែកគ្នាពីប្រពន្ធ?

តាមពិតទៅ ខ្ញុំមិនបានគិតថាយើងគួរបែកគ្នានោះទេបន្ទាប់ពីរៀបការរួច។ ផ្ទុយទៅវិញ យើងមិនបានស្រឡាញ់គ្នាឬមានគំរោងរៀបការនឹងគ្នាទេនាសម័យនោះ។ វាជាគំនិតរបស់យើងថាបែកគ្នា ពីព្រោះមានការឈ្លោះប្រកែកមួយដែលយើងមានតាំងពីរបបខ្មែរក្រហមមកម្ល៉េះ។[៦] ពេលយើងធ្វើការជាមួយគ្នានៅមាត់ទន្លេ យើងត្រឡប់ទៅធ្វើការវិញប្រហែលជាម៉ោង១រសៀលទោះបីយើងត្រូវចំអិនបាយម្ហូបដោយខ្លួនឯងក៏ដោយ។[៧]

**២**
សបបឈ ប្រើប្រាស់ភាសាកូដក្នុងការនិយាយពីទំនាក់ទំនងផ្លូវភេទ។ ដូចដែលបានបង្ហាញកាន់តែច្បាស់ក្នុងការសំភាសន៍ គាត់និងប្រពន្ធរបស់គាត់មិនបានមានទំនាក់ទំនងផ្លូវភេទក្នុងឆ្នាំបន្ទាប់ពីការរៀបការ ទោះបីជាពួកគេស្ថិតនៅក្រោមការឃ្លាំមើលរបស់ឈ្លបខ្មែរក្រហមដែលជាអ្នកត្រួតត្រាលើទំនាក់ទំនងផ្លូវភេទរបស់ពួកគេ

**៣**
ពួកគេមិនបានរួមភេទជាមួយគ្នា

**៤, ៥**
មានទំនាក់ទំនងផ្លូវភេទ

**៦**
សូមមើលសទ្ទានុក្រម “ប៉ុលពត”

**៧**
ក្នុងន័យមួយទៀត ចំអិនបាយចំណាយពេលបន្ថែមទៀតក្នុងពេលសំរាកអាហារថ្ងៃត្រង់ដ៏ខ្លី [Ed.].

ថ្ងៃមួយ ខ្ញុំចាប់បានត្រីមួយ ហើយឱ្យប្រពន្ធខ្ញុំធ្វើម្ហូបពេលថ្ងៃត្រង់។ ប្រពន្ធរបស់ខ្ញុំបានសកស្រកាត្រីនោះចេញហើយវាចំណាយពេលយូរក្នុងការចំអិន។ ខ្ញុំរអ៊ូហើយនិយាយ ថានាងល្ងង់ នាងខឹងណាស់ ហើយយំរួចនិយាយថា "ប្រសិនបើខ្ញុំល្ងង់ ម៉េចឯងមិនព្រមប្រកែកមិនរៀបការ?" ខ្ញុំក៏តបថា "ខ្ញុំមិនអាចប្រកែកបានទេ ពីព្រោះខ្ញុំនឹងត្រូវគេសំលាប់ប្រសិនបើខ្ញុំប្រកែក។" បន្ទាប់មកនាងបាននិយាយមកកាន់ខ្ញុំ ដែលធ្វើអោយខ្ញុំមិនអាចបំភ្លេចបាន៖ "ទ្រាំរហូតដល់ត្រឡប់ទៅភូមិកំនើតវិញ"។ នាងមានន័យថាតាំងពីខ្ញុំប្រមាថនាងនិយាយថានាងល្ងង់ ហើយនៅទទួលយកការរៀបការដោយសារតែការបង្ខំ ចាំរហូតដល់ពេលរបបខ្មែរក្រហមដួលរលំ ហើយយើងអាចបែកគ្នាបាន។

នាងតែងតែចងចាំនូវការសន្យារបស់នាង។ នាងនិយាយពាក្យនោះនៅឆ្នាំ១៩៧៧ ហើយនៅឆ្នាំ១៩៧៩ យើងបែកគ្នាបន្ទាប់ពីរបបខ្មែរក្រហមបាត់បង់អំណាច។ នាងត្រឡប់ទៅភូមិរបស់នាងវិញទៅរស់នៅជាមួយម្តាយ។ ខ្ញុំមិនបានហាមឃាត់នាងទេពីព្រោះនាងបាននិយាយក្នុងរបបនោះហើយថានាងនឹងចេញពីខ្ញុំ។ តាមពិតទៅយើងទាំងពីរមិនបានពេញចិត្តនឹងអាពាហ៍ពិពាហ៍នេះទេ។ ខ្ញុំមិនដែលរំពឹងថាខ្លួនឯងនឹងទទួលយកនាងជាប្រពន្ធនោះទេ។ នាងបានទៅរស់នៅជាមួយឪពុកម្តាយរបស់នាងបានប្រហែលជាពីរសប្តាហ៍។ ពេលនោះម្តាយឪពុករបស់នាងបានមកជួបខ្ញុំនិយាយថា គេចង់ឱ្យយើងរស់នៅជុំគ្នាពីព្រោះយើងបានរៀបការរួចហើយ ហើយប្រពន្ធរបស់ខ្ញុំមានផ្ទៃពោះទៀត។ គេអញ្ជើញខ្ញុំអោយទៅរស់នៅជាមួយពួកគេ ហើយខ្ញុំក៏ទៅរស់នៅជាមួយនឹងពួកគេ។ ពេលកូនរបស់ខ្ញុំកើតមក ខ្ញុំក៏គិតដែរថាយើងមិនគួរបែកគ្នាទេ។ ប៉ុន្តែប្រពន្ធរបស់ខ្ញុំប្រកែកមិនដេកនៅជាមួយខ្ញុំ ដូច្នេះបន្ទាប់ពី២ខែក្រោយខ្ញុំបានសំរេចចិត្តបែកពីនាងម្តងទៀត។

**ខ្ញុំឆ្ងល់តើមូលហេតុអ្វីបានជាពូសំរេចចិត្តទៅរស់នៅជាមួយឪពុកម្តាយរបស់គាត់?**

ពីព្រោះខ្ញុំនៅម្នាក់ឯង។ ខ្ញុំមិនមានឪពុកម្តាយនឹងគេ ហើយប្អូនប្រុសរបស់ខ្ញុំបានស្លាប់ [ក្នុងរបបនោះ]។ ខ្ញុំគិតថាវានឹងប្រសើរបើខ្ញុំរស់នៅជាមួយឪពុកម្តាយក្មេក ហើយនឹងប្រពន្ធខ្ញុំហើយនឹងទទួលយកគ្នាទៅវិញទៅមកពីមួយពេលទៅមួយពេល។ តាមពិត នាងមិនបានចង់បន្តរួមរស់ជាមួយនឹងខ្ញុំក្នុងអាពាហ៍ពិពាហ៍នេះទេ ហើយនាងនិយាយរំលឹកឡើងវិញពីឃ្លាដែលនាងបាននិយាយពីរបបខ្មែរក្រហម ថាយើងគួរតែបែកគ្នាបន្ទាប់ពីរបបនេះត្រូវបានគេរំដោះ។ នាងតែងតែរំលឹកឡើងវិញពីការឈ្លោះប្រកែកគ្នា "ប្រសិនបើខ្ញុំលូង់ យើងអាចបែកគ្នាពេលខ្ញុំជួបឪពុកម្តាយរបស់ខ្ញុំវិញ ពីព្រោះវាពិបាកណាស់ក្នុងការរស់នៅជាមួយខ្ញុំ" ហើយនាងបានយំជាញឹកញាប់។

*"ខ្ញុំបានសុំនាង២ទៅ៣ដង ហើយនាងក៏យល់ព្រមបន្ទាប់ពី៦ខែក្រោយ ហើយយើងបានរួមដំណេកជាមួយគ្នាពេលយើងរស់នៅមាត់ទន្លេ ហើយយើងមានភាពឯកជនគ្រប់គ្រាន់ដើម្បីសង្គ្រោះជីវិតរបស់ពួកយើង។*

ប្រពន្ធរបស់ខ្ញុំបានផ្តល់កំនើតដល់កូនស្រី ហើយរស់នៅជាមួយម្តាយរបស់នាងបន្ទាប់ពីយើងបែកគ្នា ហើយខ្ញុំបានទៅលេងនាងញឹកញាប់ដែរ គេរស់នៅប្រហែលជា១០គីឡូម៉ែត្រពីផ្ទះរបស់ខ្ញុំ។ ឥឡូវនេះ កូនស្រីរបស់ខ្ញុំបានរៀបការហើយមានកូនទៀត។ ពេលខ្ញុំបែកពីប្រពន្ធ ខ្ញុំបានឱ្យអ្វីៗទាំងអស់ដើម្បីឧបត្ថម្ភនាងនិងកូនស្រី ដូចជាគោ ក្របី និងរទេះគោ។ ខ្ញុំបានទាំងទិញឈើទៅសង់ផ្ទះឱ្យនាងនិងកូនស្រីទៀតផង។

**តើពូរស់នៅម្នាក់ឯងបន្ទាប់ពីបែកគ្នាមែនទេ?**

ខ្ញុំរៀបការប្រពន្ធថ្មីប្រហែលជាប្រាំបីខែបន្ទាប់ពីបែកគ្នា។ ខ្ញុំសំរេចចិត្តរៀបការម្តងទៀត ពីព្រោះខ្ញុំរស់នៅម្នាក់ឯង។ ប្រពន្ធទី២របស់ខ្ញុំ នាងរស់នៅក្នុងភូមិជាមួយខ្ញុំ។ នាពេលនោះខ្ញុំធ្វើជាមេក្រុមនៅក្នុងឃុំ និងរៀបចំក្រុមស្រ្តីមេម៉ាយ។ ខ្ញុំបានស្រឡាញ់ស្រ្តីមេម៉ាយម្នាក់ហើយស្នើរសុំនាង

រស់នៅជាមួយខ្ញុំ។ ប្រពន្ធរបស់ខ្ញុំក្រោយនេះមិនដែលបង្កបញ្ហាអ្វីក្នុងផ្ទះនោះទេ។ ខ្ញុំមានកូនពីរនាក់ជាមួយនាង។

**តើពូនៅទៅលេងប្រពន្ធមុនញឹកញាប់ដែរឬទេ?**

បាទ ហើយតាមពិតទៅខ្ញុំអញ្ជើញនាងមកផ្ទះយើងចូលរួមពិធីមួយមុនចូលឆ្នាំខ្មែរក្នុងឆ្នាំ២០១៤។ ខ្ញុំមិនដឹងថាហេតុអ្វីបានជានាងមិនរៀបការនោះទេ ប៉ុន្តែនាងតែងតែនិយាយថានាងមិនចង់រៀបការទៀតទេ។ មានបុរស២ទៅ៣នាក់ដែលបានស្នើសុំនាងរៀបការប៉ុន្តែនាងមិនយល់ព្រម។ វាហាក់ដូចជានាងខូចចិត្តតាំងពីរបបខ្មែរក្រហមមកម្ល៉េះ។ បន្ទាប់ពីយើងរៀបការ នាងបាននិយាយថានាងមិនចង់រៀបការម្តងទៀតទេ នាងគ្រាន់តែចង់រស់នៅម្នាក់ឯងហើយនាងខំប្រឹងធ្វើការណាស់។

នាងស្គមខ្លាំងណាស់ហើយឈឺស្ទើរតែនឹងស្លាប់បន្ទាប់ពីនាងផ្តល់កំណើតដល់កូនស្រីរបស់យើងរួច។ ខ្ញុំមិនដែលធ្លាប់បានគិតថាប្រពន្ធរបស់ខ្ញុំមានផ្ទៃពោះទេក្នុងរបបនោះ។ យើងមិនបានដឹងអំពីរឿងនោះទេ ប៉ុន្តែនាងមានផ្ទៃពោះពីព្រោះយើងបានរស់នៅជាមួយគ្នានិងរួមដំណេកជាមួយគ្នាដើម្បីសង្គ្រោះជីវិតរបស់យើង។ ប្រសិនបើយើងមិនរួមដំណេកនិងគ្នាយើងនឹងត្រូវគេសំលាប់។[៨] និយាយត្រង់ទៅ ខ្ញុំមិនដែលធ្លាប់រំពឹងថា យើងអាចមានកូននឹងគ្នានោះទេ។ យើងធ្វើការហត់ណាស់ហើយមានអាហារតិចតួចនិងកំលាំងខ្សោយ។ ប្រពន្ធរបស់ខ្ញុំខ្លាចមានកូនជាពិសេសគឺការមានផ្ទៃពោះដែលមិនបានគ្រោងទុក។ ប៉ុន្តែនាងស្រឡាញ់កូនស្រីណាស់។

**តើកូនស្រីរបស់ពូបានដឹងលំអិតពីការរៀបការរបស់ពូដែរឬទេ?**

តាមពិតទៅ កូនស្រីរបស់ខ្ញុំទើបតែដឹងថាខ្ញុំនិងប្រពន្ធរបស់ខ្ញុំបានរៀបការក្នុងរបបខ្មែរក្រហម។ ប៉ុន្តែកូនស្រីខ្ញុំមិនបានដឹងថាយើងត្រូវគេបង្ខំឱ្យរៀបការនោះទេ។ ដូចគ្នានឹងកូនរបស់ប្រពន្ធទីពីរខ្ញុំដែរ។ ខ្ញុំមិនបានប្រាប់កូនថាត្រូវគេបង្ខំឱ្យរៀបការនោះទេ ពីព្រោះខ្ញុំមិនចង់ឱ្យគេមានអារម្មណ៍ថាមានកំហុស។ តាមពិតទៅខ្ញុំមិនមានបញ្ហាធំដុំជាមួយប្រពន្ធទីមួយ

នោះទេ។ យើងគ្រាន់តែមិនមានទំនាក់ទំនងជិតស្និទ្ធ។ ផ្ទុយទៅវិញ ខ្ញុំមានទំនាក់ទំនងល្អជាមួយប្រពន្ធក្រោយរបស់ខ្ញុំ។

**ដូចពូបាននិយាយមុននេះ ពូមិនបានពេញចិត្តនឹងការរៀបការដោយបង្ខំតាំងពីដំបូង។ បន្ទាប់ពីពូបានរស់នៅជាមួយប្រពន្ធរបស់ពូបានមួយរយៈ តើពូមានបានចង់បន្តរស់នៅជាមួយគាត់ទោះបីជារបបខ្មែរក្រហមចប់ដែរឬទេ?**

បាទ ខ្ញុំគិតអញ្ចឹងមែន។ ក្នុងរបបខ្មែរក្រហម សមាជិកខ្មែរក្រហមអនុញ្ញាតឱ្យយើងធ្វើផ្ទះនិងកាប់ដើមឈើមកធ្វើផ្ទះដើម្បីរស់នៅជាមួយនាង [នៅតាមមាត់ទន្លេ]។ ខ្ញុំបាន ផ្តើមគិតថាយើងអាចរស់នៅជាមួយគ្នារហូតនិងមានកូនជាមួយគ្នានៅទីនោះ។ ពេលរបបខ្មែរក្រហមរលំ ខ្ញុំបានប្រាប់ប្រពន្ធ[ទី១]ខ្ញុំថា ប្រសិនបើយើងនៅទីក្បែរមាត់ទន្លេ ក្នុងផ្ទះរបស់យើង យើងអាចទៅនេសាទត្រីហើយវានឹងងាយស្រួលសំរាប់ជីវិតរបស់យើង។ ខ្ញុំនិយាយជាមួយនាងច្រើនណាស់ ហើយព្យាយាមបញ្ចុះបញ្ចូលនាង។ ទោះបី ជាអ្នកជិតខាង [នៅក្បែរមាត់ទន្លេ] ក៏អង្វរឱ្យនាងនៅដែរ។ ប៉ុន្តែបន្ទាប់ពីពីរខែក្រោយមកនាងនៅតែប្រកែក ដូច្នេះខ្ញុំបាននាំនាងទៅភូមិកំនើតវិញដើម្បីទៅរស់នៅជាមួយឪពុកម្តាយ។ នាងតែងតែចងចាំពាក្យដែលខ្ញុំនិយាយទៅកាន់នាងថា "អ្នកឯងល្ងង់"។

ខ្ញុំមិនបានចង់ក្លាយជាពោះម៉ាយទេ ហើយខ្ញុំក៏មិនចង់ឱ្យប្រពន្ធរបស់ខ្ញុំទៅជាស្ត្រី មេម៉ាយនោះដែរ។[៩] ខ្ញុំអាណិតនាង ហើយនោះជាហេតុផលដែលខ្ញុំចង់បន្តរស់នៅជាមួយនាង។ ខ្ញុំប្រាប់នាងថាខ្ញុំមិនចង់បែកគ្នាទេ ហើយខ្ញុំចង់មានប្រពន្ធតែមួយ ទោះបីយើងទាំងពីរត្រូវបានគេបង្ខំអោយរៀបការក៏ដោយ។ ខ្ញុំមានអារម្មណ៍អាណិតអាសូរប្រពន្ធខ្ញុំណាស់ដែលឪពុកម្តាយរបស់យើងមិនបានរៀបចំពិធីរៀបការឱ្យយើង ពីព្រោះវាជាពិធីសំខាន់សំរាប់ជីវិតរបស់ស្ត្រីគ្រប់រូប។ ផ្ទុយទៅវិញ ក្រោយមកឪពុកម្តាយរបស់នាងហើយសូម្បីតែអ្នកញាតិជិតខាងបានទទួលស្គាល់យើងជាប្តីប្រពន្ធនឹងគ្នា ដូច្នេះយើងគួរតែបង្កើតជីវិតជាប្តីប្រពន្ធរបស់យើងឱ្យប្រសើរឡើង ទោះបីជាយើងមិនបានមានពិធីរៀបការតាមប្រពៃណីក៏ដោយ។

៨
ម្តងទៀត ភាសាកូដត្រូវបានប្រើ។ អត្ថន័យទូទៅគឺថាគេមិនបានដឹងពីបញ្ហាផ្លូវភេទ និងការបន្តពូជ ប៉ុន្តែដោយសារតែគេត្រូវបានតំរូវអោយរួមភេទ បើមិនដូច្នេះទេអាចនឹងប្រឈមនឹងការស្លាប់ ដូច្នេះប្រពន្ធរបស់គាត់បានមានផ្ទៃពោះ

៩
សូមមើលសទ្ទានុក្រម "មេម៉ាយ."

ខ្ញុំគិតថាការបែកគ្នានឹងនាំអោយមានបញ្ហាប៉ះទង្គិច។ ប្រសិនបើយើងបែកគ្នា មនុស្សផ្សេងៗនឹងសួរយើងពីមូលហេតុដែលយើងបែកគ្នា។ ហើយខ្ញុំមិនចង់ឱ្យគេដឹងជាសាធារណៈថាជាប្ដីដែលបែកបាក់គ្នា ហើយបាត់បង់កិត្តិយសនោះទេ។ ខ្ញុំចង់ឱ្យគេសរសើរខ្ញុំថា ខ្ញុំមានគ្រួសារមួយដែលសុខសាន្តនឹងគ្នា—ដូចដែលខ្ញុំមានឥឡូវនេះ យើងមិនដែលមានបញ្ហាធំនឹងគ្នាជាមួយប្រពន្ធទី២របស់ខ្ញុំនោះទេ។ មានអង្គការខ្លះបានមកសហគមន៍របស់ខ្ញុំដើម្បីសំភាសន៍ប្ដីប្រពន្ធអំពីស្ថានភាពគ្រួសាររបស់ពួកគេ និងទំនាក់ទំនងរបស់គេ ហើយខ្ញុំតែងតែចូលរួមជាមួយប្រពន្ធទី២របស់ខ្ញុំ។ ពេលខ្លះពេលប្រពន្ធខ្ញុំ [ប្រពន្ធទីពីរ] នាងខឹង ខ្ញុំនៅស្ងៀម ហើយក្រោយមកយើងក៏ប្រសើរឡើងវិញ។ យើងទទួលស្គាល់ថាមនុស្សគ្រប់គ្នាតែងតែធ្វើខុស ហើយយើងមិនឱ្យបញ្ហារីករាលដាលទៅគ្រួសារទាំងមូលនោះទេ។ ប្រពន្ធក្រោយរបស់ខ្ញុំពិតជាយល់ និងលើកទឹកចិត្តខ្ញុំពេលខ្ញុំមានបញ្ហា។ ខ្ញុំគិតថាយើងពិតជាបង្ហាញការអាណិតអាសូរចំពោះគ្នា និងក្ដីមេត្តាចំពោះគ្នា។

ប្រពន្ធក្រោយរបស់ខ្ញុំមានចំណេះដឹងមធ្យម ប្រពន្ធមុនខ្ញុំមិនចេះអាននិងសរសេរទេ។ ខ្ញុំគិតថាប្រពន្ធមុនរបស់ខ្ញុំហើយនិងខ្ញុំមានកម្ម ពីព្រោះយើងរស់នៅជាមួយគ្នាបានតែមួយរយៈខ្លី ហើយបន្ទាប់មកយើងក៏បែកគ្នា។ ផ្ទុយទៅវិញ ខ្ញុំនៅតែអាណិតអាសូរប្រពន្ធមុនខ្ញុំ ពីព្រោះនាងមិនដែលនិយាយដើមគេ គាត់ទន់ភ្លន់ មិនដែលធ្វើអោយខ្ញុំអាម៉ាស់មុខនោះទេ។ មានតែហេតុផលមួយគត់ដែលនាងបានលើកឡើងអំពីការចង់បែកពីខ្ញុំ គឺការដែលយើងឈ្លោះប្រកែកគ្នាពីមុន "ប្រសិនបើខ្ញុំល្ងង់ហេតុអ្វីបានជាទទួលយកការរៀបការនេះ?"

### តើពូមានធ្វើពិធីរៀបការជាមួយប្រពន្ធក្រោយរបស់ពូដែរឬទេ?

បាទ យើងមានពិធីតូចតាចមួយដើម្បីជាការទទួលដឹងឮថាយើងបានរៀបការ ប៉ុន្តែខ្ញុំមិនបានមានពិធីធំដុំដូចសព្វថ្ងៃនេះទេ។ ប្រពន្ធរបស់ខ្ញុំជាស្ត្រីមេម៉ាយពីព្រោះប្ដីរបស់ នាងបានស្លាប់នារបបខ្មែរក្រហម។

តាមច្បាប់ ប្រសិនបើយើងចង់បាន យើងអាចមានលិខិតរៀបអាពាហ៍ពិពាហ៍បាន។ ជាមួយប្រពន្ធមុនរបស់ខ្ញុំយើងគ្រាន់តែបែកគ្នា ហើយចេញឆ្ងាយពីគ្នា—យើងគ្មានលិខិតស្នាមអ្វីនោះទេ។

**តាមដែលខ្ញុំបានឮមុននេះ ពូហាក់ដូចជាបារម្ភពីកិត្តិយសនិងការបែកបាក់អាចប៉ះពាល់ដល់កិត្តិយស។ តើប្រពន្ធរបស់ពូមុនមានការបារម្ភពីកិត្តិយសដែរឬទេ?**

តាមពិតទៅនាងក៏គិតពីបញ្ហានេះដែរ ហើយនាងមិនចង់អោយខ្ញុំប៉ះពាល់នាង និងគេងជាមួយនាងទេ។ នាងតែងតែទទូចថាយើងនឹងបែកគ្នាពេលយើងត្រឡប់ទៅភូមិវិញ... ក្នុងគំនិតរបស់ខ្ញុំ នាងសំរេចចិត្តរហ័សពេកថានាងថាមិនចង់បន្តជីវិតអាពាហ៍ពិពាហ៍ជាមួយខ្ញុំ។ នាងមានការខកចិត្តនឹងអ្វីដែលខ្ញុំបាននិយាយនៅពេលយើងឈ្លោះប្រកែកគ្នា។ វាជាកំហុសរបស់ខ្ញុំនាពេលនោះដែរ ប៉ុន្តែពាក្យរបស់ខ្ញុំបាននិយាយរួចបាត់ទៅហើយ។

ខ្ញុំនិយាយពាក្យទាំងនោះពីព្រោះខ្ញុំចង់មានពេលសំរាក ហើយនៅត្រូវត្រឡប់ទៅធ្វើការមុនពេលទៀត។ ពេលរបបខ្មែរក្រហមយើងមិនអាចទៅធ្វើការយឺតទេ ហើយយើងគោរពគោលការណ៍អង្គការពីព្រោះឈ្លបតែងតែយកការសំងាត់ពីយើង។ ប្រសិនបើ យើងទៅធ្វើការយឺត យើងនឹងត្រូវគេសង្ស័យក្នុងការធ្វើខុសហើយនឹងត្រូវសំលាប់។ ពេលមួយនោះក្នុងរបបនោះខ្ញុំស្ទើរតែត្រូវស្លាប់នៅពេលខ្ញុំមកពីស្ទូងយឺត ពីព្រោះមិត្តរបស់ខ្ញុំបបួលខ្ញុំទៅបាញ់ចាប។ មេក្រុមខ្មែរក្រហមទូន្មានខ្ញុំល្ងាចនោះ។ ពីពេលនោះមក ខ្ញុំចាប់ផ្តើមមានអារម្មណ៍ភ័យខ្លាចក្នុងការបង្កើតកំហុសទោះបីជាតូចតាចក៏ដោយ។ ខ្ញុំឃើញសមាជិកខ្មែរក្រហមយកមនុស្សទៅសំលាប់ចោលពេលគេធ្វើអ្វីខុស បានចោទប្រកាន់មនុស្សទាំងនោះថាមិនចង់ធ្វើការអោយ*អង្គការ*។

**នៅពេលពូនៅក្នុងរបបខ្មែរក្រហម តើពូបានធ្លាប់គិតថារបបនេះនឹងបញ្ចប់នាថ្ងៃណាមួយដែរឬទេ?**

ជាការពិតទៅខ្ញុំបានជួបបុរសម្នាក់ឈ្មោះ ស. ។ គាត់បានប្រាប់ខ្ញុំថារបបខ្មែរក្រហមនឹងមិននៅបានយូរអង្វែងទេពីព្រោះមានកំលាំងរើបំរះច្រើនណាស់។ គាត់ទូន្មានអោយខ្ញុំបត់បែនតាមកាលៈទេសៈ។ ខ្ញុំផ្តុះបញ្ចាំងទៅលើពាក្យពេចន៍របស់គាត់ ហើយគាត់និយាយត្រូវ។ យើងគួរតែសំរបខ្លួនក្នុងរបបនោះដើម្បីរស់ បើមិនដូច្នោះទេយើងនឹងប្រឈមមុខនឹងការត្រូវគេសំលាប់។ ត្រូវហើយ ខ្ញុំមិនដែលធ្លាប់គិតថានឹងរស់រានមានជីវិតរហូតដល់សព្វថ្ងៃនោះទេ ពីព្រោះខ្ញុំឃើញសាកសពមនុស្សស្លាប់ជាច្រើននៅជុំវិញខ្ញុំ ហើយមនុស្សកំពុងស្លាប់ម្តងម្នាក់ៗនៅពេលខ្ញុំជីកប្រឡាយនិងរែកដី។ ខ្ញុំមិនដែល ស្រម៉ៃថាខ្ញុំនឹងរស់រានមានជីវិតទេ ហើយខ្ញុំក៏មិនដែលគិតអំពីអនាគតដែរ។

# ករណីសិក្សា ២

ចផ អាយុ ៦៥ឆ្នាំ
សំភាសន៍នៅថ្ងៃទី ២៥ មេសា ២០១៤
នៅក្រុងភ្នំពេញ នៅអង្គការចិត្តសង្គមអន្តរវប្បធ៌កម្ពុជា។

**មីងបានរៀបការមុនរបបខ្មែរក្រហម តើមីងអាចប្រាប់ខ្ញុំពីការរៀបការនោះបានទេ?**

ចាស ខ្ញុំអាចប្រាប់បាន។ ខ្ញុំបានទៅរស់នៅជាមួយបងស្រីរបស់ខ្ញុំដែលរៀបការរួចម្នាក់នៅពេលដែលឪពុករបស់ខ្ញុំបានស្លាប់។ ខ្ញុំបានមើលថែទាំក្របីព្រោះយើងមានក្របីជាច្រើន។ ខ្ញុំមិនអាចទៅសាលា។ ខ្ញុំបានធ្វើការធ្ងន់នៅវាលស្រែដើម្បីជួយបងស្រីរបស់ខ្ញុំ។ ម្ដាយរបស់ខ្ញុំបាននិយាយថា "ឯងមិនបាច់ទៅសាលារៀនទេ។ ប្រសិនបើឯងទៅរៀនហើយចេះសរសេរ ឯងនឹងសរសេរសំបុត្រអោយប្រុសស្នេហ៍។ ដូច្នេះឯងមិនបាច់រៀនទេ។" ដូច្នេះខ្ញុំបានរស់នៅជាមួយបងស្រីហើយធ្វើការនៅផ្ទះ។ នៅពេលដែលបានទទួលសំណើរសុំរៀបការមួយ ខ្ញុំក៏បានទុកឱ្យបងស្រី និងម្ដាយខ្ញុំជាអ្នកធ្វើការសំរេចចិត្ត។ ខ្ញុំបានរៀបការនៅពេលដែលខ្ញុំមានអាយុ ១៥ ឆ្នាំ។

បងស្រីបានរៀបចំមង្គលការអោយខ្ញុំ។ គាត់តែងតែនិយាយថាបើមានបុរសអ្នកមានណាម្នាក់ចង់រៀបការជាមួយខ្ញុំ គាត់នឹងយល់ព្រម។ បុរសនោះជាអ្នកមានដូច្នេះហើយ ទើបគាត់យល់ព្រមឱ្យមករៀបការជាមួយខ្ញុំ។ ខ្ញុំមិនបានបដិសេធទេ។ ខ្ញុំគ្រាន់តែធ្វើតាមពួកគាត់ ខ្ញុំបានធ្វើតាមបងស្រី ម្ដាយ និងឪពុករបស់ខ្ញុំ។ ប្រសិនបើពួកគាត់ចង់ អោយខ្ញុំរៀបការជាមួយនរណាម្នាក់ខ្ញុំនឹងយល់ព្រម។ ហើយបន្ទាប់មក ប្រសិនបើមានការខុសឆ្គងចំពោះជំរើសរបស់ពួកគេ [ការរៀបការមិនបានល្អ] គ្រួសាររបស់ខ្ញុំនឹងបន្តជួយទំនប់បំរុងនិងមើលថែខ្ញុំ។ ប៉ុន្តែប្រសិនបើខ្ញុំធ្វើការសំរេចចិត្តដោយខ្លួនឯង ពួកគាត់នឹងមិនបន្តជួយមើលថែខ្ញុំទេ ប្រសិនបើ

ការសំរេចចិត្តរបស់ខ្ញុំមិនត្រឹមត្រូវ។ នេះគឺជាអ្វីដែលពួកគាត់បានប្រាប់ខ្ញុំ ឪពុកម្តាយ និងបងស្រីរបស់ខ្ញុំ។

**តើមីងអាចរៀបរាប់ពីការរៀបការរបស់មីងបានដែរឬទេ?**

ក្នុងកំឡុងពិធីភ្ជាប់ពាក្យ មានមនុស្សយកនំនិងផ្លែឈើ និងមានតន្ត្រី ហើយខ្ញុំមានខោអាវថ្មីជាច្រើនហើយមុខរបស់ខ្ញុំត្រូវបានតុបតែង។ ពេលដែលខ្ញុំមើលខ្លួនឯង ខ្ញុំបានដឹងខ្លួនឯងថាខ្ញុំនៅក្មេងណាស់រួចខ្ញុំក៏បានយំ។ ខ្ញុំបានអាណិតខ្លួនឯងដោយសារតែខ្ញុំនៅក្មេងហើយត្រូវបានរៀបការជាមួយបុរសចំណាស់ម្នាក់ដែលមានអាយុ៣៥ឆ្នាំ។ យើងមើលទៅដូចជាឪពុកនិងកូនស្រីនៅក្នុងមង្គលការនោះ។ គាត់ធ្លាប់បួសជាសង្ឃ។ គាត់បានសឹកដើម្បីរៀបការជាមួយខ្ញុំ។ ឪពុករបស់គាត់មិនសប្បាយចិត្តជាមួយខ្ញុំដោយសារតែខ្ញុំជាអ្នកក្រ ប៉ុន្តែបងប្អូនរបស់គាត់ចូលចិត្តខ្ញុំដោយសារតែខ្ញុំជាអ្នកឧស្សាហ៍ធ្វើការដូចមនុស្សប្រុស។ ប៉ុន្តែឪពុករបស់គាត់មិនចូលចិត្តខ្ញុំទេ។ ដោយសារតែបងប្អូនរបស់គាត់ចូលចិត្តខ្ញុំ និងស្រុះស្រួលជាមួយនឹងមង្គលការនេះ ហើយគាត់ក៏មិនបាន ខ្វាយខ្វល់ជាមួយនឹងការគិតរបស់ឪពុកគាត់ដែរ។

អាពាហ៍ពិពាហ៍របស់ខ្ញុំគឺល្អ។ ប្តីខ្ញុំបានជួយខ្ញុំទាំងការងារផ្ទះ និងស្រែចំការ ហើយគាត់យកចិត្តទុកដាក់ថែរក្សាខ្ញុំ។ គាត់មានការងារនៅឃុំ។ ខ្ញុំបានចាត់ទុកគាត់ដូចជាឪពុករបស់ខ្ញុំ។ ខ្ញុំអាណិតគាត់ដោយសារតែគាត់ហ៊ានប្រឆាំងនឹងឪពុករបស់គាត់ដើម្បីរៀបការជាមួយខ្ញុំ។ ប្តីរបស់ខ្ញុំមិនដែលវាយធ្វើបាបខ្ញុំឬបង្កទុក្ខទោសដល់ខ្ញុំនោះទេ។ គាត់ស្រឡាញ់ខ្ញុំ។ មានតែឪពុកក្មេករបស់ខ្ញុំទេដែលពិបាកជាមួយខ្ញុំ ដោយគាត់តែងតែប្រាប់ខ្ញុំឱ្យធ្វើនេះ ធ្វើនោះ ធ្វើបង្អែមផ្សេងៗ។ ខ្ញុំយំរាល់ថ្ងៃ។ វាត្រូវចំណាយពេល ច្រើនដើម្បីចំអិនអាហារអស់ទាំងនេះ ដោយសារតែខ្ញុំមិនបានដឹងអំពីរបៀបចំអិនទាល់តែសោះ។ ពេលដែលអាហារចំអិនរួច ខ្ញុំបានយកវាទៅអោយគាត់ តែគាត់បដិសេធមិនបរិភោគ។ គាត់បានងាកមុខចេញនិងមិនបានបរិភោគអ្វីទាំងអស់។ ខ្ញុំត្រូវតែអត់ធ្មត់ ហើយអង្វរ

គាត់យ៉ាងស្រួលឱ្យគាត់បរិភោគវា។ គាត់មិនចូលចិត្ត ខ្ញុំទេ។ នៅពេលដែលស្វាមីរបស់ខ្ញុំត្រូវទៅធ្វើការឆ្ងាយពីផ្ទះ ឪពុកក្មេករបស់ខ្ញុំតែងតែអោយខ្ញុំចាកចេញទៅ នៅទីណាដែលខ្ញុំចង់ទៅ។ គាត់មិនចង់អោយខ្ញុំនៅផ្ទះទេ នៅពេលដែលស្វាមីរបស់ខ្ញុំមិននៅ។ ម្ដាយរបស់ប្ដីខ្ញុំបានស្លាប់មុនពេលយើងរៀបការ។

> *ចាស អនុសេនីយឯកបានស្រឡាញ់ខ្ញុំ ហើយបានសំលាប់ប្ដីខ្ញុំដោយសារតែស្រឡាញ់ ខ្ញុំ។ អនុសេនីយឯក ប. បានសំលាប់ប្ដីខ្ញុំ ដូច្នេះគាត់អាចរៀបការជាមួយខ្ញុំបាន។*

**មីងនៅក្មេងណាស់ ដូច្នេះខ្ញុំឆ្ងល់ថាតើមីងបានយល់អំពីអាពាហ៍ពិពាហ៍ដែរឬក្នុងពេលនោះ?**

ខ្ញុំស្មានថាអាពាហ៍ពិពាហ៍គឺការរស់នៅជាមួយគ្នាដូចបងប្អូន។ ខ្ញុំមិនបានដឹងថាការរួមភេទជាផ្នែកមួយនៅក្នុងជីវិតអាពាហ៍ពិពាហ៍នោះទេ។ ជាដំបូងខ្ញុំមិនបានអោយស្វាមីរបស់ខ្ញុំប៉ះពាល់ខ្ញុំទេ។ មានពេលមួយនោះដែលគាត់ប៉ះពាល់ខ្ញុំ ខ្ញុំបានរត់ចេញពីព្រោះ ខ្ញុំខ្លាចគាត់សួរខ្ញុំថាហេតុអ្វីបានជាខ្ញុំខ្លាចខ្លាំងយ៉ាងនេះ។ ខ្ញុំបាននិយាយថា ខ្ញុំមិនបានដឹងថាប្ដីប្រពន្ធដែលបានរៀបការហើយត្រូវប៉ះពាល់គ្នាបែបនេះទេ ប្រសិនបើខ្ញុំបានដឹងខ្ញុំនឹងមិនរៀបការទាល់តែសោះ។ បន្ទាប់មកមានថ្ងៃមួយ បងប្អូនរបស់គាត់បានមកនិយាយជាមួយខ្ញុំ ពន្យល់ខ្ញុំថាប្ដីប្រពន្ធគួរត្រូវធ្វើអ្វីខ្លះក្រោយពេលរៀបការហើយ។ ដូច្នេះហើយទើបខ្ញុំបានដឹង។

**មីងបាននិយាយថាក្នុងរបបខ្មែរក្រហម មីងត្រូវបានគេដាក់ទារុណកម្មដោយសារតែ មីងប្រកែកមិនព្រមរៀបការជាមួយនឹងបុរសម្នាក់ទៀត។ តើមានអ្វីកើតឡើងចំពោះប្ដី ទីមួយរបស់មីងនាពេលនោះ?**

ចាស អនុសេនីយឯកបានស្រឡាញ់ខ្ញុំហើយបានសំលាប់ប្ដីខ្ញុំដោយសារតែស្រឡាញ់ ខ្ញុំ។ អនុសេនីយឯក ប. បានសំលាប់ប្ដីខ្ញុំ ដូច្នេះគាត់អាចរៀបការជាមួយខ្ញុំបាន។ អនុសេនីយឯក ប. គ្រប់គ្រងប្រជាជនប្រហែលជា៣៥០០០នាក់។

មួយថ្ងៃក្រោយម៉ោងធ្វើការខ្ញុំមិនបានឃើញប្ដីត្រឡប់មកនៅពេលបាយ

ថ្ងៃត្រង់។ ខ្ញុំមិនបានហូបបាយទេខ្ញុំបានព្យាយាមស្វែងរកគាត់។ ពេលខ្ញុំមិនបានឃើញគាត់មកវិញម៉ោងប្រហែលជា១០ មនុស្សបានប្រាប់ខ្ញុំថាឈប់រកទៅពីព្រោះគេបានឃើញគាត់ត្រូវបានគេយកទៅឆ្លងស្ពានទៅគុកនៅវត្ត xx បាត់ទៅហើយ។ មនុស្សទាំងនោះបានប្រាប់ ខ្ញុំថាអនុសេនីយឯក ប. បានបញ្ជាអោយមេកងនាំប្ដីរបស់ខ្ញុំទៅធ្វើការនៅកន្លែងថ្មីបាត់ហើយ។ ពេលខ្ញុំបានឮដូចនេះ ខ្ញុំចាប់ផ្ដើមស្រែកខ្លាំងៗថា "សូមនាំប្ដីរបស់ខ្ញុំត្រឡប់មកវិញមក។" ខ្ញុំត្រូវបានគេដាក់ច្រវាក់ដោយសារតែខ្ញុំស្រែករកប្ដី។ គេបានដាក់ច្រវាក់ ហើយនាំខ្ញុំទៅដាក់គុកនៅវត្ត xx។ ខ្ញុំត្រូវបានគេឃុំនៅទីនោះរយៈពេលមួយយប់ ហើយបន្ទាប់មកអនុសេនីយឯក ប. បានបញ្ជាអោយគេដោះលែងខ្ញុំ។ យប់បន្ទាប់ពីខ្ញុំត្រូវគេដោះលែង មេកងបានហៃរហមខ្ញុំទៅដាំដំឡូងនៅសាលាចិននៅ xx។

ពេលខ្ញុំទៅដល់សាលា ខ្ញុំបានឃើញមនុស្សនៅទីនោះរួចស្រេចទៅហើយ។ មានគូចំនួន៩គូរួមទាំងខ្ញុំ។ ដោយសារតែខ្ញុំត្រូវបានគេប្រាប់ឱ្យមកដាំដំឡូងនៅសាលា ខ្ញុំបានសួរទៅកាន់មេកងថា "មិត្តបងអោយខ្ញុំមកដាំដំឡូងមែនទេ?" គាត់ឆ្លើយតបថា "ទេ មិត្តឯងមកទីនេះដើម្បីរៀបការនិងអនុសេនីយឯក ប." ពេលឮដូចនេះខ្ញុំយំ។ ខ្ញុំបានតាំងចិត្តថាខ្ញុំនឹងមិនរៀបការនោះទេ។ គូមួយៗត្រូវបានគេឱ្យចាប់ដៃ ហើយដល់វេនខ្ញុំ មេកងនិយាយថា "មិត្តឡើងនិយាយ" ខ្ញុំបាននិយាយថា "ទេ ខ្ញុំមិនដឹងថា ប្ដីនរណានោះទេ ប៉ុន្តែនេះមិនមែនជាប្ដីរបស់ខ្ញុំនោះទេ។ ខ្ញុំនឹងមិនរៀបការនោះទេ ហើយអ្នកណាអាចយកខ្ញុំទៅណាក៏យកទៅ ខ្ញុំមិនខ្វល់នោះទេ។ ប្រសិនបើចង់សំលាប់ ពេលនេះ ក៏ខ្ញុំមិនខ្វល់ដែរ។ ខ្ញុំមិនដឹងថាតើឪពុកម្ដាយ និងបងប្អូនខ្ញុំនៅទីណាទេពេលនេះ ហើយពេលខ្ញុំនិយាយថាខ្ញុំមិនចង់រៀបការ គឺមានន័យថាខ្ញុំមិនរៀបការទេ។ ដូច្នេះសូមយកខ្ញុំទៅណាក៏យកទៅតាមតែអ្នកចង់" អនុសេនីយឯកបានទះកំផ្លៀងខ្ញុំ។ គាត់បានយកស្បែកជើងវាយក្បាលខ្ញុំ៤ទៅ៥ដង។ [ពេលដែលគាត់កំពុងវាយខ្ញុំ] គាត់បានសួរថា "រៀបការឬអត់?" ខ្ញុំនៅតែនិយាយថា "ទេ ទេ"។

អនុសេនីយឯក ប. បានបញ្ជាអោយអ្នកយាមរបស់គាត់នាំខ្ញុំទៅដាក់គុក នៅវត្ត xx។ គាត់បាននិយាយទៅកាន់អ្នកយាមថា "នាំវាទៅទីនោះ ហើយអញនឹងរំលោភវា [ពេលក្រោយ]។" នៅក្នុងគុក ខ្ញុំត្រូវបានគេដោះសំលៀកបំពាក់អស់ ហើយដាក់ច្រវាក់។ គេដាក់ច្រវាក់ជើងខ្ញុំកន្ធែកចេញពីគ្នា ហើយដៃរបស់ខ្ញុំអោយចេញពីគ្នា។ ខ្ញុំកាន់តែព្យាយាមរើ ច្រវ៉ាក់កាន់តែតឹង។ ខ្ញុំបានស្រែក ហើយអនុសេនីយឯក ប. បញ្ជាឱ្យអ្នកយាម វាយខ្ញុំដើម្បីឱ្យខ្ញុំឈប់ស្រែក។ ខ្ញុំស្រែកថា "យកខ្ញុំទៅណាទៅទៅលោកអើយ ប៉ុន្តែកុំធ្វើទារុណកម្មខ្ញុំពីព្រោះខ្ញុំមិនបានធ្វើអ្វីខុសនោះទេ។ ខ្ញុំបានរៀបការរួចហើយ ហើយខ្ញុំមិនរៀបការនឹងអ្នកណាទេ។ សូមដោះលែងខ្ញុំទៅ។" បន្ទាប់មកទាហានក្មេងៗ ប្រហែលជាអាយុ១៥ទៅ១៦ឆ្នាំ យកស្បែកជើងរបស់គេមកប៉ះប្រដាប់ភេទខ្ញុំ ហើយគេច្របាច់ដោះរបស់ខ្ញុំ ហើយថើបខ្ញុំរហូតដល់ខ្ញុំបាត់ស្មារតី។

ពេលខ្ញុំដឹងខ្លួនឡើងពេលព្រឹក ខ្ញុំបានឃើញអនុសេនីយ៍ឯក ប. ដេកក្បែរខ្ញុំ។ គាត់បាននិយាយថា "ឃើញអត់? ប្រសិនបើព្រមរៀបការជាមួយអញនោះនឹងមិនមានរឿងអញ្ចឹងទេ។ ទោះបីជាមិនព្រមក៏អញបានហើយ។" ហើយរាល់យប់ ខ្ញុំមិនដឹងថាតើទាហានក្មេងៗ នោះមកពីណាទេ ប៉ុន្តែគេបានមកវាយខ្ញុំ រំលោភខ្ញុំរហូតដល់បាត់ស្មារតី។ ហើយពេលខ្ញុំក្រោកឡើង ខ្ញុំបានឃើញអនុសេនីយឯក ប. នៅក្បែរខ្ញុំរហូត។

**តើមិនមាននរណាម្នាក់ឆ្លងកាត់គុកនោះ ហើយបានឮអ្វីកើតឡើងទេមែនទេ?**

មានតែក្រុមគេទេ មានតែក្រុមទាហានខ្មែរក្រហមទេ។ វាស្ងាត់ណាស់ ហើយមនុស្សមិនអនុញ្ញាតឱ្យមកជិតគុកនោះទេ។ ទាហានបានយាមជុំវិញគុកនោះ [ដើម្បីឱ្យដាក់ថាគ្មាននរណាមកក្បែរនោះ។] គុកនោះមានតែដំបូលឥតជញ្ជាំងទេ។ ខ្ញុំគ្មានគំនិតដឹងថាតើគុកនោះមានរូបរាងបែបណានោះទេនាពេលថ្ងៃ ពីព្រោះពួកយើងបានបាត់ស្មារតីទាំងអស់គ្នា។ យើងភ្ញាក់ដឹងខ្លួននៅម៉ោង៥ល្ងាច។ មានប្រហែលជា៥០ទៅ២០នាក់ជាប់គុកទីនោះទាំងអស់សុទ្ធតែជាស្ត្រី។

ករណីខ្លះត្រូវបានបញ្ជូនមកទីនេះដោយសារតែគេប្រកែកមិនរៀបការ ដូចករណីខ្ញុំដែរ។ គេរំលោភស្ត្រីទាំងនោះ។ គេយកប្រដាប់ភេទរបស់គេ ដាក់ចូលក្នុងមាត់របស់ពួកយើង ហើយយកវាមកដាក់នឹងមុខរបស់ យើង។ ខ្ញុំមិនបានដឹងថាតើមានមនុស្សប៉ុន្មាននាក់រំលោភខ្ញុំក្នុងមួយ យប់ៗនោះទេ។ គេរំលោភស្ត្រីនៅមុខពួកយើង ហើយខ្ញុំគ្រាន់តែបិទ ភ្នែក។ ខ្លួនរបស់ខ្ញុំញ័រអស់ហើយ។ ខ្ញុំយំទាំងថ្ងៃទាំងយប់។ ស្ត្រីផ្សេង ទៀតស្រែក និងយំផងដែរ។ មានស្ត្រីម្នាក់នាងស្អាតណាស់ ប៉ុន្តែនាង ស្លាប់បន្ទាប់ពីមួយយប់ក្រោយដោយសារគេរំលោភនាងរហូតដល់ស្លាប់។

**តើអ្នកណារំលោភមីងនៅក្នុងគុកនោះ?**

គឺទាហានក្មេងៗ និងអ្នកយាម។ រាល់យប់អនុសេនីយឯក ប. បានមក ហើយរំលោភខ្ញុំ។ អ្នកយាមក្មេងៗទាំងនោះបានវាយខ្ញុំហើយទះកំផ្លៀង ខ្ញុំរហូតដល់បាត់ស្មារតី បន្ទាប់មកអនុសេនីយឯក ប. បានមករំលោភខ្ញុំ។ ខ្ញុំដឹងថាជាអនុសេនីយឯក ប. ពីព្រោះខ្ញុំបានឃើញគាត់ដេកនៅ ក្បែរខ្ញុំ គ្រប់ពេលខ្ញុំភ្ញាក់ដឹងខ្លួន។

**តើមីងបានដឹងទេថាតើហេតុអ្វីបានជាគេធ្វើបែបនេះទៅលើមីងដែរឬទេ?**

ពីព្រោះខ្ញុំប្រកែកមិនព្រមរៀបការ។ មានបុរសម្នាក់ដែលធ្វើការនៅក្នុង គុកនោះជាអ្នកដឹកម្ហូបពី xx ទៅ xx ដូចជាអំបិល ត្រី និងបន្លែ។ ខ្ញុំបាន សុំអង្វរគាត់អោយជួយខ្ញុំ។ ខ្ញុំបាននិយាយថាខ្ញុំនឹងដឹងគុណគាត់ ហើយ នឹងថែរក្សាគាត់ពេលគាត់ចាស់ទៅ។ ដូច្នេះ គាត់ក៏បានឱ្យមាសជាច្រើន ទៅអនុសេនីយឯក ប. ដើម្បីប្តូរនឹងខ្ញុំ ហើយខ្ញុំក៏ត្រូវបានដោះលែង។

ខ្ញុំមិនបានដឹងទេថាហេតុអ្វីបានជាគាត់យល់ព្រមដោះលែងខ្ញុំនោះទេ។ អនុសេនីយ៍ឯក ប.បាន ប្រាប់ទៅបុរសចាស់នោះថាអោយថែរក្សាខ្ញុំឱ្យ បួសខ្ញុំជា។ គាត់បានឱ្យអ្នកយាមតាមខ្ញុំដើម្បីអោយច្បាស់ថាខ្ញុំត្រូវបាន គេថែរក្សាបានល្អ។ ខ្ញុំបានគិតថាគាត់ចង់បានខ្ញុំម្តងទៀតលើកក្រោយ នៅពេលខ្ញុំជា ដូច្នេះហើយបានជាគាត់ឱ្យអ្នកយាមទៅតាមខ្ញុំ ឬប្រហែល ជាខ្ញុំមិនច្បាស់ទេ។

**តើមីងគិតថាគាត់ដោះលែងមីងដោយសារតែគាត់អាណិតមីង?**

ខ្ញុំក៏មិនដឹងដែរ។ ខ្ញុំមិនមានគំនិតអ្វីទេ។

**តើហេតុអ្វីបានជាបុរសចាស់នោះយល់ព្រមជួយមីង?**

គាត់គ្មានបងប្អូន គ្មានឪពុកម្ដាយ ឬសាច់ញាតិនៅសល់ទេ [ដើម្បីថែរក្សាគាត់ពេលចាស់ទៅ] ដោយសារតែខ្មែរក្រហមបានសំលាប់ពួកគេអស់ហើយ។ ខ្ញុំបានឆ្លងកាត់ភូមិជាច្រើន ជាមួយបុរសចាស់នោះ ហើយអ្នកឃាមតាមឃើងរហូតគ្រប់កន្លែង។

**មីងត្រូវបានជាប់គុក ធ្វើទារុណកម្ម ហើយរំលោភដោយសារតែមីងមិន ព្រមរៀបការ។ តើមីងមានគិតនិងមានអារម្មណ៍បែបណាដែរនៅពេលនោះ ពេលមីងបានដឹងថានេះជាទណ្ឌកម្មរបស់មីង?**

ខ្ញុំមានអារម្មណ៍វេទនាណាស់ ហើយឯកា។ ប្រសិនបើគេស្នើសុំការរៀបការដូចការរៀបការខ្ញុំលើកទីមួយ ខ្ញុំប្រហែលអាចនឹងព្រមរៀបការ។ ខ្ញុំបានប្រកែកពីព្រោះគ្មានឪពុកម្ដាយ គ្មានភ្លេង គ្មានសាច់ញាតិ គ្មានអាចារ្យ គ្មានសំលៀកបំពាក់ និងគ្មានការតុបតែងមុខ ហើយខ្ញុំមិនបានឃើញមុខមនុស្សម្នាក់នោះ [មុនពេលរៀបការ]។ ខ្ញុំបានដឹងតែឈ្មោះ ហើយបន្ទាប់មកខ្ញុំត្រូវបានប្រាប់អោយរៀបការនឹងគាត់។ ខ្ញុំអាចនឹងព្រមរៀបការប្រសិនបើវាតាមប្រពៃណី ហើយមិនមែនជាការពិន័យដូច្នេះ។ ខ្ញុំបានគិតថាប្រសិនជាខ្ញុំប្រកែក ខ្ញុំនឹងត្រូវសំលាប់។ ខ្ញុំមិនបានដឹងដល់ថាមានការធ្វើទារុណកម្មក្រៅពីការសំលាប់នោះទេ។ គូផ្សេងៗទៀតគេយល់ព្រម គេនៅលីវទាំងអស់ពេលនោះ ហើយមានតែខ្ញុំទេដែលមេម៉ាយ។

> *“ខ្ញុំបានប្រកែកពីព្រោះគ្មានឪពុកម្ដាយ គ្មានភ្លេង គ្មានសាច់ញាតិ គ្មានអាចារ្យ គ្មានសំលៀកបំពាក់ និងគ្មានការតុបតែងមុខ ហើយខ្ញុំមិនបានឃើញ មុខមនុស្សម្នាក់នោះ [មុនពេលរៀបការ]។*

**ពេលមីងរៀបការជាមួយនិងប្ដីរបស់មីងមុនរបបខ្មែរក្រហម មីងក៏មិនបានស្គាល់គាត់ឬ ស្រឡាញ់គាត់ដែរពិតមែនទេ?**

ចាស ខ្ញុំមិនបានស្រឡាញ់គាត់ទេ។ ខ្ញុំធ្វើតាមបងស្រីរបស់ខ្ញុំ និងឪពុកម្ដាយរបស់ខ្ញុំ។

**តើការរៀបការទាំងពីរនេះខុសគ្នាដូចម្តេចដែរ?**

ខុសគ្នា។ សំរាប់ការរៀបការទី១របស់ខ្ញុំ ខ្ញុំធ្វើតាមឪពុកម្តាយ បងប្អូន ហើយទោះបីជាការរៀបការនោះខុសឆ្គង គេនឹងទទួលខុសត្រូវលើខ្ញុំ ហើយទុកខ្ញុំនៅក្នុងគ្រួសារ។ ខ្ញុំមិនប្រកែកដោយសារតែខ្ញុំមានឪពុកម្តាយ អាចារ្យ និងតន្ត្រីក្នុងពិធីរៀបការ ហើយនៅក្នុងរបបខ្មែរក្រហម គេមិនបានប្រាប់ខ្ញុំជាមុននោះទេ ហើយមិនបានសួរថាតើខ្ញុំព្រមឬអត់ទេ។ គេកុហកខ្ញុំថាអោយខ្ញុំទៅដាំជំឡូង។

ការរៀបការនារបបខ្មែរក្រហមគ្មានអត្ថន័យទេ។ គ្មានការចុះឈ្មោះរៀបការ។ គ្មានការទទួលដឹងឮអំពីការរៀបការ ឬប្តីប្រពន្ធថ្មី។ មនុស្សខ្លះត្រូវបានសំលាប់ បន្ទាប់ពីគេត្រូវបានគេបង្ខំឱ្យរៀបការ។ វាគ្មានន័យអ្វីទេ។

**តើពេលណារឿងនេះបានកើតមានលើ *មីង*?**

ប្រហែលជាឆ្នាំ១៩៧៨។ ប្តីរបស់ខ្ញុំបានស្លាប់ប្រហែលជា៨ខែមុនពេលវៀតណាមចូល។

**ប្រសិនបើមីងព្រមរៀបការជាមួយអនុសេនីយ៍ឯក ប. តើជីវិតរបស់មីងនឹងខុសប្លែកដែរឬទេពេលនេះ?**

ខ្ញុំបានគិតថាប្រសិនបើខ្ញុំបានយល់ព្រមរៀបការ គាត់នឹងនៅជាមួយខ្ញុំតែមួយគ្រា ហើយគាត់នឹងសំលាប់ខ្ញុំ។ ដូច្នេះ ខ្ញុំប្រកែកមិនរៀបការនឹងគាត់គឺប្រសើរជាង។

**ខ្ញុំបានដឹងថាមីងមានផ្ទៃពោះនៅក្នុងគុកពេលមានរឿងនេះកើតឡើងលើមីងតើពិតមែនទេ?**

ចាស ប្រហែលជាមានផ្ទៃពោះបីខែ។

**កូនរបស់មីងនៅតែមានសុខភាពល្អទោះបីជាមីងត្រូវបានគេធ្វើទារុណកម្ម?**

ចាស។

**បន្ទាប់ពីរបបខ្មែរក្រហមមីងបានរៀបការម្តងទៀត។ តើអ្វីដែលធ្វើអោយមីងសំរេចចិត្តរៀបការម្តងទៀត?**

ជីវិតនៅពេលនោះពិបាកណាស់។ បុរសដែលរៀបការហើយបានមកផ្ទះរបស់ខ្ញុំពេលយប់ហើយមករំខានខ្ញុំ និយាយលូកលាន់ខ្ញុំ ញ៉ែខ្ញុំ ហើយព្យាយាមបញ្ចុះបញ្ចូលខ្ញុំអោយរួមភេទនឹងគេ។ ពេលខ្លះពេលខ្ញុំទៅផ្សារ ឬចូលរួមពិធីក្នុងភូមិ គេបានស្ទាក់ផ្លូវខ្ញុំ ហើយព្យាយាមមកឱបខ្ញុំ ហើយប៉ះពាល់ខ្ញុំ ហើយខ្ញុំបានព្យាយាមគេចចេញ។ ខ្ញុំបានប្រាប់ទៅម្តាយនិងសាច់ញាតិខ្ញុំ ហើយគេបានណែនាំឱ្យខ្ញុំរៀបការជាមួយជីដូនមួយខ្ញុំ។ ខ្ញុំបានយំដូចនៅរបបខ្មែរក្រហមដែរ។

ខ្ញុំយំពីព្រោះខ្ញុំអាណិតខ្លួនខ្ញុំ។ តាំងពីកើតមក ខ្ញុំមានប្តីមុនរបបខ្មែរក្រហម ហើយបន្ទាប់មកក្នុងរបបខ្មែរក្រហមគេធ្វើបាបខ្ញុំ ហើយបន្ទាប់ពីរបបខ្មែរក្រហម បងប្អូនរបស់ខ្ញុំគេមានគ្រួសាររបស់គេ។ ដោយសារតែខ្ញុំធ្លាប់បានរៀបការរួចមកហើយ ខ្ញុំបានសំរេចចិត្តនៅម្នាក់ឯងជាមួយនឹងកូនប្រុសរបស់ខ្ញុំ។ ជីវិតរបស់ខ្ញុំវេទនាណាស់។ ខ្ញុំបានព្យាយាមប្រាប់បុរសៗដែលមានប្រពន្ធហើយថា ខ្ញុំមិនស្រឡាញ់ប្តីគេទេ ហើយសូមមើលប្តីរបស់អ្នកកុំអោយមករំខានខ្ញុំទៀត។ បងស្រីរបស់ខ្ញុំបានណែនាំអោយខ្ញុំរៀបការប្រសិនបើមានអ្នកណាស្នើរខ្ញុំពីព្រោះជីវិតរបស់ខ្ញុំគួរអោយរន្ធត់ណាស់។ ខ្ញុំបានសំរេចចិត្តរៀបការម្តងទៀតដើម្បីមានអ្នកការពារខ្ញុំពីបុរសដែលព្យាយាមមើលងាយខ្ញុំ។ ប្រសិនបើមិនមែនព្រោះតែអញ្ចឹងទេ ខ្ញុំនឹងមិនរៀបការទៀតទេ។ ខ្ញុំមិនចង់ឱ្យគេថាខ្ញុំមានប្តីច្រើន។ បងស្រីរបស់ខ្ញុំប្រាប់ខ្ញុំថាកុំឱ្យខ្វល់ពីអ្នកដទៃនិយាយ ហើយបងប្អូនរបស់ខ្ញុំមិនអាចការពារខ្ញុំបានទេពេលយប់ពេលប្រុសៗទាំងនោះមកព្យាយាមវាយប្រហារខ្ញុំបែបផ្លូវភេទ។

**តើប្តីរបស់មីងបានដឹងអំពីអ្វីដែលបានកើតមានលើមីងនារបបខ្មែរក្រហមដែរឬទេ?**

ចាស គាត់បានដឹងហើយគាត់មិនប្រកាន់ទេ។

**តើមីងមានបានរៀបចំពិធីរៀបការតាមប្រពៃណីសំរាប់ការរៀបការលើកទី២ដែរឬទេ?**

ទេ យើងគ្រាន់តែធ្វើពិធីប្រពៃណីខ្លះៗ ហើយមានគ្រួសារនិងចាស់ទុំចូលរួម ប៉ុន្តែមិនមែនពិធីរៀបការទាំងមូលនោះទេ។

**តើមីងមានកូនប៉ុន្មាននាក់ដែរ?**

កូន៨នាក់ រួមទាំងកូនប្រុសបងគេដែលជាកូនជាមួយនឹងប្តីមុនរបស់ខ្ញុំ។

**តើកូនរបស់មីងបានដឹងពីអ្វីដែលបានកើតឡើងលើមីងក្នុងរបបខ្មែរក្រហមដែរឬទេ?**

ចាស ខ្ញុំបានប្រាប់ពួកគេ។ គេយំ។ ខ្ញុំយំពេលខ្ញុំប្រាប់គេ ដូច្នេះទើបបានគេយំដែរ។ ខ្ញុំមិនប្រាប់អ្នកជិតខាងនោះទេ។ ប៉ុន្តែថ្មីៗនេះគេចេះតែសួរខ្ញុំអំពីអតិតកាលរបស់ខ្ញុំពីព្រោះគេឃើញអង្គការជាញឹកញាប់បានមកផ្ទះរបស់ខ្ញុំ។ បន្ទាប់មកខ្ញុំបានបង្ហាញគេនូវសៀវភៅសក្ខីកម្មរបស់ខ្ញុំ។[១០] គេអាណិតខ្ញុំហើយបានសរសើរខ្ញុំដែលបានអង្គការគាំទ្រខ្ញុំ ហើយវាល្អសំរាប់ខ្ញុំ។

**តើជីវិតអាពាហ៍ពិពាហ៍របស់មីងពេលនេះយ៉ាងណាដែរ?**

ខ្ញុំបែកដំណេកជាមួយនិងប្តីរបស់ខ្ញុំតាំងពីកូនចុងក្រោយរបស់ខ្ញុំកើត។ ពេលខ្ញុំបត់ជើងតូច ខ្ញុំមានអារម្មណ៍ឈឺហើយមានឈាម។ ប្តីរបស់ខ្ញុំចង់ឱ្យខ្ញុំជាសះស្បើយ គាត់មិនប្រកាន់ដែលយើងបែកដំណេកគ្នាទេ។ បន្ទាប់ពីរបបខ្មែរក្រហមមក ខ្ញុំបានទៅជួបពេទ្យវៀតណាម ដែលមកក្នុងភូមិព្យាបាលជំងឺ។ គេបានផ្តល់ថ្នាំឱ្យខ្ញុំ ហើយដោយសារតែថ្នាំនោះខ្ញុំបានប្រសើរ។ ប្រសិនបើមិនអញ្ចឹងទេ [ដោយសារថ្នាំនោះទេ] ខ្ញុំមិនដឹងថាជំងឺរបស់ខ្ញុំធ្ងន់ដល់កំរិតណានោះទេ។

# ករណីសិក្សា ៣

អបឈ ភេទប្រុស អាយុ ៥៨ឆ្នាំ និង សច ភេទស្រី អាយុ ៥៤ ឆ្នាំ ប្តីប្រពន្ធទាំងពីរត្រូវបានសំភាសន៍នៅថ្ងៃទី ២៣ មេសា ឆ្នាំ ២០១៤ នៅភ្នំពេញ។ ដើម្បីឱ្យការអានមានភាពងាយស្រួល ពាក្យ “ប្តី” និង “ប្រពន្ធ” ត្រូវបានប្រើ។

**ពូមីងបានរៀបការយូរមកហើយ។ តើពិធីរៀបការមានអត្ថន័យបែបណាដែរចំពោះពូមីង?**

ប្តី: បច្ចុប្បន្ននេះ មង្គលការត្រូវបានរៀបចំឡើងតាមប្រពៃណី ហើយរួមបញ្ចូលទាំងការចូលរួមពីភ្ញៀវ គ្រួសារ សាច់ញាតិ និងមិត្តភក្តិពីភាគីទាំងពីរ។ ការរៀបការនារបប ខ្មែរក្រហមគឺខុសគ្នាទាំងស្រុង។ ពិធីរៀបការមុនរបបខ្មែរក្រហមគឺស្រដៀងគ្នានឹងពិធីរៀបការនាពេលបច្ចុប្បន្ននេះ។

**មីង តើមីងគិតម៉េចដែរ? តើពិធីរៀបការមានអត្ថន័យដូចម្តេចដែរសំរាប់ស្ត្រី?**

អត្ថន័យនៃការរៀបការគឺស្រពិចស្រពិល។ ពិធីរៀបការគឺមានតំលៃសំរាប់មនុស្សស្រី ពីព្រោះថា មនុស្សគ្រប់គ្នាទទួលស្គាល់ស្ត្រីដែលបានរៀបការជាកូនស្រីល្អដែលស្តាប់បង្គាប់។ ស្ត្រីបានតុបតែងស្រស់ស្អាត និងទទួលភ្ញៀវច្រើននាក់។ ការរៀបការគឺសំខាន់ណាស់សំរាប់ស្ត្រីខ្មែរគ្រប់រូប។ ប្រសិនបើយើងស្រលាញ់គ្នាដោយគ្មានការទទួលស្គាល់ ពីឪពុកម្តាយឬសាច់ញាតិហើយយើងរត់ចេញរត់តាមគ្នាវាមិនល្អទេក្នុងវប្បធម៌យើង។ តាមប្រពៃណីខ្មែរ កូនត្រូវតែគោរពឪពុកម្តាយហើយការរៀបការ មិនអាច កើតមានបានទេលុះត្រាតែឪពុកម្តាយទទួលព្រមនិងរៀបចំឱ្យពួកគេ។ ប្រសិនបើប្តីប្រពន្ធមិនគោរពតាមឪពុកម្តាយ ហើយសំរេចចិត្តតែខ្លួនឯង ក្នុងការរៀបការដោយមិនមានការព្រមព្រៀងពីឪពុកម្តាយ ពួកគេមិនមែនជាកូនល្អទេ។

១០ ការព្យាបាលតាមបែបសក្ខីកម្មរបស់អង្គការចិត្តសង្គម អន្តរវប្បធម៌កម្ពុជា បានផ្តល់នូវការគាំទ្រផ្លូវចិត្ត ដល់ជនរងគ្រោះដើម្បីកត់ត្រាបទពិសោធន៍របស់ពួកគេក្នុងរបបខ្មែរក្រហម និងចែករំលែកជា សាធារណៈក្នុងផ្នែកមួយនៃពិធីបែបសាសនា

ប្តីៈ សំរាប់បុរសវាដូចគ្នាដែរ ពីព្រោះបុរសទាំងអស់ត្រូវតែគោរព និងធ្វើតាមការព្រមព្រៀងរបស់ឪពុកម្តាយ។ ប្រសិនបើបុរសនោះចង់រៀបការជាមួយស្ត្រីនោះ ហើយឪពុកម្តាយរបស់គាត់មិនពេញចិត្ត ហើយគាត់នៅតែចង់រៀបការជាមួយស្ត្រីនោះ គ្រួសារនឹងមិនសប្បាយចិត្តទេ។

ប្រពន្ធៈ ក្នុងករណីនេះប្រសិនបើស្ត្រីនេះជាកូនស្រីល្អ ឪពុកម្តាយនឹងមិនធ្វើអ្វីនោះទេ [បន្ទាប់ពីពេលវេលាកន្លងទៅ]។ ប្រសិនបើស្ត្រីនេះជាស្ត្រីមិនល្អបញ្ហាជាមួយនឹងឪពុកម្តាយនឹងធ្ងន់ធ្ងរ។



## តើការរៀបការត្រូវពឹងផ្អែកទាំងស្រុងទៅលើបំណងប្រាថ្នារបស់ឪពុកម្តាយទាំងអស់ឬ?

ប្តីៈ មិនទាំងស្រុងទេ ពិធីរៀបការមិនអាចកើតមាននោះទេ លុះត្រាតែមានការយល់ព្រមរវាងកូន និងឪពុកម្តាយ។

ប្រពន្ធៈ ចាស ការយល់ព្រមពីកូន [ក្នុងការរៀបការ] គឺសំខាន់ណាស់។ ឧទាហរណ៍៖ ប្រសិនបើឪពុកម្តាយបង្ខំក្មួយឯងឱ្យរៀបការជាមួយបុរសដែលក្មួយមិនស្រឡាញ់ តើក្មួយឯងធ្វើដូចម្តេច? ប្រសិនបើយើងរៀបការដោយគ្មានការស្រឡាញ់ យើងនឹងមិនមានសុភមង្គលក្នុងជីវិតរបស់យើងទេទោះបីជាបុរសនោះមានប្រាក់ច្រើនក៏ដោយ។ ក្នុងរបបខ្មែរ-ក្រហមមេដឹកនាំមិនបានសួរនាំយើងពីការព្រមព្រៀងនោះទេ។ តាមអ្វីដែលខ្ញុំដឹងគេសំលាប់មនុស្សច្រើនណាស់ ហើយដូច្នេះគេបង្ខំមនុស្សឱ្យរៀបការ ដោយគ្មានលក្ខខណ្ឌដើម្បីបង្កើតគ្រួសារថ្មី។

## តើពូរំពឹងថានឹងរៀបការមុនពេលខ្មែរក្រហមចូលកាន់កាប់អំណាចដែរឬទេ?

ប្តីៈ ខ្ញុំមិនដែលគិតអំពីការរៀបការនោះទេ។ មុនឆ្នាំ១៩៧៥ ខ្ញុំនៅកំពុងសិក្សាហើយខ្ញុំ គិតតែពីការរៀនសូត្រនិងជួយឪពុកម្តាយ។ ខ្ញុំមិនបានគិតថាខ្ញុំពេញវ័យគ្រប់គ្រាន់នឹងរៀបការនោះទេ។

ប្រពន្ធៈ ខ្ញុំមិនដែលគិតអំពីការរៀបការនោះទេ ពីព្រោះខ្ញុំរស់នៅជាមួយ

ឪពុកម្តាយខ្ញុំនាពេលនោះ។ ខ្ញុំទើបតែមានអាយុប្រហែលជា១៥ឆ្នាំ ហើយមិនទាន់គ្រប់ការ [មានរដូវ] នៅឡើយទេ។

> “ជីវិតរបស់ស្ត្រី ត្រូវផ្លាស់ប្តូរទាំងស្រុងពេលរៀបការរួចដូចជា “ខ្មោចប្តូរកាយ”។

**តើការរៀបការមានអត្ថន័យដូចម្តេចដែរសំរាប់បុរស ឭ?**

ប្តី: វាអាស្រ័យទៅលើបុរស។ បុរសខ្លះ គិតថាគេមិនទាន់ចង់រៀបការ ពីព្រោះពេលគេមានកូនគេខ្លាចបាត់បង់សេរីភាព និងមិនអាចទៅណាមកណាបាន [ចេញដើរលេង និងផឹកស៊ី] ជាមួយមិត្តភក្តិ។ ផ្ទុយទៅវិញ សំរាប់បុរសខ្លះគេចង់រៀបការពីព្រោះគេខ្លាចនៅម្នាក់ឯងពេលគេចាស់ទៅ។

ប្រពន្ធ: សំរាប់ខ្ញុំ ខ្ញុំគិតថាភាពនៅលីវនិងរស់នៅជាមួយម្តាយគឺងាយស្រួលជាងមានប្តី។ បន្ទាប់ពីខ្ញុំមានប្តីខ្ញុំគិតថាជីវិតគឺពិបាក។

ប្រពន្ធ: ខ្ញុំត្រូវតែមើលថែរក្សាកូន ហើយខ្ញុំត្រូវតែថែរក្សាលុយកាក់សំរាប់ផ្គត់ផ្គង់គ្រួសារ និងរៀបចំគំរោងសំរាប់អនាគតរបស់កូន។ ជីវិតរបស់ស្ត្រីត្រូវផ្លាស់ប្តូរទាំងស្រុងពេលរៀបការរួចដូចជា “ខ្មោចប្តូរកាយ”។ យើងមិនអាចចេញដើរដោយសេរីបានយើងត្រូវតែប្រាប់ប្តីពេលទៅណាមកណា។ ប្រសិនបើយើងមិនគោរពគ្នាទៅវិញទៅមកយើងនឹងងាយបែកបាក់គ្នា។ យើងមិនអាចពាក់សំលៀកបំពាក់តាមដែលយើងចង់ ហើយយើងត្រូវតែប្រាប់ប្តីពេលយើងចំណាយលុយកាក់ផ្សេងៗ។ បុរសខ្លះគេមិនចូលចិត្តអោយប្រពន្ធរបស់គេស្លៀកពាក់សំលៀកបំពាក់សិចស៊ី ហើយបុរសខ្លះចង់អោយប្រពន្ធរបស់គេពាក់សំលៀកបំពាក់ខ្លី និងសិចស៊ី។ ដូច្នេះស្ត្រីត្រូវគិតពីការចង់បានរបស់ប្តី... ប្រសិនបើស្ត្រីនោបាន ប្តីល្អ—គាត់មិនលេងល្បែង មិនមានប្រពន្ធផ្សេង មិនផឹកនិងមិនចេញក្រៅពេលយប់—ស្ត្រីនេះជាស្រីសំណាង។ ប្រសិនបើស្ត្រីនោះបានប្តីមិនល្អវានឹងនាំមកនូវការសោកស្តាយយ៉ាងខ្លាំង។ ទំនួលខុសត្រូវសំរាប់ស្ត្រី អាស្រ័យលើប្តី។ ដំបូងនាងមិនដឹងថាតើបុរសនោះជាបុរសប្រភេទណានោះទេ។ យើងអាចដឹងពីគាត់បានតាមរយៈការរស់នៅជាមួយគ្នាមួយរយៈ។

ប្តី: ដូចគ្នា. . . បុរសក៏បារម្ភពីជីវិតរៀបការរបស់គេដែរ ពីព្រោះស្ត្រីខ្លះចូលចិត្តចេញដើរខាងក្រៅនិងតុបតែងមុខ។ ស្ត្រីខ្លះមានទំនួលខុសត្រូវចំពោះស្វាមីនិងកូនៗរបស់ខ្លួន ហើយគេព្យាយាមសន្សំលុយកាក់ និងថែរក្សាអ្វីៗគ្រប់ទាំងអស់ និងមនុស្សគ្រប់គ្នាក្នុងគ្រួសារ។

ប្រពន្ធ: ខ្ញុំគិតថាស្ត្រីភាគច្រើនគឺជាអ្នករងគ្រោះ [នៃការរៀបការ] ពីព្រោះស្ត្រីមានផ្ទៃពោះ ហើយបុរសមិនមានផ្ទៃពោះទេបន្ទាប់ពីការរួច។ ហើយបុរសអាចមានស្រីផ្សេង នេះជាហេតុផលដែលពិបាកសំរាប់ស្ត្រី។ រវាងជីវិតនៅលីវនិងជីវិតរៀបការ ខ្ញុំគិតថាមើលថែរក្សាឪពុកម្តាយវាងាយស្រួលជាង [ក្នុងជីវិតនៅលីវ]។ ប៉ុន្តែខ្ញុំគិតថាខ្ញុំមិនអាចរស់នៅម្នាក់ឯងរហូតបានទេ ពីព្រោះបងប្អូនរបស់ខ្ញុំមានគ្រួសាររបស់គេ ហើយឪពុកម្តាយខ្ញុំ មិនអាចរស់នៅជាមួយខ្ញុំរហូតបាននោះទេ។ ខ្ញុំមិនមានអ្នកមើលថែរក្សាពេលខ្ញុំឈឺ។ ដូច្នេះខ្ញុំត្រូវតែរៀបការដើម្បីមានអ្នកនៅជាមួយខ្ញុំទោះបីជាវាពិបាកពេលខ្លះ។

**ឥឡូវនេះ ខ្ញុំចង់សួរទាក់ទងទៅនឹងពិធីរៀបការដោយបង្ខំក្នុងរបបខ្មែរក្រហម។ នៅពេលណាដែលពូនិងមីងត្រូវបានគេប្រាប់អំពីការបង្ខំអោយរៀបការ?**

ប្តី: យើងត្រូវបានគេប្រាប់អំពីការបង្ខំរៀបការប្រហែលជាមួយសប្តាហ៍មុន។ យើងត្រូវបានគេប្រាប់ឱ្យរៀបការនៅថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៧៨។

**តើអ្នកណាជាអ្នកប្រាប់?**

ប្រពន្ធ: កម្មាភិបាលពីរនាក់។ ពួកគេជាប្តីប្រពន្ធ [រៀបការ] បុរសម្នាក់និង ស្ត្រីម្នាក់។ កម្មាភិបាលក៏ធ្វើតាមគោលការណ៍ខ្មែរក្រហម ហើយពួកគេ គ្រាន់តែជាអ្នកផ្តល់ដំណឹងដល់ប្រជាជនដែលនៅក្នុងភូមិ [អំពីអ្នកដែល នឹងត្រូវរៀបការ]។ ខ្ញុំជាផ្នែកមួយនៅក្នុងក្រុមស្ត្រីនៅលីវ ហើយកម្មាភិបាល បានបញ្ជាឱ្យមេក្រុមស្ត្រីប្រាប់ខ្ញុំថាខ្ញុំនឹងត្រូវរៀបការក្នុងថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៧៨។ ខ្ញុំឆ្លើយតបថា "តើខ្ញុំរៀបការនៅទីណាហើយ ហេតុអ្វីបានជាខ្ញុំត្រូវរៀបការ?" ខ្ញុំត្រូវបានគេប្រាប់នៅពេលយប់

ពីព្រោះមិនមានពេលប្រាប់នាពេលថ្ងៃទេ ហើយខ្ញុំត្រូវបានគេប្រាប់ពេលកំពុងប្រជុំ។ មានកម្មាភិបាលប្រាប់ថាអ្នកត្រូវរៀបការ។ គេបានប្រកាសថា " មិត្ត ក. មិត្តឯងត្រូវរៀបការនៅថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៧៨ ពេលយប់" ហើយគេបានប្រាប់ទៀតថា មាន៥ទៅ៦គូនឹងត្រូវរៀបការនាពេលនោះដែរ។ ខ្ញុំមានអារម្មណ៍សោកស្តាយ ហើយប្រសិនបើខ្ញុំអាចរត់ទៅឆ្ងាយបាន ខ្ញុំនឹងរត់។

> *យើងមិនបានដឹងថា នឹងត្រូវធ្វើអ្វីបន្ទាប់នោះទេ ហើយយើងចង់រត់ចេញប៉ុន្តែយើងខ្លាចគេសំលាប់។ ដូច្នេះយើងមានតែទទួលយកការបង្ខំរៀបការនោះ។*

**មីងចង់រត់គេចទៅឆ្ងាយ។ តើអ្វីដែលធ្វើឱ្យមីងមិនសប្បាយចិត្ត?**

ប្រពន្ធ: ខ្ញុំនឹងរៀបការហើយរស់នៅជាមួយបុរសម្នាក់។ ខ្ញុំមិនបានចង់រៀបការទេ ពីព្រោះឪពុកម្តាយខ្ញុំមិននៅក្បែរខ្ញុំ ខ្ញុំមិនមានខោអាវថ្មីៗ មិនមានសាច់ញាតិចូលរួមមង្គលការ ហើយគ្មានអ្វីពិសេសសំរាប់ខ្ញុំទេ។ យើងត្រូវបានគេណែនាំឱ្យគ្នាទៅវិញទៅមក ហើយបន្ទាប់មកយើងត្រូវតែរស់ នៅជាមួយគ្នា។ ពេលខ្ញុំដឹងថាខ្ញុំត្រូវរៀបការ ខ្ញុំបដិសេធថាខ្ញុំមិនចង់រៀបការទេ ហើយគេបាននិយាយថាខ្ញុំត្រូវតែរៀបការ។ ខ្ញុំពិតជាស្តាយណាស់ ហើយខ្ញុំគ្រាន់តែយល់ព្រមតាមអ្វីដែលគេបង្ខំដើម្បីសង្គ្រោះជីវិតពីព្រោះខ្ញុំមិនអាចរត់ចេញពីរបបនោះបានទេ។ អ្នកផ្សេងក៏បានបដិសេធដែរ ប៉ុន្តែគេនៅតែរៀបការពីព្រោះគេមិនមានជំរើស។ យើងមានការពិភាក្សាគ្នាស្ងាត់ៗនៅក្នុងក្រុមស្ត្រីពីការបង្ខំឱ្យរៀបការ។ យើងមិនបានដឹងថា នឹងត្រូវធ្វើអ្វីបន្ទាប់នោះទេ ហើយយើងចង់រត់ចេញប៉ុន្តែយើងខ្លាចគេសំលាប់។ ដូច្នេះយើងមានតែទទួលយកការបង្ខំរៀបការនោះ។

**ពូ តើពេលណាពូត្រូវបានគេប្រាប់អំពីការបង្ខំឱ្យរៀបការ?**

ប្តី: ខ្ញុំត្រូវបានប្រាប់ដោយមេក្រុមប្រុសម្នាក់។ គាត់ប្រាប់ខ្ញុំថា "មិត្ត មិត្តឯងត្រូវរៀបការ នៅថ្ងៃ២០ ខែសីហា ឆ្នាំ ១៩៧៨"។ ខ្ញុំត្រូវបានគេប្រាប់នៅពេលថ្ងៃពេលខ្ញុំសំរាកការងារ ហើយបន្ទាប់មកខ្ញុំត្រូវបានគេហៅឈ្មោះ

ឱ្យត្រៀមខ្លួនរៀបការនៅថ្ងៃទី២០ សីហា ឆ្នាំ១៩៧៨។ គេបានប្រាប់ខ្ញុំថា "មានមិត្តនារីរួចហើយ ហើយមិត្តត្រូវតែរៀបការនៅថ្ងៃ២០ សីហា។" គេបានប្រាប់ខ្ញុំពីឈ្មោះកូនក្រមុំខ្ញុំដែរ។ ខ្ញុំមានអារម្មណ៍មិនសប្បាយចិត្តទេពីព្រោះកម្មាភិបាលចាត់ទុកការរៀបការដូចជាល្បែងលេង។ ខ្ញុំបានប្រាប់ឳពុកម្ដាយរបស់ខ្ញុំដឹងអំពីការរៀបការនេះ ហើយគេបានសួរខ្ញុំថា "តើនារីម្នាក់នោះរស់នៅឯណា?"។ ខ្ញុំបានប្រាប់គេថា ខ្ញុំគ្រាន់តែដឹងថានាងរស់នៅភូមិ xx ចំងាយពីផ្ទះឳពុកម្ដាយខ្ញុំប្រហែលជា៨គីឡូម៉ែត្រ។ ខ្ញុំប្រាប់គេថាខ្ញុំមិនបានស្គាល់នាងច្បាស់ទេ បានស្គាល់នាងពេលនាងធ្វើការក្បែរគ្នា។ ខ្ញុំមិនដែលបាននិយាយជាមួយនាងទេ។ នារបបនោះយើងស្គមណាស់មើលដូចមនុស្សចាស់។

**តើមានអ្វីកើតឡើងនៅថ្ងៃទី២០ សីហា ១៩៧៨?**

ប្ដី: យើងរៀបការនៅម៉ោង៧យប់។

**តើមីងស្លៀកពាក់អ្វីដែរ?**

ប្រពន្ធ: យើងស្លៀកពាក់ខោអាវខ្មៅ។[១១]

**តើខោអាវថ្មីឬចាស់?**

ប្រពន្ធ: ខោអាវចាស់។

ប្ដី: យើងមិនមានខោអាវថ្មីៗនោះទេនាពេលនោះ។

ប្រពន្ធ: យើងបានហូបបបររួច ហើយពិធីបានចាប់ផ្ដើមនាម៉ោង៧យប់។

**តើមានប្ដីប្រពន្ធប៉ុន្មានគូដែរដែលនៅជាមួយពូមីងពេលនោះ?**

ប្ដី: មាន៦គូ។ កម្មាភិបាលបានហៅឈ្មោះមនុស្សពីរនាក់ដែលនឹងរៀបការ។ បន្ទាប់ពី ហៅឈ្មោះរួច ប្ដីប្រពន្ធបានអង្គុយទល់មុខគ្នា។ ពួកអ្នកដែលមិនបានស្គាល់គ្នាពួកគេបានប្រឡំអ្នកដែលនឹងរៀបការជាមួយគេពីព្រោះពិធីរៀបការគឺធ្វើឡើងច្រើនគូណាស់។

ប្រពន្ធ: ប្ដីប្រពន្ធគូក្រោយៗមិនបានស្គាល់គ្នាទេ គេមានការប្រឡំបល់គ្នា

ហើយគេត្រូវបានគេបង្ខំ "ដូចឆ្កែដូចឆ្មា"។

**ដូច្នេះ គេមិនបានស្គាល់គ្នាសូម្បីតែឈ្មោះ។**

ប្តី: មិនស្គាល់សូម្បីតែឈ្មោះ។

**តើមានអ្នកណាផ្សេងទៀតនៅក្នុងពិធីនោះក្រៅពីគូប្តីប្រពន្ធដែរឬទេ?**

ប្តី: មានកម្មាភិបាល និងមេកងខ្មែរក្រហម។

ប្រពន្ធ: មានកូន [សមាជិកខ្មែរក្រហម] ពីព្រោះគេបានរៀបការដែរ។ ពេលយើងរៀបការនោះ យើងរៀបការ "ដូចគោ"។

ប្តី: ប្រសិនបើយើងប្រកែក យើងនឹងត្រូវបានគេបញ្ជូនទៅភ្នំ។ មានកម្មាភិបាលខ្លះមិនព្រមរៀបការ ពួកគេត្រូវបានគេបញ្ជូនទៅធ្វើការនៅភ្នំ xx ។ ខ្ញុំទទួលយកការបង្ខំអោយរៀបការនេះដើម្បីឱ្យបាននៅក្នុងភូមិ ហើយបានរស់ជីវិត។

ប្រពន្ធ: យើងបានរៀបការពីព្រោះយើងចង់រស់នៅក្នុងភូមិមិនមែនព្រោះតែស្រឡាញ់គ្នានោះទេ។

**តើឪពុកម្តាយរបស់មីងចូលរួមចំណែកក្នុងពិធីការនោះដែរឬទេ?**

ប្រពន្ធ: ទេ។ យើងជាកូនអង្គការ។ដូច្នេះអង្គការអាចរៀបចំពិធីនេះដោយមិនចាំបាច់មានឪពុកម្តាយទេ។

**តើមីងពូមាននិយាយពាក្យសច្ចាដែរឬទេ?**

ប្តី: បាទ យើងបានប្តេជ្ញាថា "យើងនឹងទទួលយកមិត្តនារី ហើយនឹងរស់នៅជាមួយគ្នាអស់មួយជីវិត។" វាត្រជាក់ណាស់ ហើយមានភ្លៀងទៀតនាពេលនោះ។

**តើពូមានអារម្មណ៍បែបណាដែរពេលនោះ?**

ប្តី: ខ្ញុំមានអារម្មណ៍មិនសប្បាយចិត្តពីព្រោះខ្ញុំត្រូវបានគេបង្ខំឱ្យរៀបការ។ យើងមិនបានស្គាល់គ្នា ហើយមិនបានស្រឡាញ់គ្នា។ ប្រពៃណីបានដើរតួនាទីសំខាន់ដែរពីព្រោះ ឪពុកម្តាយរបស់យើងមិនបានចូលរួម

១១ ក្នុងរបបខ្មែរក្រហម សំលៀកបំពាក់គឺត្រូវអោយស្លៀកពណ៌ខ្មៅ

ទទួលស្គាល់ការរៀបការជាមួយយើង។

ប្រពន្ធៈ ចាស ហេតុផលទាំងពីរនេះហើយដែលខ្ញុំមិនសប្បាយចិត្ត។ ខ្ញុំអាណិតខ្លួនឯង ហើយចិត្តរបស់ខ្ញុំច្របូកច្របល់ ហើយខ្ញុំមិនដឹងថាត្រូវធ្វើបែបណានោះទេ។

ប្ដីៈ យើងមិនអាចយំបាន ទោះបីជាយើងចង់យំ។[១២]

ប្រពន្ធៈ ហើយយើងមិនអាចរត់បានទេ។ និយាយឱ្យត្រង់ទៅ ប្រសិនបើប្ដីរបស់ខ្ញុំបង្ខំខ្ញុំ [បន្ទាប់ពីពិធីប្ដេជ្ញារួច] ខ្ញុំនឹងសំលាប់ខ្លួនហើយ។ ខ្ញុំមិនដែលស្រឡាញ់បុរសណាពីមុនមកទេ ហើយខ្ញុំមិនដែលស្រម៉ៃនឹងចង់មានទំនាក់ទំនងផ្លូវភេទជាមួយបុរសណាទេ។ តែតាមពិតទៅគាត់មិនបានបង្ខំខ្ញុំទេ។

**តើយប់ដំបូងនៃការរៀបការនោះយ៉ាងណាដែរ?**

ប្ដីៈ យើងបានទៅផ្ទះ ហើយដេកនៅទីនោះ។ ផ្ទះនោះប្រហែលជា ៣x៤ម៉ែត្រ។

ប្រពន្ធៈ ផ្ទះតូចៗត្រូវបានកសាងឡើងជាជួរនៅជាប់ៗគ្នាសំរាប់ប្ដីប្រពន្ធរៀបការរួច។

ប្ដីៈ យើងមិនបាននិយាយគ្នាច្រើនហើយឮៗទេ។ ផ្ទះនោះធ្វើពីឫស្សីនិងស្បូវ។ ផ្ទះនោះតូច ហើយមានជណ្ដើរបីកាំហើយនៅខាងក្នុងមិនមានគ្រែនិងកន្ទេលទេ។[១៣]

ប្រពន្ធៈ យើងយកកន្ទេល និងមុងពីផ្ទះចាស់យើងទៅ។

ប្ដីៈ យើងបាននៅជាមួយគ្នានៅផ្ទះតែមួយ ប៉ុន្តែយើងគេងក្នុងមុងខុសគ្នា។ វាងងឹតខ្លាំងណាស់ ហើយយើងគ្រាន់តែស្ងាត់ស្ងៀម។

**តើពួមីងបាននិយាយគ្នាមុន អំពីការគេងក្នុងមុងខុសគ្នាដែរឬទេ?**

ប្រពន្ធៈ យើងមិនបាននិយាយគ្នាមុនទេ។

ប្ដីៈ យើងខ្លាចគ្នាទៅវិញទៅមក។

**តើពួមីងបាននិយាយគ្នានាយប់ពេលរៀបការដែរឬទេ?**

ប្រពន្ធ: យើងមិនមានពាក្យច្រើននិយាយគ្នានោះទេ។

**តើពួមីងបាននិយាយតាមផ្លូវទៅផ្ទះដែរឬទេ?**

ប្តី: ទេ។ យើងគ្រាន់ដើរទៅផ្ទះ លាងជើង និងដៃហើយគេង។

**តើមីងមានអារម្មណ៍បែបណាដែរពេលយប់នោះ?**

ប្រពន្ធ: ដំបូង ខ្ញុំខ្លាចថាមានកម្មាភិបាលដឹងថាយើងមិនរួមដំណេកនឹងគ្នា។[១៤] ទីពីរ ខ្ញុំខ្លាចប្តីរបស់ខ្ញុំបង្ខំខ្ញុំអោយរួមភេទ។

ប្តី: ខ្ញុំមិនហ៊ានគេងនៅក្បែរប្រពន្ធខ្ញុំទេព្រោះខ្ញុំមិនដែលស្គាល់នាង ហើយ មិនដែលនិយាយគ្នាពីមុនមកទេ។ ខ្ញុំក៏ខ្លាចដែរពីព្រោះខ្ញុំមិនដែលស្រឡាញ់នរណាម្នាក់ពីមុនមក។

ប្រពន្ធ: ប្តីរបស់ខ្ញុំបានប្រាប់ខ្ញុំថា "មិត្តឯងគួរដេកទៅហើយកុំអោយមានសំលេងអី។ ប្រសិនបើមានកម្មាភិបាលគិតថាយើងមិនចុះសំរុងគ្នា យើងនឹងត្រូវគេសំលាប់"។ ឈ្លបតែងតែលបស្តាប់យើងស្ទើរតែរាល់យប់។ ថ្ងៃមួយមេក្រុមឈ្មោះ xx បានសង្ស័យខ្ញុំថា ខ្ញុំមិនបានរួមភេទជាមួយប្តី។ ខ្ញុំឆ្លើយថា "តើមិត្តបងនិយាយពីអ្វីហ្នឹង?" មេក្រុមគាត់អាចដឹងថាខ្ញុំមិនបានរួមភេទដោយគ្រាន់តែសង្កេតរូបរាងរបស់ខ្ញុំ។ ពេលខ្ញុំប្រកែកការសង្ស័យរបស់គាត់ ហើយគាត់ក៏សើចដាក់ខ្ញុំ។

ប្តី: មេក្រុមក៏សួរខ្ញុំដែរ ហើយគាត់បានសួរថា "តើទំនាក់ទំនងប្តីប្រពន្ធរបស់មិត្តឯង យ៉ាងម៉េចហើយ?" ខ្ញុំឆ្លើយថា "វាល្អទេ"។

**តើរយៈពេលយូរប៉ុណ្ណាដែលពូមីងរស់នៅក្នុងផ្ទះឬស្សីស្បូវនោះ?**

ប្តី: យើងនៅជុំគ្នាប្រហែលជាមួយសប្តាហ៍។ បន្ទាប់ពីមួយសប្តាហ៍ក្រោយមក ខ្ញុំរស់នៅក្នុងផ្ទះ ហើយធ្វើការក្បែរផ្ទះ ហើយប្រពន្ធរបស់ខ្ញុំធ្វើការនៅ xx ហើយដេកនៅទីនោះ។ មានកម្មាភិបាលអនុញ្ញាតឱ្យគូថ្មីជួបគ្នាមួយខែម្តង។

ប្រពន្ធ: ខ្ញុំឆ្ងល់ថាហេតុអ្វីបានជាគេបង្ខំយើងឱ្យរៀបការ ហើយ

១២
ជាញឹកញាប់ វាត្រូវបាននិយាយថា ការបង្ហាញនូវចិត្តរំភើប (ការស្រឡាញ់ ទុក្ខព្រួយ កំហឹង) ត្រូវបានហាមឃាត់ក្នុងរបបខ្មែរក្រហមថាជាសញ្ញាមួយនៃការមិនយល់ស្របជាមួយនឹងគោលការណ៍របស់ អង្គការ

១៣
ផ្ទះប្រពៃណីរបស់ខ្មែរត្រូវបានទប់ដោយសសរដើម្បីការពារទឹកជំនន់ និងសត្វផ្សេងៗកុំអោយចូលផ្ទះ

១៤
មានទំនាក់ទំនងផ្លូវភេទ។ សូមមើលផងដែរទៅលើករណីសិក្សា ១ [Ed.]

បន្ទាប់មកបំបែកយើង។ ក្នុងរបបនោះ គេសំលាប់មនុស្សច្រើនណាស់ គេបានរៀបចំការបង្ខំឱ្យរៀបការ ហើយបន្ទាប់មកគេបំបែកប្តីប្រពន្ធថ្មីថ្មោង។

ប្តី: ខ្ញុំត្រូវធ្វើការនៅក្បែរភូមិ។ ខ្ញុំជាអ្នកនេសាទត្រីហើយយកត្រីទៅផ្ទះបាយ [សមូហភាព] ក្នុងភូមិ។

ប្រពន្ធ: ខ្ញុំជាអ្នកធ្វើការឆ្ងាយពីផ្ទះ។ ខ្ញុំកាប់ឈើ ខ្ញុំស្ទូងស្រូវ និងច្រូតស្រូវ។ ខ្ញុំអាចទៅផ្ទះមួយខែម្តង។ ខ្ញុំមិនចង់ទៅទេពីព្រោះខ្ញុំមិនស្រឡាញ់ប្តីខ្ញុំ ហើយផ្ទុយទៅវិញខ្ញុំបានទៅផ្ទះម្តាយខ្ញុំ។ ខ្ញុំកម្រទៅជួបប្តីខ្ញុំណាស់។ ខ្ញុំប្រាប់គេឯងថាខ្ញុំមិនអាចទៅផ្ទះញឹកញាប់នោះទេពីព្រោះខ្ញុំធ្វើការច្រើនណាស់ ហើយខ្ញុំនៅឆ្ងាយប្រហែលជា១០គីឡូម៉ែត្រ។ ខ្ញុំបានឈប់តែមួយថ្ងៃពីការងារហើយខ្ញុំបានធ្វើការហត់ណាស់ ខ្ញុំមិនអាចមានថាមពលគ្រប់គ្រាន់ក្នុងការដើរផ្លូវឆ្ងាយ។ ប៉ុន្តែតាមពិតទៅខ្ញុំមិនដែលនឹកឬគិតពីប្តីនោះទេ [ពេលយើងបែកគ្នា]។

**ពេលត្រូវបានគេបំបែកចេញបន្ទាប់ពីរៀបការរួចបានមួយសប្តាហ៍ តើពូមានអារម្មណ៍បែបណា?**

ប្តី: ខ្ញុំមានអារម្មណ៍ធម្មតា ហើយខ្ញុំមិនបាននឹកនាងទេ។

ប្រពន្ធ: ខ្ញុំមិនបានខ្វល់ថាតើខ្ញុំទៅឆ្ងាយប៉ុណ្ណាពីប្តីខ្ញុំនោះទេ។

**តើពូមានការសប្បាយចិត្តពេលបានបែកគ្នាឬ?**

ប្តី: ខ្ញុំមិនបានគិតពីការសប្បាយចិត្តឬអត់នោះទេ។ បញ្ហាសំខាន់គឺខ្ញុំបានគិតថាខ្ញុំអាចនៅរស់បាន។ ខ្ញុំមិនបានគិតពីអ្វីដែលបានកើតឡើងនាពេលអនាគតនោះទេ។

**តើពេលណាដែលអ្នកទាំងពីររួមភេទដំបូង?**

ប្តី: យើងរួមដំណេកជាមួយគ្នាពេលរបបខ្មែរក្រហមបានបញ្ចប់ក្នុងដើមឆ្នាំ១៩៧៩។

**ខ្ញុំចង់បញ្ជាក់ថាអ្នកទាំងពីរមិនបានរួមដំណេកជាមួយគ្នាតាំងពីរៀបការរួចដល់ឆ្នាំ១៩៧៩?**

ប្ដី: ត្រឹមត្រូវហើយ យើងបានលាក់ពីទំនាក់ទំនងរបស់យើង។

ប្រពន្ធ: នាពេលនោះ ប្ដីរបស់ខ្ញុំបានលួចរបស់និងលាក់របស់ទុកឱ្យខ្ញុំហូប។ គាត់លួចត្រីសំរាប់ឱ្យខ្ញុំហូប។

**បន្ទាប់ពីរបបខ្មែរក្រហម តើហេតុអ្វីបានជាពូមីងសំរេចរស់នៅជាមួយគ្នាជាប្ដីប្រពន្ធ?**

ប្ដី: ពេលយើងជំលៀសក្នុងឆ្នាំ១៩៧៩ បន្ទាប់ពីវៀតណាមបានរំដោះប្រទេសយើង មនុស្សគ្រប់គ្នារត់ទៅរស់នៅជាមួយគ្រួសារវិញហើយគេឈប់រស់នៅជាក្រុមដូចពីមុន។ ខ្ញុំរស់នៅជាមួយម្ដាយរបស់ខ្ញុំ ហើយប្រពន្ធរបស់ខ្ញុំទៅរស់នៅជាមួយម្ដាយនាង។

**ដូច្នេះពូនិងមីងមិនបាននៅជាមួយគ្នាទេដំបូង?**

ប្រពន្ធ: ទេ ខ្ញុំរស់នៅជាមួយម្ដាយរបស់ខ្ញុំ។

ប្ដី: ខ្ញុំរស់នៅជាមួយម្ដាយរបស់ខ្ញុំ។

ប្ដី: ថ្ងៃមួយ មានមនុស្សម្នាក់បានប្រាប់ខ្ញុំពីកន្លែងដែលប្រពន្ធរបស់ខ្ញុំនៅ យុវជនដែលរស់នៅភូមិជាមួយគ្នា។ ខ្ញុំក៏សួរគេឯងថាបានដឹងដំណឹងពីប្រពន្ធរបស់ខ្ញុំ ហើយយុវជនម្នាក់បាននិយាយថា នាងរស់នៅជាមួយម្ដាយ របស់នាងនៅភូមិមួយឆ្ងាយ។ ម្ដាយរបស់ខ្ញុំមិនចង់ឱ្យខ្ញុំចោលប្រពន្ធខ្ញុំ ហើយគាត់មានរទេះគោ។ ដូច្នេះគាត់ប្រាប់អោយខ្ញុំអោយទៅយកប្រពន្ធ ខ្ញុំអោយមករស់នៅជុំគ្នាពីព្រោះគាត់មិនចង់ឱ្យប្រពន្ធខ្ញុំរស់នៅតែជាមួយម្ដាយនាងទេ។ ដូច្នេះខ្ញុំក៏ទៅយកនាងមកឱ្យម្ដាយរបស់ខ្ញុំ។

ប្រពន្ធ: នាពេលនោះខ្ញុំមិនមានរទេះគោទេ ម្ដាយខ្ញុំឈឺទៀតហើយយើងមានរបស់របរខ្លះដូចជាអង្ករ ចាន និងឆ្នាំង ហើយខ្ញុំត្រូវស្ពាយវាធ្វើដំនើរតាមផ្លូវ។

ប្ដី: ខ្ញុំទៅយកនាងនៅម៉ោង១២ថ្ងៃត្រង់។

ប្រពន្ធ: ថ្ងៃនោះប្អូនប្រុសខ្ញុំនិយាយមកខ្ញុំថា "តើអ្នកណាជិះរទេះគោមកនោះ?" ខ្ញុំក៏បែរខ្នងទៅមើល ហើយខ្ញុំបារម្ភថាហេតុអ្វីបានជាប្តីរបស់ខ្ញុំជិះរទេះគោមកទីនេះធ្វើអ្វី។ ខ្ញុំរៀបចំបន្តដំណើរទៅទៀតជាមួយម្តាយ ហើយខ្ញុំមិនខ្វល់ថាតើគាត់ទៅណាជាមួយនឹងគ្រួសាររបស់គាត់នោះទេ។

**តើមីងមានគំរោងនឹងជួបជាមួយប្តីរបស់មីងទេ?**

ប្រពន្ធ: ទេ។

**តើហេតុអ្វីដែរបានជាពូរកប្រពន្ធរបស់ពូ?**

ប្តី: ពីព្រោះម្តាយរបស់ខ្ញុំបានប្រាប់អោយខ្ញុំទៅយកនាងឱ្យមករស់នៅជាមួយយើង។

ប្រពន្ធ: ពេលខ្ញុំជួបគាត់ គាត់និយាយថា "ម្តាយរបស់ខ្ញុំបានឱ្យខ្ញុំមកយកអ្នក និងម្តាយ ហើយយើងគួរតែទៅជាមួយគ្នាពីព្រោះយើងអាចថែរក្សាគ្នាទៅវិញទៅមក។" ខ្ញុំបានគិតថាខ្ញុំមិនមានមធ្យោបាយធ្វើដំណើរ ខ្ញុំខ្លាចថាខ្ញុំមិនអាចរត់ចេញបានសេរីភាព លុះត្រាតែខ្ញុំទៅជាមួយគាត់។ ដូច្នេះប្តីរបស់ខ្ញុំយករបស់របរខ្ញុំនិងម្តាយខ្ញុំដាក់លើរទេះគោទៅរស់នៅជាមួយនឹងគ្រួសាររបស់គាត់។ ពិតណាស់ខ្ញុំទៅជាមួយគាត់ដោយសារតែខ្ញុំមិនមានជំរើសអ្វីនោះទេ ម្តាយរបស់ខ្ញុំឈឺ រួចប្តីរបស់ខ្ញុំមានរទេះគោ។ ម្តាយក្មេករបស់ខ្ញុំស្រឡាញ់ខ្ញុំខ្លាំងណាស់។

**តើមីងធ្លាប់ជួបម្តាយក្មេករបស់មីងពីមុនឬទេ?**

ប្រពន្ធ: ចាស យើងធ្លាប់ជួបគ្នាពីមុន។

**ប្រសិនបើម្តាយរបស់ពូមិនឱ្យពូទៅយកប្រពន្ធ តើពូនឹងទៅយកប្រពន្ធពូឬទេ?**

ប្តី: ខ្ញុំមិនអាចទៅរកនាងទេ [ដោយគ្មានការគាំទ្រពីម្តាយ] ពីព្រោះខ្ញុំមិនមានរទេះគោផ្ទាល់ខ្លួន ហើយរទេះគោគឺជារបស់ម្តាយខ្ញុំ។ តាមពិតទៅខ្ញុំក៏ចង់ឱ្យនាងរស់នៅជាមួយយើងដែរ ពីព្រោះយើងអាចថែរក្សាគ្នាបានពេលធ្វើដំណើរតាមផ្លូវ។ បន្ទាប់មក ពេលយើងធ្វើដំណើរនៅក្នុងព្រៃ [មួយ

សប្ដាហ៍ យើងបានជួបប្រទះនូវការលំបាកច្រើនណាស់ ហើយយើងបានជួយគ្នាទៅវិញទៅមកយ៉ាងច្រើន។ យើងចាប់ផ្ដើមមានអារម្មណ៍ល្អនឹងគ្នាទៅវិញទៅមកបន្ទាប់ពីពេលនោះ។

“…យើងបានជួបប្រទះនូវការលំបាកច្រើនណាស់ ហើយយើងបានជួយគ្នាទៅវិញទៅមកយ៉ាងច្រើន។ យើងចាប់ផ្ដើមមានអារម្មណ៍ល្អនឹងគ្នាទៅវិញទៅមកបន្ទាប់ពីពេលនោះ។

ប្រពន្ធ: ពេលយើងដើរជាមួយគ្នាក្នុងព្រៃ បងប្រុសខ្ញុំនិងខ្ញុំទៅរកទឹក។ ប្ដីរបស់ខ្ញុំបានសង់ខ្ទមតូចដើម្បីរស់នៅបណ្ដោះអាសន្ន។

ប្ដី: ខ្ញុំបានធ្វើខ្ទមសំរាប់ប្រពន្ធខ្ញុំហើយនិងគ្រួសាររបស់នាងស្នាក់នៅ៣ទៅ៤ថ្ងៃពេលយើងកំពុងធ្វើដំនើរ។ យើងបានចំណាយពេលវេលាជាមួយគ្នាហើយយើងបានជួយគ្នាទៅវិញទៅមក។ ដូច្នេះយើងចាប់ផ្ដើមស្រឡាញ់គ្នាទៅវិញទៅមក។ ពេលយើងទៅដល់ xx យើងនៅជាមួយគ្នាហើយយើងមិនបានបែកគ្នាទៀតទេ។

ប្រពន្ធ: ថ្ងៃមួយខ្ញុំបានសួរប្ដីខ្ញុំ "តើបងបានដឹងថាហេតុអ្វីបានជាយើងត្រូវគេបង្ខំឱ្យរៀបការទេ?" គាត់ឆ្លើយថា "ទេ" ខ្ញុំបាននិយាយលេងថា "បងឯងចាស់ជាងខ្ញុំហេតុអីក៏មិនដឹង"។

**តើពូមីងមានកូនប៉ុន្មាននាក់?**

ប្ដី: យើងមានកូន៧នាក់។

ប្រពន្ធ: ខ្ញុំមានផ្ទៃពោះនៅឆ្នាំ១៩៧៩។

ប្ដី: កូនដំបូងរបស់ខ្ញុំកើតក្នុងដើមឆ្នាំ១៩៨០។

**តើកូនរបស់មីងបានដឹងពីការបង្ខំរៀបការរបស់មីងដែរឬទេ?**

ប្រពន្ធ: គេបានដឹង ពីព្រោះថ្មីៗនេះខ្ញុំបានប្រាប់គេ។

ប្ដី: ខ្ញុំបានប្រាប់គេថាយើងទាំងពីរត្រូវគេបង្ខំឱ្យរៀបការ ហើយយើងមិនបានដឹងពីស្នេហាច្រើនដូចក្មេងជំនាន់ក្រោយនោះទេ។

ប្រពន្ធ: មុននេះគេនៅក្មេងដោយសារតែហេតុនេះហើយបានជាខ្ញុំទើបតែ

ប្រាប់គេថ្មីៗនេះ។ ខ្ញុំគិតថាគេនឹងយល់ហើយអំពីស្ថានភាពរបស់យើងក្នុងរបបខ្មែរក្រហម។ ខ្ញុំបានទូន្មានកូនស្រីខ្ញុំឱ្យគោរពតាមប្រពៃណីខ្មែរ ហើយមិនគួរឱ្យប្រុសប៉ះដៃជើង ឬខ្លួនប្រាណមុនរៀបការនោះទេ។ ខ្ញុំបានប្រាប់គេផងដែរថា "ម្ដាយបានឆ្លងកាត់ការលំបាកច្រើនណាស់ក្នុងរបបខ្មែរក្រហម ហើយម្ដាយមិនបានស្រឡាញ់ឪពុករបស់កូនឯងទេ ពេលម្ដាយរៀបការនឹងគាត់។"

### តើកូនមីងបានរៀបការឬនៅ?

ប្រពន្ធ: នៅសល់តែកូនស្រីមួយទេដែលមិនទាន់រៀបការ។ ពិធីរៀបការកូនរបស់ខ្ញុំគឺសប្បាយណាស់ ហើយត្រូវបានធ្វើឡើងតាមប្រពៃណី។ កូនបងរបស់ខ្ញុំគាត់រកស៊ីទិញជ្រូកចិញ្ចឹមជីវិត។ កូនទី២របស់ខ្ញុំជាកសិករ ហើយកូនទី៣ជាអ្នកនេសាទត្រី។ កូនស្រីពៅដែលមិនទាន់រៀបការ នាងមានអាយុ១៩ឆ្នាំ ហើយកំពុងនៅរៀនថ្នាក់ទី១១។

ប្ដី: គេរស់នៅក្បែរយើង ពីព្រោះយើងបានចែកដីក្នុងភូមិឱ្យគេ។

### តើពូមីងមានអារម្មណ៍បែបណាដែរនៅពិធីរៀបការកូន?

ប្ដី: ខ្ញុំមានអារម្មណ៍សប្បាយចិត្តដែលគេបានរៀបការតាមប្រពៃណី ហើយ ខ្ញុំអាណិតខ្លួនឯង ពីព្រោះពិធីរៀបការធ្វើឡើងក្នុងរបបខ្មែរក្រហម គឺវាខុសគ្នាទាំងស្រុងពីការរៀបការតាមប្រពៃណី។ វាមានភ្ញៀវតិចតួចមែនទែនក្នុងរបបនោះ ហើយគ្មានឪពុកម្ដាយចូលរួមទេ។

ប្រពន្ធ: ខ្ញុំបានប្រាប់កូនប្រុសនិងកូនស្រីខ្ញុំថា ការរៀបការនោះគឺល្អណាស់សំរាប់ជីវិត ផ្ទុយទៅវិញយើងអាចរៀបចំពិធីតូចតាចបំផុត។

### តើអ្នកជិតខាងរបស់ពូមីងបានដឹងពីការបង្ខំរៀបការរបស់អ្នកទាំងពីរទេ?

ប្ដីនិងប្រពន្ធ: គេបានដឹង។

### តើគេមានបានរើសអើងអ្នកទាំងពីរដែរឬទេ?

ប្ដី: ទេ ការរៀបការរបស់យើងកើតមាននារបបខ្មែរក្រហម ហើយអ្នកដទៃទៀតក៏ឆ្លងកាត់ដូចគ្នាអញ្ចឹងដែរ។

**តើមីងធ្លាប់បានចង់រៀបពិធីមង្គលការឡើងវិញដែរឬទេ?**

ប្រពន្ធ: ក្នុងឆ្នាំ១៩៧៩ ម្តាយរបស់ខ្ញុំបាននិយាយថាគាត់ចង់រៀបពិធីការសំរាប់យើងម្តងទៀតតែពេលនោះយើងមិនមានលុយទេ។ ម្តាយរបស់ខ្ញុំយំពេលកម្មាភិបាលបានបង្ខំប្តីខ្ញុំឱ្យរៀបការជាមួយខ្ញុំ។ គាត់យំពីព្រោះគាត់អាណិតយើង។ កូនគាត់ភាគ ច្រើនបានរៀបការត្រឹមត្រូវនាជំនាន់លន់នល់។[១៥] គាត់មិនបានគិតថាប្តីរបស់ខ្ញុំនិងខ្ញុំ រៀបការដោយបែបនេះទេ។ យើងក៏ចង់ធ្វើពិធីជប់លៀងតាមប្រពៃណីដែរ ប៉ុន្តែយើងមិនមានលុយកាក់គ្រប់គ្រាន់ទេ ហើយឥឡូវនេះយើងព្យាយាមសន្សំលុយសំរាប់ពេលយើងចាស់ទៅ។

១៥ រដ្ឋាភិបាលបានទំលាក់ចេញពីដំណែងដោយខ្មែរក្រហមបានឡើងកាន់អំណាច ឆ្នាំ ១៩៧០ - ១៩៧៥។ មើលសទ្ទានុក្រម “លន់ នល់”

**ក្នុងឆ្នាំ១៩៧៩ និងឆ្នាំ១៩៨០ តើរាជរដ្ឋាភិបាលមានបានធ្វើអ្វីខ្លះសំរាប់ជាសំណងដែរឬទេ?**

ប្តី: ទេ មិនទេ។

**តើពូមីងមានចុះសំបុត្រអាពាហ៍ពិពាហ៍ដែរឬទេ?**

ប្រពន្ធ: ទេ ពួកយើងមិនបានចុះឈ្មោះទេ។ ខ្ញុំអត់ចង់ធ្វើវាទេព្រោះពួកយើងចាស់ហើយឥឡូវនេះ។

ប្តី: យើងបានថតរូបក្នុងសំលៀកបំពាក់ប្រពៃណីនៅហាងថតរូបក្នុងឆ្នាំ២០០០។ យើងបានតុបតែងមុខ។ ដោយសារយើងមិនបានរៀបការតាមប្រពៃណី យើងចង់ធ្វើដូចជាបានរៀបការតាមរយៈរូបថតទាំងនេះ។

ប្រពន្ធ: ខ្ញុំសប្បាយចិត្តដែលខ្ញុំអាចតុបតែងមុខហើយថតរូប។ ខ្ញុំស្រឡាញ់រូបថតហ្នឹងណាស់។

**ដោយសារតែអ្នកទាំងពីរបានរស់នៅជាមួយគ្នារហូតមកដល់សព្វថ្ងៃ តើពូមីងមានគំរោងបែកគ្នាដែរទេ?**

ប្រពន្ធ: ទេ យើងចាស់ហើយ។ ខ្ញុំបានសំរេចចិត្តនៅជាមួយគាត់ពីព្រោះយើងមានកូនជាមួយគ្នា ហើយមានអនុស្សាវរិយ៍ល្អៗនឹងគ្នាពីពេលយើងនៅក្នុងព្រៃ។ សព្វថ្ងៃនេះ ខ្ញុំមិនចង់មានដៃគូផ្សេងទៀតនោះទេ។

**ចុះពូវិញយ៉ាងម៉េចដែរ?**

ប្ដី: ម្ដាយរបស់ខ្ញុំលើកទឹកចិត្តឱ្យយើងរស់នៅជាមួយគ្នា បន្ទាប់មកយើងមានកូនយើងស្រឡាញ់កូន ហើយយើងសំរេចចិត្តរស់នៅជាមួយគ្នារហូតដល់បច្ចុប្បន្ន។ ខ្ញុំមានអារម្មណ៍សោកស្ដាយដែលយើងមិនបានរៀបការម្ដងទៀតតាមប្រពៃណី។

# ករណីសិក្សា ៤

ហអរ ភេទស្រី អាយុ ៥២ឆ្នាំ
សំភាសន៍នៅថ្ងៃទី ២ ឧសភា ២០១៤
នៅផ្ទះរបស់គាត់។

**តើមីងមានអាយុប៉ុន្មាននៅពេលមីងបានរៀបការនៅរបបខ្មែរក្រហម?**

ពេលនោះមីងមិនមែនមានអាយុ២០ឆ្នាំទេ។ មីងទើបតែមានអាយុ ១៨ឆ្នាំប៉ុណ្ណោះ។ មីងនៅក្មេងនៅឡើយ។

**ខ្ញុំចង់ដឹងអំពីយោបល់របស់មីងទូទៅអំពីការរៀបការមុនពេលរបបខ្មែរក្រហម។ តើការរៀបការមានអត្ថន័យអ្វីខ្លះចំពោះមីង?**

នៅក្នុងរបបខ្មែរក្រហម ការរៀបការគឺគ្មានន័យអ្វីទេ។ យើងគ្មានផ្កាស្លា គ្មានមេបា គ្មានអាចារ្យ និងគ្មានចាស់ទុំដឹងឮអ្វីទាំងអស់។ យើងបានរៀបការដោយគ្រាន់តែសំដីពីរ ឬបីម៉ាត់ដោយមិនមានន័យអ្វីឡើយ។ វាទទេតែម្តង ។

**តើការរៀបការតាមបែបប្រពៃណីមានសារៈសំខាន់មែនទេ?**

ចាស គឺសំខាន់ខ្លាំងណាស់។ កាលខ្ញុំនៅក្មេង ខ្ញុំតាមយាយរបស់ខ្ញុំទៅរៀបការអ្នកនៅស្រុកភូមិជាមួយគ្នា។ នៅពេលនោះការរៀបការមិនមានតែមួយថ្ងៃទេ គឺបីថ្ងៃបីយប់។ ហើយគេធ្វើនំនិងបង្អែម រីឯមង្គលការវិញគឺធំជាងឥឡូវឆ្ងាយណាស់។ មានតន្ត្រី មេក្រូ និងការតុបតែង ការស្លៀកពាក់ខោអាវពិសេសៗជាច្រើន។ មិនថាឥឡូវឬពីមុនគេមានអ្វីៗទាំងអស់នៅក្នុងពិធីមង្គលការ។ មានតែពេលដែលខ្ញុំរៀបការទេដែលមិនមានអ្វីទាំងអស់។ ការរៀបការតាមបែបប្រពៃណីគឺពិបាករៀបចំណាស់ នៅរបបខ្មែរក្រហម។ សូម្បីតែពេលចាស់ៗ ឬក៏ឪពុកម្តាយរៀបចំ ក៏ពួកគាត់ត្រូវទទួលការយល់ព្រមពីកូនៗរបស់គាត់ដែរ។ មានតែនៅរបបខ្មែរក្រហមទេដែលយើងត្រូវតែរៀបការជាមួយអ្នកដែលយើងមិនចង់រៀបការជាមួយ ។

## តើការរៀបការរបស់មីងយ៉ាងដូចម្ដេចដែរក្នុងរបបខ្មែរក្រហម?

វាគ្មានន័យអ្វីទាំងអស់។ មានអ្នករៀបការពី៥០ទៅ៦០គូនៅពេលរៀបការម្ដងៗដោយគ្រាន់តែនិយាយតែពីរឬបីម៉ាត់ដោយចំណាយពេលតែ ២ ទៅបីនាទីប៉ុណ្ណោះ។ តើវាមានន័យអ្វី? ដោយសារតែវាមិនមានន័យអញ្ចឹងហើយទើបមានអ្នកលែងលះគ្នាឬក៏រស់នៅដាច់ដោយឡែកពីគ្នាដូចអ្វីដែលបានកើតឡើងចំពោះខ្ញុំឥឡូវនេះអញ្ចឹង។ ការរៀបការពីមុនគឺខុសគ្នាឆ្ងាយណាស់ ក្រោយពេលរៀបការហើយប្ដីប្រពន្ធអាចរស់នៅជាមួយគ្នា ដោយមានសុភមង្គល និងចេះជួយធ្វើការគ្នាដើម្បីផ្គត់ផ្គង់គ្រួសារ។ តែនៅក្នុងរបបខ្មែរក្រហមវិញ ឪពុកម្ដាយឬសាច់ញាតមិនត្រូវបានអនុញ្ញាតឱ្យចូលរួមឬក៏ដឹងឮអំពីការរៀបការទេ- "អ្ហ៎... កូនរបស់យើងរៀបការ... ដូចនេះឬដូចនោះជាដើម។" មិនមានបងប្អូនណាបានដឹងថាយើងបានរៀបការនោះទេ។ មានប្ដីប្រពន្ធជាច្រើនដែលបានរៀបការក្នុងរបបខ្មែរក្រហមបានលះលែងគ្នាជាងពាក់កណ្ដាលឬក៏លើសពីនេះដែលឥឡូវនេះបានលះលែងគ្នា។ ការរៀបការក្នុងរបបខ្មែរក្រហមកំរ នឹងបានរស់នៅជាមួយគ្នាបានរហូតមកដល់ឥឡូវនេះណាស់។[១៦] ការលះលែងតែងតែបានកើតឡើងនៅក្នុងរបបខ្មែរក្រហមពីព្រោះដោយសារតែមិនមានសេចក្ដីស្រលាញ់រវាងដៃគូរ ដូច្នេះហើយទើបក្រោយរបបខ្មែរក្រហមត្រូវបានរំលំមានប្ដីប្រពន្ធជាច្រើនបានលះលែងគ្នា ដូចខ្ញុំនិងប្ដីរបស់ខ្ញុំជាដើម ។

## តើជាដំបូងមីងដឹងយ៉ាងដូចម្ដេចថាមីងត្រូវរៀបការ?

ពេលនោះបុរសម្នាក់បានធ្វើការស្នើរសុំទៅមេកង។ ពេលនោះគេមានមេ ក្រុមយុវជន និងមេក្រុមយុវនារីដែលមានប្រហែលពី៥០ទៅ១០០នាក់ក្នុងមួយក្រុម។ ពេលដែលមានយុវជនណាម្នាក់ធ្វើការស្នើរសុំប្រធានក្រុមនឹងរៀបចំនូវតារាងឈ្មោះយុវនារី អោយយុវជននោះ។ បន្ទាប់មកសំណើក៏ត្រូវបានបញ្ជូនទៅអោយមេក្រុមយុវនារីថា—"មានយុវជនម្នាក់នេះចង់រៀបការជាមួយយុវនារីម្នាក់នេះជាដើម។" នៅពេលប្រជុំពេលយប់មេក្រុមយុវនារីប្រកាសដូចជា "អ្ហ៎ មិត្ត ក. មានយុវជនម្នាក់

បានស្នើសុំរៀបការជាមួយមិត្ត... អង្គការនឹងរៀបការមិត្តជាមួយនឹងបុរសម្នាក់នេះហើយ។”

បុរសមិនអាចធ្វើការស្នើរសុំបាន លុះត្រាតែមានការយល់ស្របពីអង្គការផងដែរ។ ពួកគេ [សមាជិកខ្មែរក្រហម] មើលប្រវត្តិគ្រួសារនិងត្រូវប្រាកដថា "សាវតាអ្នកទាំងពីរត្រូវគ្នា។” ប្រសិនបើយើងធ្លាប់ជាសត្រូវរបស់អង្គការ—ដូចជាយើងមានសាច់ញាតិដែលត្រូវបានសំលាប់ដោយអង្គការ—យើងក៏ត្រូវបានចាត់ទុកថាជាខ្មាំង ហើយខ្មាំងអាចរៀបការបានតែជាមួយខ្មាំងប៉ុណ្ណោះ។ ឧទាហរណ៍ដូចជារូបខ្ញុំជាដើម ឪពុករបស់ខ្ញុំត្រូវបានសំលាប់ ដូចនេះខ្ញុំមានសាវតាមិនល្អក៏ដោយសារតែខ្ញុំមានការពាក់ព័ន្ធជាមួយខ្មាំង។ បុរសម្នាក់ដែលបានស្នើរសុំរៀបការជាមួយខ្ញុំក៏មានការពាក់ព័ន្ធជាខ្មាំងដែរ ដូច្នេះហើយទើបគេឱ្យរៀបការជាមួយគ្នា។ មានតែយុវជនយុវនារីណាដែលសាវតារបស់ពួកគាត់មិនមានពាក់ព័ន្ធនឹងខ្មាំងទេទើបគេហៅថា"សាវតាដែលត្រូវគ្នា។” ដំណឹងនេះជាអ្វីដែលខ្ញុំត្រូវបានប្រាប់ដោយមេកង។

សំរាប់ការរៀបការរបស់ខ្ញុំ មេក្រុមបានប្រាប់ខ្ញុំនៅពេលប្រជុំពេលយប់ "មិត្ត នៅថ្ងៃនេះ មិត្តត្រូវធ្វើការប្តេជ្ញាបុរសម្នាក់នេះជាប្តីរបស់មិត្តហើយមិត្តមិនអាចបដិសេធបានទេ។ បើទោះណាជាមិត្តមិនចង់រៀបការក៏ដោយក៏មិត្តត្រូវតែរៀបការបើទោះជាមិត្តមិនចង់រៀបការជាមួយបុរស ម្នាក់នេះក៏ដោយមិត្តត្រូវតែរៀបការ ពីព្រោះអង្គការបានរៀបចំសំរាប់មិត្ត ដូច្នេះមិត្តមិនអាចបដិសេធបានទេ” មេក្រុមយុវនារីគឺជានារី។ ការប្រជុំតែងតែធ្វើឡើងនៅពេលយប់ពីព្រោះពួកគេមិនចង់ខ្ជះខ្ជាយពេលវេលាធ្វើការពេលថ្ងៃ។ ការប្រជុំទាំងអស់គឺធ្វើនៅពេលយប់រហូតដល់ម៉ោង ១០និង ១១យប់។

ស្រ្តីមិនអាចធ្វើការស្នើរសុំរៀបការបានទេ មានតែបុរសទេដែលអាចធ្វើបាន។ ខ្ញុំមិនដឹងថាមកពីអ្វីនោះទេ។ យុវជនអាចមើលយុវនារី និងអាចស្គាល់ឈ្មោះនារីនោះ ក៏ដោយសារតែពួកគេធ្វើការជាមួយគ្នាឬក៏គាត់

១៦ ដោយផ្អែកទៅលើលទ្ធផលនៃការស្រាវជ្រាវតាមបែបបរិមាណដែលអត្ថបទនេះជាអត្ថបទអម ៥១,៣ ភាគរយនៃការរៀបការត្រូវបានបន្តនៅក្នុងកំឡុងពេលណាមួយបន្ទាប់ ពីរបបខ្មែរក្រហមរលំ។ សូមមើល "ដូចខ្មោចប្តូរកាយ” - ការសិក្សាអំពីផលប៉ះពាល់នៃការរៀបការដោយ បង្ខំក្នុងរបបខ្មែរក្រហម” អង្គការចិត្តសង្គម អន្តរវប្បធម៌ កម្ពុជា (ធីភីអូ) ខែតុលា ឆ្នាំ ២០១៤

អាចមានសាច់ញាតិដែល ធ្វើការយ៉ាងជិតស្និតជាមួយនារីនោះ។ ដូចនេះ ហើយបងប្អូនរបស់គាត់ អាចនិយាយមកកាន់គាត់ថា "អ៊ូ ឯងគួរតែធ្វើការស្នើរសុំរៀបការជាមួយ នារីម្នាក់នេះ។ នាងជាមនុស្សល្អ ដូចនេះដូចនោះជាដើម។" បុរសទាំង ឡាយតែងតែដឹងអំពីនារីៗតាមរយៈបណ្តាញទាំងនេះ។ ដូចនឹងករណីខ្ញុំអញ្ចឹង។ បងប្អូនជីដូនមួយរបស់ប្តីខ្ញុំធ្វើការជាមួយខ្ញុំ ហើយពួកគេបានប្រាប់ប្តីខ្ញុំឱ្យធ្វើការស្នើសុំរៀបការជាមួយខ្ញុំ បើទោះជាខ្ញុំមិនដែលជួបប្តីខ្ញុំផ្ទាល់មុខក៏ដោយ។ នាងបានប្រាប់ប្តីខ្ញុំថា "ឯងគួរតែធ្វើការស្នើរសុំរៀបការជាមួយនារីម្នាក់នេះ។ នាងធ្វើការជាមួយខ្ញុំ ហើយនាងសុភាពរាបសា។" ដូច្នេះហើយបានជាប្តីរបស់ខ្ញុំបានធ្វើការស្នើរសុំរៀបការជាមួយខ្ញុំ។ ប៉ុន្តែដឹងទេ ពេលខ្លះមិនមានការស្នើរសុំអ្វីទេ។ អង្គការគ្រាន់តែរៀបចំតែម្តងថាតើអ្នកណាត្រូវរៀបការជាមួយអ្នកណា។

**តើករណីភាគច្រើនត្រូវបានរៀបចំដោយអង្គការឬក៏ការស្នើរសុំដោយបុរស?**

ខ្ញុំមិនអាចនិយាយបាន ប្រហែលជាទាំងពីរភាគី។ មានករណីខ្លះអង្គការគ្រាន់តែមើលសាវតារបស់យើង ហើយប្រសិនបើសាវតាយើងត្រូវគ្នា ពួកគេនឹងបន្តដោយរៀបចំរៀបការយើង។ ប្រហែលជាមួយសប្តាហ៍ក្រោយពេលនៃការប្រកាសនៅក្នុងអង្គប្រជុំ ពួកយើងនឹងរៀបការ។ ខ្ញុំត្រូវបានគេប្រាប់ថា "បើសិនជាមិត្តមិនព្រមមិត្តមិនមែនជាកូនរបស់អង្គការទេ។ មិត្តត្រូវតែធ្វើការប្តេជ្ញា។" នៅពេលនោះក៏មានអ្នកផ្សេងទៀតរៀបការដែរ ហើយខ្ញុំចង់រស់និងមិនចង់ត្រូវបានគេយកទៅសំលាប់ទេ។ បើទោះជាខ្ញុំមានឱកាសប្រាប់ឪពុកម្តាយរបស់ខ្ញុំក៏ដោយ ក៏ពួកគាត់មិនហ៊ានទៅប្រឆាំងនឹងអង្គការដែរ ដូច្នេះហើយខ្ញុំគ្មានជំរើសអ្វីក្រៅពីធ្វើតាមអង្គការបានរៀបចំឱ្យខ្ញុំប៉ុណ្ណោះ។ ហើយនៅពេលដែលខ្ញុំធ្វើការប្តេជ្ញា ឪពុកម្តាយរបស់ខ្ញុំមិនបានដឹងអ្វីទាំងអស់។

**តើមីងមានអារម្មណ៍យ៉ាងដូចម្តេចនៅពេលនោះ?**

ខ្ញុំមានអារម្មណ៍ថាការប្តេជ្ញានេះមិនមាននរណាទទួលស្គាល់មិនដូចនឹងការរៀបការមុនរបបនេះទេ។ ខ្ញុំមានអារម្មណ៍សោកស្តាយចំពោះខ្លួនឯង

សោកស្តាយដោយសារតែខ្ញុំមិនមានការរៀបការជម្មតាមួយដោយឪពុកម្តាយខ្ញុំមិនបានដឹងថាខ្ញុំបានរៀបការ បងប្អូនខ្ញុំក៏មិនបានដឹង។ ខ្ញុំគ្រាន់តែបានរៀបការនៅក្នុងចំណោមមនុស្សប្លែកមុខមួយក្រុមដែលខ្ញុំមិនដែលធ្លាប់ស្គាល់ ដូចនេះហើយខ្ញុំមានអារម្មណ៍សោកស្តាយ ប៉ុន្តែខ្ញុំបានយល់ព្រមរៀបការដើម្បីរស់។

> “ *យើងបានដេកបែរខ្នងដាក់គ្នានិងមិនបាននិយាយគ្នាអ្វីទាំងអស់ ហើយខ្ញុំមិនអាចឈប់គិតបានដោយសារតែមានមនុស្សចំឡែកដេកជិតខ្ញុំ។*

## តើមីងអាចនិយាយបន្ថែមទៀតអំពីនីតិវិធីនៃការប្តេជ្ញាចិត្តនេះទេ?

វាគឺនៅ xx នៅជិតទល់ដែនវៀតណាម។ ខ្ញុំបានធ្វើការនៅទីនោះ ហើយក្រោយពេលប្តេជ្ញារួចខ្ញុំនៅទីនោះដដែល។ វាត្រូវបានរៀបចំឡើងនៅក្នុងសាលប្រជុំមួយនៅពេលយប់។ មានទាំងអស់២៤គូ។ ខ្ញុំមិនបានចាំថ្ងៃខែទេ ហើយក៏មិនបានដឹងថាថ្ងៃអាទិត្យ ឬក៏ថ្ងៃច័ន្ទដែរ។ ពួកគេបានឱ្យខោអាវពណ៌ខ្មៅមកអោយយើងស្លៀកពាក់។ ប្តីរបស់ខ្ញុំធ្លាប់ឃើញខ្ញុំពី មុនប៉ុន្តែខ្ញុំមិនដែលធ្លាប់ឃើញគាត់ទេ។ ខ្ញុំគ្រាន់តែបានធ្វើតាមបញ្ជា និងធ្វើការប្តេជ្ញាហើយបន្ទាប់មកមានមេកងពីរនាក់បង្ហាញបន្ទប់ដែលយើងនឹងស្នាក់នៅនាយប់នោះហើយខ្ញុំគ្រាន់តែតាមគេ។ បន្ទប់ទាំងនោះនៅជិតៗគ្នាដោយមានកំរាលតូចមួយនៅលើផ្ទៃរាបស្មើរ ហើយជញ្ជាំងត្រូវបានបាំងដោយស្លឹកត្នោត។ សាលនៃបន្ទប់ទាំងនោះវែងដែលត្រូវបានក្រាលដោយរនៀបឫស្សី។ បន្ទប់នីមួយៗមិនត្រូវបានគ្របដណ្តប់ទាំងស្រុងនោះទេ ហើយយើងអាចឃើញគ្នាទៅវិញទៅមក។ នៅយប់ដំបូងនោះយើងមិនបានរួមដំនេកជាមួយគ្នាទេ។ យើងបានដេកបែរខ្នងដាក់គ្នានិងមិនបាននិយាយគ្នាអ្វីទាំងអស់ ហើយខ្ញុំមិនអាចឈប់គិតបានដោយសារតែមានមនុស្សចំឡែកដេកជិតខ្ញុំ។ មិនដូចក្មេងសម័យឥឡូវទេ យើងមិនបានដឹងអំពីការរួមភេទអ្វីទេ។ យើងល្ងង់ណាស់នៅក្នុងរបបនោះ ហើយក៏មិនបានដឹងអំពីការរៀបការអ្វីដែរ។ ពេលនោះគេ មានកងឈ្លបហើយយើងក៏ខ្លាចមានបញ្ហាផងដែរ ដូច្នេះហើយយើងមានតែស្ងាត់និងសម្ងំដេកប៉ុណ្ណោះ។ យើងខ្លាចអ្នកយាម

វាយ។ យើងមិនត្រូវបានអនុញ្ញាតឱ្យចេញពីបន្ទប់ដែលគេអោយនៅទេ បើយើងចេញគេនឹងវាយយើង។ កាលនោះ គេធ្វើបាបយើងដូចសត្វធាតុ អញ្ចឹង។ ចាស ក្រោយពេលប្ដេជ្ញារួច ពួកគេយកយើងចូលក្នុងបន្ទប់ គេយាម និងស៊ើបការពីយើង។

ខ្ញុំមានការខ្មាស់អៀន តែគាត់មិនបានខ្មាស់អៀនអ្វីទេពីព្រោះគាត់ជាបុរស។ ថ្ងៃបន្ទាប់ យើងបានក្រោកពីព្រលឹមដើម្បីទៅធ្វើការរៀងៗខ្លួន ហើយយើងមិនបានជួបគ្នាទេ រហូតដល់យប់ម៉ោងប្រហែល៨ឬ៩យប់ ហើយបន្ទាប់មកទៀតយើងចូលដេក។ វាត្រូវការចំណាយពេលរាប់ខែ មុននឹងប្ដីរបស់ខ្ញុំនិងខ្ញុំអាចមើលមុខគ្នាត្រង់ទៅត្រង់មក។ ខ្ញុំមិនបានដឹងថាតើមុខរបស់ប្ដីខ្ញុំមានមុខមាត់យ៉ាងម៉េចទេសំរាប់ខែដំបូងក្រោយពីបានរៀបការពីព្រោះយើងបានជួបគ្នាតែពេលយប់។ ហើយមានថ្ងៃមួយមានការប្រជុំស្រុកដ៏ធំមួយ ទើបខ្ញុំសំរេចចិត្តចង់មើលមុខរបស់គាត់ ហើយខ្ញុំបានមើលគាត់ដោយលួច លាក់។ គាត់ខ្មៅហើយស្គម និងមើលទៅមិនស្អាតទាល់តែសោះ។ ខ្ញុំមានការសោកស្ដាយជាខ្លាំង ហើយយំតែម្នាក់ឯងនៅពេលដែលខ្ញុំបានដឹង ប៉ុន្តែសួរថា តើខ្ញុំអាចធ្វើអ្វីបាន? ខ្ញុំមានការសោកស្ដាយជាខ្លាំងដោយមិនមានសេចក្ដីស្រលាញ់អ្វីទាំងអស់ ហើយខ្ញុំគិតថាឪពុកម្ដាយរបស់ខ្ញុំប្រាកដជាបន្ទោសខ្ញុំជាខ្លាំង ប្រសិនបើគាត់បានដឹងពីមង្គលការនេះ។ ក្រោយពេលប្រជុំចប់ ខ្ញុំបានដើរទៅកាន់កន្លែងធ្វើការរបស់ខ្ញុំ ហើយខ្ញុំបានជួបគាត់តាមផ្លូវ។ ខ្ញុំមិនបាននិយាយទៅរកគាត់ទេ យើងធ្វើដូចជាមិនដែលស្គាល់គ្នា។

## តើយើងនិយាយរកគ្នានៅពេលណា?

មានពេលខ្លះយើងនិយាយរកគ្នា ឬក៏គាត់បានសួរខ្ញុំនូវសំនួរមួយចំនួន ហើយខ្ញុំបានឆ្លើយវិញយ៉ាងខ្លី។ គាត់បានសួរពីគ្រួសាររបស់ខ្ញុំ ការងារ និងសួរពីនេះពីនោះជាដើម។ ប៉ុន្តែខ្ញុំមានការខ្មាស់អៀនដោយសារតែយើងសំរាកជិតបន្ទប់អ្នកផ្សេងទៀត ហើយយើងងាយនឹងឮគ្នាទៅវិញទៅមក។ អញ្ចឹងហើយ សួរថាតើយើងជជែកគ្នារបៀបណា? ខ្ញុំមិនហ៊ាន

សូម្បីតែរំកិលខ្លួនពេលដេកផង ដោយសារតែផ្ទៃក្រាលដោយឫស្សីមួយដើមប៉ុណ្ណោះ។ យើងធ្វើអ្វីក៏ដោយក៏មានអ្នកនៅបន្ទប់ផ្សេងទៀតនឹងដឹង ហើយបានឮ។ យើងមិនហ៊ានរួមភេទក៏ដោយសារតែខ្លាចអ្នកផ្សេងនឹងឮ។ សូម្បីតែក្អួយ [សំដៅលើអ្នកសំភាសន៍] ក៏មិនហ៊ានដែរ។ ខ្ញុំមិនដឹងថាហេតុអ្វីបានជាពួកគេយកយើងមកដាក់ក្នុងបន្ទប់នោះ ទីដែលយើងមិនហ៊ានរួមភេទបែបនេះទេ ហើយគេតាមលបស្តាប់យើងទៀត ។

> *"ខ្ញុំមិនបានដឹងថាតើមុខរបស់ប្តីខ្ញុំមានមុខមាត់យ៉ាងម៉េចទេ សំរាប់ខែដំបូងក្រោយពីបានរៀបការ ពីព្រោះយើងបានជួបគ្នាតែពេលយប់។*

## តើមីងបានស្រលាញ់ប្តីរបស់មីងទេក្រោយមក?

ខ្ញុំមានអារម្មណ៍ពេលខ្លះស្រលាញ់ពេលខ្លះមិនស្រលាញ់។ យើងគ្រាន់តែរស់នៅជាមួយគ្នាយ៉ាងស្រុះស្រួលមិនថាយើងស្រលាញ់គ្នា ឬអត់ នោះទើបអង្គការមិនដាក់ទោសយើង។ មួយរយៈក្រោយមកពួកយើងត្រូវបានបញ្ជូនទៅកាន់កន្លែងផ្សេងមួយទៀតជាទីដែលយើងត្រូវបានអនុញ្ញាតឱ្យសាងសង់ផ្ទះតូចផ្ទាល់ខ្លួន ហើយបន្ទាប់មកយើងអាចរួមភេទដោយសារតែមានលក្ខខ័ណ្ឌប្រសើរ និងឯកជនជាងមុន។ យើងបានយល់ស្របថានឹងរស់នៅជាមួយគ្នាដូចប្តីប្រពន្ធ ដោយសារតែយើងមិនអាចលែងលះគ្នាបាន និងក៏ដោយសារតែយើងចង់រស់បន្តទៀត។ ស្រលាញ់ ឬអត់ យើងចង់ការពារអោយរួចពីការសំលាប់។ ដូចនេះហើយ យើងបានរស់ដោយសុខដុមដូចដៃគូផ្សេងទៀតដែរ។ ប្រហែលជា៤ឬ៥ខែ ក្រោយពេលយើងបានរៀបការទើបរៀតណាមបានមកដល់។ នាពេលនោះខ្ញុំបានមានផ្ទៃពោះកូនស្រីរបស់ខ្ញុំ ដែលសព្វថ្ងៃនេះនាងពេញវ័យហើយ។ ខ្ញុំមិនបានដឹងអ្វីអំពីការមានផ្ទៃពោះនោះទេ។ យើងបានយល់ព្រមមានទំនាក់ទំនងផ្លូវភេទនឹងគ្នា ប៉ុន្តែមិនបានដឹងអំពីរបៀបការពារមិនឱ្យមានផ្ទៃពោះនោះទេ ហើយប្តីខ្ញុំក៏អញ្ចឹងដែរ។ ខ្ញុំមិនបានដឹងថាខ្ញុំបានមានផ្ទៃពោះរហូតដល់ខ្ញុំមានអារម្មណ៍ថាមានទារកកម្រើកក្នុងពោះរបស់ខ្ញុំ។ ខ្ញុំបានផ្តល់កំណើតក្រោយរបបត្រូវបានរលំ។ កូនស្រីរបស់ខ្ញុំពេលនេះនាងមានកូន៣នាក់។

ក្រោយរបបត្រូវបានបញ្ចប់ ប្ដីរបស់ខ្ញុំនិងខ្ញុំបានទៅនៅជាមួយម្ដាយរបស់ខ្ញុំ នៅក្នុងភូមិរបស់យើង។ ម្ដាយក្មេករបស់ខ្ញុំបានរស់នៅជាប់ភ្នំនៅក្នុងភូមិដូចគ្នា។ មួយរយៈក្រោយមក ប្ដីរបស់ខ្ញុំបានទាមទារឱ្យមករស់នៅជាមួយម្ដាយរបស់គាត់។ ដោយសារតែខ្ញុំ គិតដល់កូនស្រីរបស់ខ្ញុំទើបខ្ញុំតាមគាត់។ ខ្ញុំបានផ្ដល់កំណើតឱ្យកូនខ្ញុំពីរនាក់ទៀតនៅពេលដែលរស់នៅទីនោះ ដូច្នេះយើងមានកូនបីនាក់ពេលដែលប្ដីរបស់ខ្ញុំ និងខ្ញុំបានលះលែងគ្នា។

## ហេតុអ្វីបានជាមីងលះលែង?

យើងលះលែងដោយសារតែពេលនោះប្ដីរបស់ខ្ញុំជាទាហ៊ាន ហើយគាត់ប្ដូរមកធ្វើនៅទីក្រុង xx ហើយគាត់មាននូវរឿងអាស្រូវស្នេហាជាមួយអ្នកផ្សេង។ គាត់មានមិត្តស្រីជាច្រើន។ ពេលដែលគាត់រកលុយបាន គាត់បានរៀបការជាមួយប្រពន្ធផ្សេងទៀត ហើយទុកឱ្យខ្ញុំនៅផ្ទះជាមួយម្ដាយរបស់គាត់។ ខ្ញុំមានកូនបីនាក់ហើយខ្ញុំធ្វើស្រែជាមួយម្ដាយក្មេករបស់ខ្ញុំ ហើយដោយសារ តែគាត់ជាទាហ៊ានគាត់កំរមកផ្ទះណាស់។ វាកំសត់ណាស់។ គាត់ទទួលបានប្រាក់ខែហើយបន្ទាប់មកគាត់រកបានមិត្តស្រីថ្មី និងរស់នៅជាមួយគេរាប់ខែ។ រឿងទាំងនេះវាមិនអាចលាក់បានទេនៅទីក្រុង xx។ ខ្ញុំមានពូម្នាក់នៅទីក្រុងមួយនេះ ដោយគាត់បានប្រាប់ខ្ញុំថា "ប្ដីរបស់ឯងបានរៀបការជាមួយប្រពន្ធម្នាក់ទៀតហើយ។" ខ្ញុំមិនដឹងត្រូវធ្វើយ៉ាងម៉េច។ ខ្ញុំមិនអាចចេញទៅរកគាត់ ដោយសារតែខ្ញុំមានផ្ទះ មានកូន មានគោ និងម្ដាយក្មេកដែលត្រូវមើលថែ។ ដូចនេះខ្ញុំមិនបានតាមទៅរកគាត់ទេហើយ "បើគាត់នៅចាំយើងគាត់នឹងត្រឡប់មកវិញ។" ពេលគាត់មកវិញ ខ្ញុំបានព្យាយាមនិយាយជាមួយគាត់ ប៉ុន្តែគាត់មិនស្ដាប់ ហើយគាត់បានចាកចេញអស់មួយរយៈធំម្ដងទៀត ដោយបានរៀបការជាមួយប្រពន្ធផ្សេងម្នាក់ទៀត។ គាត់មានប្រពន្ធជាច្រើន។ ចុងក្រោយបង្អស់ គាត់បានរៀបការជាមួយប្រពន្ធផ្សេងម្នាក់ទៀតនៅភ្នំ xx នៅខាងកើតក្រុង xx។ ខ្ញុំបានទៅកន្លែងដែលគាត់បានរៀបការ។ ខ្ញុំជិះរថភ្លើង។ កូនស្រីច្បងរបស់ខ្ញុំ មានអាយុប្រហែល១០ឆ្នាំហើយ ខ្ញុំបាន

យកនាងទៅជាមួយខ្ញុំទៅជួបមេរបស់ប្តីខ្ញុំ។ ខ្ញុំបានដាក់ពាក្យបណ្តឹងជាមួយមេរបស់គាត់ដើម្បីបញ្ឈប់មង្គលការនេះ មេរបស់ប្តីខ្ញុំបានយល់ព្រមជាមួយនឹងខ្ញុំថា ប្រសិនបើគាត់រៀបការម្តងទៀតគាត់មិនអាចបំពេញកាតព្វកិច្ចនៅកន្លែងការងាររបស់គាត់បានទៀតទេ។ នាព្រឹកថ្ងៃរៀបការ មេរបស់គាត់បានឃាត់គាត់ទុកនៅក្នុងបន្ទាយ ហើយមិនអនុញ្ញាតអោយគាត់ទៅកាន់រោងការទេ។ ដូចនេះទើបប្រពន្ធរបស់គាត់បានរៀបការជាមួយសំលៀកបំពាក់របស់គាត់។[១៧]

១៧ ប្រពៃណីខ្មែរមួយដែលអនុញ្ញាតឱ្យការរៀបការជាមួយនឹងសំលៀកបំពាក់ ជំនួសការអវត្តមានរបស់អ្នករៀបមង្គលការ

ក្រោយមកខ្ញុំបានត្រលប់មកផ្ទះវិញ។ ខ្ញុំបានរងចាំប្រហែលមួយខែហើយគាត់នៅតែមិនត្រលប់មកវិញ គាត់ខឹងខ្ញុំយ៉ាងខ្លាំងដោយសារតែខ្ញុំបានបញ្ឈប់មង្គលការរបស់គាត់។ មួយខែក្រោយមកទៀត ខ្ញុំបានសុំឪពុកម្តាយក្មេករបស់ខ្ញុំទៅនៅជាមួយម្តាយរបស់ខ្ញុំ។ ខ្ញុំមានកូនបីនាក់ ហើយក៏គ្មាននរណាម្នាក់ជួយខ្ញុំថែទាំពួកគេទេ។ ម្តាយក្មេករបស់ខ្ញុំធ្លាប់បាននិយាយថា[ម៉ែមិនអាចឃាត់ឯងមិនឱ្យចាកចេញបានទេ ហើយម៉ែក៏មិនអាចសុំឱ្យឯងនៅបានដែរ ពីព្រោះម៉ែដឹងថាប្តីឯងបានធ្វើឱ្យឯងឈឺចាប់ និងមិនបានថែឯងទេ។] ឪពុកក្មេករបស់ខ្ញុំបានព្យាយាមបញ្ចុះបញ្ចូលខ្ញុំឱ្យនៅ ប៉ុន្តែ បើទោះជាគាត់បានព្យាយាមយ៉ាងណាក៏ខ្ញុំបានសំរេចចិត្តទៅហើយ។ ខ្ញុំបានសង់ផ្ទះជាប់នឹងផ្ទះឪពុកម្តាយក្មេករបស់ខ្ញុំ ហើយនៅពេលដែលខ្ញុំរុះរើវា ខ្ញុំបានយកឈើទៅសង់ឡើងវិញនៅផ្ទះម្តាយរបស់ខ្ញុំ។ ដោយសារតែខ្ញុំមិនមានយានជំនិះ កូនខ្ញុំ និងខ្ញុំបានដើរទៅកាន់ផ្ទះម្តាយខ្ញុំ។

ក្រោយពេលខ្ញុំបានស្នាក់នៅជាមួយឪពុកម្តាយខ្ញុំបានមួយខែ ខ្ញុំបានសំរេចចិត្តកំទេចផ្ទះដែលខ្ញុំបាននៅជុំគ្នាជាមួយប្តីរបស់ខ្ញុំចោល។ ម្តាយខ្ញុំបានអង្វរខ្ញុំកុំអោយកំទេចវាដោយគាត់គិតថាខ្ញុំអាចនឹងទៅរួមរស់ជាមួយប្តីរបស់ខ្ញុំវិញ ក៏ព្រោះតែយើងមានកូនបីនាក់ជាមួយគ្នា។ ប៉ុន្តែ មួយខែក្រោយមក ប្តីរបស់ខ្ញុំនៅតែមិនបានមករកខ្ញុំ ហើយខ្ញុំក៏សំរេច ចិត្តកំទេចផ្ទះនោះចោល។ រាល់ថ្ងៃខ្ញុំតែងតែយំនៅក្នុងផ្ទះនោះ។ ខ្ញុំមានកូនបីនាក់ហើយ។ ខ្ញុំបានសំរេចចិត្តដោយខ្លួនឯងថាលះលែង។ ខ្ញុំបានប្រាប់ឪពុក

របស់ខ្ញុំថា "ពុកចាំមើល ខ្ញុំនឹងមិនត្រឡប់ទៅរកប្តីខ្ញុំវិញទេ។ បើខ្ញុំបានសំរេចចិត្តថាចាកចេញគឺចាកចេញហើយ។ ខ្ញុំឆ្អែតចិត្តនឹងគាត់ហើយ ហើយខ្ញុំចង់លះលែងឥឡូវនេះ។" ពេលដែលខ្ញុំបានមករួមរស់ជាមួយម្តាយខ្ញុំវិញ ប្តីរបស់ខ្ញុំខ្លាចឪពុករបស់ខ្ញុំខ្លាំងណាស់រហូតទាល់តែគាត់មិនហ៊ានមករកខ្ញុំ។

ពេលដែលខ្ញុំគិតទៅដល់រឿងនេះ ខ្ញុំមានការឆ្អែតឆ្អន់ជាខ្លាំងគឺឆ្អែតខ្លាំងណាស់! ពេលខែភ្លៀងម្តងៗខ្ញុំបានធ្វើការនៅស្រែ ខ្ញុំគ្មានប្តីមកជួយទេ។ ខ្ញុំមានកូនតូចៗ ហើយខ្ញុំតែងតែទៅស្រែដើម្បីធ្វើស្រែ។ កាលនោះយើងមានក្របីមួយចំនួន ហើយខ្ញុំតែងតែមើលថែវាដល់ពេលយប់។ ពេលខ្ញុំត្រលប់មកពីធ្វើស្រែវិញ កូនរបស់ខ្ញុំបានដេកលក់អស់ទៅហើយ។ រាល់ពេលដែលខ្ញុំបានចំអិនអាហារឱ្យកូនរបស់ខ្ញុំ វាយប់ជ្រៅទៅហើយ។ ខ្ញុំឆ្អែតឆ្អន់ខ្លាំងណាស់ ហើយបើទោះជាមានរឿងអ្វីកើតឡើងក៏ដោយ ក៏ខ្ញុំមិនទទួលគាត់មកវិញដែរ។ ខ្ញុំគ្មានសង្ឃឹមអ្វីទៅលើប្តីរបស់ខ្ញុំទេ ហើយខ្ញុំហ៊ានចិញ្ចឹមកូនខ្ញុំដោយខ្លួនឯង។ ក្មួយដឹងទេ មុនពេលដែលគាត់បានក្លាយជាទាហ៊ានគាត់មិនអីទេ។ គាត់ជួយធ្វើស្រែចំការ ធ្វើសួរ និងជួយមើលថែកូនចៅ ។ គាត់មិនអីរហូតទាល់តែគាត់ក្លាយជាទាហ៊ាន ទើបគាត់ផ្លាស់ប្តូរ។ ពេលដែលគាត់ក្លាយជាទាហ៊ានគាត់បានចាប់ផ្តើមវាយធ្វើបាបខ្ញុំ។ ខ្ញុំបានក្លាយជាមេម៉ាយ[១៨] នៅអាយុ៣០ឆ្នាំហើយក៏មិនបានយកប្តីទៀតដែរ ។

## អញ្ចឹងមីងបានសំរេចចិត្តមិនរៀបការទៀតទេឬ?

ចាស មានអ្នកផ្សេងទៀតគេបានចូលស្តី ប៉ុន្តែខ្ញុំបានបដិសេធ។ ខ្ញុំបានសំរេចចិត្តថា នៅក្នុងមួយជីវិតគឺមានប្តីម្តងគឺវាគ្រប់គ្រាន់ហើយ។ ខ្ញុំបានឆ្អែតឆ្អន់នឹងការលំបាក ដូច្នេះហើយទើបខ្ញុំបានតាំងចិត្តថាមិនយកប្តីទៀតទេ។ ខ្ញុំខ្លាចគេធ្វើបាបកូនៗរបស់ខ្ញុំក៏ដូចជាខ្ញុំផងដែរ។ មានប្តីពីរនាក់គឺមិនងាយទេ ដូចនេះខ្ញុំមើលថែកូនៗរបស់ខ្ញុំ ហើយខ្ញុំក៏គ្មានពេលវេលាណាទៅគិតដល់ប្តីណាម្នាក់ទៀតដែរ។ ខ្ញុំឆ្អែតឆ្អន់នឹងប្តីរបស់ខ្ញុំ

ហើយគ្រាន់តែចង់មើលថែកូនៗរបស់ខ្ញុំប៉ុណ្ណោះ។ មានពេលខ្លះ ខ្ញុំមិនបានគិតថាខ្ញុំអាចចិញ្ចឹមកូនតែម្នាក់ឯងបានទេ ហើយក៏មានពេលខ្លះទៀត ខ្ញុំមិនគិតថាយើងអាចត្រដរស់បានផង។ គាត់មិនដែលមកលេងកូនទេ ក្រោយពេលយើងបានលែងលះគ្នា។

ប៉ុលពត[១៩] បានរៀបចំមង្គលការនេះ ហើយកំហុសទាំងនេះបានបំផ្លាញជីវិតរបស់ខ្ញុំ។ បច្ចុប្បន្ននេះក្មួយឃើញទេ ? ខ្ញុំមិនមានអ្វីដូចគេទេ។ ខ្ញុំមិនបានរៀបការដូចគេ។ ចំពោះកូនខ្ញុំវិញមានគេតែងតែនិយាយថា "អ្វីម្តាយឯងជាមេម៉ាយ ហើយម្តាយឯងរៀបការដោយមិនមានខាន់ស្លា។" មិនមាននរណាម្នាក់អញ្ជើញខ្ញុំឱ្យចូលរួមពិធីអ្វីទេ។ ខ្ញុំមានការខកចិត្តជាខ្លាំងក្នុងមួយជីវិតរបស់ខ្ញុំ ដោយសារតែការរៀបការពេលនោះ។ សង្គមមានការរើសអើងខ្ញុំដោយសារតែខ្ញុំជាស្ត្រីមេម៉ាយ។ ឧទាហរណ៍ដូចជា ក្នុងពិធី ប្រពៃណីមួយពេលពិធីហូបស្លានៅក្នុងពិធីមង្គលការ ពួកគេមិនបានឱ្យខ្ញុំចូលរួមទេ។ ពួកគេមិនបានអញ្ជើញស្ត្រីណាដែលជាមេម៉ាយ ឬ ក៏លះលែងប្តី ឬក៏បែកផ្លូវគ្នាក៏ដោយ។ យើងបាក់មែកបាក់ជាង មានន័យថាយើងគ្មានប្តី។ សូម្បីតែក្នុងពិធីមង្គលការកូនស្រីរបស់ខ្ញុំ ខ្ញុំមិនត្រូវបានអនុញ្ញាតឱ្យធ្វើជាមេបាឡើយ ហើយម្តាយរបស់ខ្ញុំក៏ត្រូវចូលរួមជំនួសខ្ញុំវិញ។ ទាំងកូននិងម្តាយត្រូវបានគេរើសអើងនៅក្នុងមួយជីវិត របស់យើង។ កូនស្រីរបស់ខ្ញុំមិនត្រូវបានអញ្ជើញឱ្យទៅចូលរួមធ្វើជាអ្នកកំដរ ហើយកូនប្រុសរបស់ខ្ញុំក៏អញ្ចឹងដែរ ពីព្រោះពួកគេគ្មានឪពុក។ ខ្ញុំមានសេចក្តីអាណិតអាសូរពួកគេណាស់ ហើយខ្ញុំក៏មិនចង់គិតដល់រឿង នេះដែរពីព្រោះពេលគិតដល់ម្តងៗវាធ្វើអោយខ្ញុំយំ។ ប្រសិនបើប៉ុលពតមិនបានរៀបចំឱ្យខ្ញុំរៀបការពេលនោះ ខ្ញុំប្រហែលជាត្រូវបានរៀបការជាមួយនរណាម្នាក់ផ្សេងទៀត ឬក៏មិនបានរៀបការអ្វីទាំងអស់ ឬក៏ ខ្ញុំអាចមានអាពាហ៍ពិពាហ៍តាមប្រពៃណីមួយ ហើយកូនៗរបស់ខ្ញុំក៏មានមុខមានមាត់ដូចគេដែរថ្ងៃនេះ។ ចាស ខ្ញុំបានធ្វើខុសជាមួយនឹងការរៀបការនោះ។ យើងមិនអាចធ្វើការជ្រើសរើស យើងមិនបានស្គាល់គ្នាជាមុន ហើយខ្ញុំក៏មិនបានដឹងអំពីសាវតារបស់ប្តីខ្ញុំដែរ ។ យើងមិនបាន

១៨
សូមមើលសទ្ទានុក្រម "មេម៉ាយ"

១៩
សូមមើលសទ្ទានុក្រម "ប៉ុលពត"

ដឹងអំពីអ្វីពីគ្នាទៅវិញទៅមកនោះទេ។

**តើមីងអាចរៀបរាប់អំពីការបីបាច់ថែទាំកូនៗរបស់មីងម្នាក់ឯងបានទេ?**

ខ្ញុំបានយកកង់ចាស់របស់ខ្ញុំមួយដើរប្រមូលគ្រឿងទេស និងគ្រឿងផ្សំ
ផ្សេងៗយកទៅលក់នៅទីក្រុងភ្នំពេញ។ ខ្ញុំរកលុយបានជាច្រើនអំពីមុខ
របរមួយនេះដោយគ្រប់គ្រាន់នឹងបញ្ជូនកូនខ្ញុំទៅរៀនបាន។ វាមានការ
លំបាកណាស់ ប៉ុន្តែខ្ញុំចង់ឱ្យកូនៗរបស់ខ្ញុំមានចំណេះដឹង។ ពួកគេបាន
ជាប់វិទ្យាល័យទាំងអស់គ្នា។ កូនស្រីរបស់ខ្ញុំបានរៀបការក្រោយពេល
នាងបានបញ្ចប់វិទ្យាល័យ ហើយកូនប្រុសរបស់ខ្ញុំឥឡូវកំពុងតែបន្តការ
សិក្សានៅភ្នំពេញ។ មានកូនប្រុសៗល្អបែបនេះគឺខ្ញុំមានសំណាងខ្លាំង
ណាស់ ពួកគេមិនបានបង្កឱ្យមានបញ្ហាអ្វីទេ។ ពួកគេជាកូនល្អ។ ឥឡូវ
ពេលដែលគេបានធំៗបែបនេះ ខ្ញុំក៏មិនចាំបាច់ធ្វើការធ្ងន់ដូចមុនទេ
ហើយខ្ញុំសង្ឃឹមថាពួកគេនឹងជួយខ្ញុំវិញពេលដែលខ្ញុំមិនអាចធ្វើការតទៅ
ទៀតបាន។ ខ្ញុំឃើញក្មេងផ្សេងៗទៀត ដែលមានឪពុកជួយទំនប់បំរុង
ពួកគេមានភាពងាយស្រួលច្រើនជាងកូនៗរបស់ខ្ញុំ។ ប្រពន្ធទាំងនោះ
ដែលគេមានប្ដីពួកគេអាចជួយគិតគ្នាដោះស្រាយបញ្ហាទាំងឡាយ សំរាប់
ខ្ញុំវិញខ្ញុំធ្វើការសំរេចចិត្ត ដោះស្រាយរាល់បញ្ហាដោយខ្លួនឯង។ បើសិនខ្ញុំ
មិនរកវិធីដោះស្រាយទេគ្មានអ្នកណាគេជួយខ្ញុំដោះស្រាយនោះទេ។
ប៉ុន្តែខ្ញុំក៏បានឃើញថាមានស្ដ្រីមេម៉ាយខ្លះក៏មិនអាចមានលទ្ធភាពទំនប់
បំរុងកូនៗរបស់ពួកគេដែរ។ ខ្ញុំមានមោទនភាពចំពោះខ្លួនឯងដែល ខ្ញុំ
អាចបីបាច់ចិញ្ចឹមកូនៗឱ្យបានទៅសាលា មានការងារ និងរកចំណូល
បាន។ ខ្ញុំមិនមានមោទនភាពអ្វីណាស់ណាទេ ប៉ុន្តែខ្ញុំកោតសរសើរខ្លួន
ឯង។ សូម្បីតែអ្នកភូមិជាមួយខ្ញុំក៏សរសើរខ្ញុំថា "អ៊ូ ឯងជាស្ដ្រីមេម៉ាយ
ប៉ុន្តែកូនៗឯងជាកូនល្អដែលស្ដាប់បង្គាប់ម្ដាយ។" ដូច្នេះហើយការខំប្រឹង
ប្រែងរបស់ខ្ញុំមិនឥតប្រយោជន៍នោះទេ ហើយកូនៗ របស់ខ្ញុំក៏ល្អជាងកូន
អ្នកដទៃដែរ។

# ករណីសិក្សា ៩

បស ភេទស្រី អាយុ ៥៣ឆ្នាំ
សំភាសន៍នៅថ្ងៃទី ២៥ មេសា ២០១៤
នៅទីក្រុងភ្នំពេញ នៅអង្គការចិត្តសង្គមអន្តរវប្បធម៌កម្ពុជា។

**តើជីវិតរបស់មីងយ៉ាងណាដែរមុនរបបខ្មែរក្រហមកាន់អំណាច?**

គ្រួសាររបស់ខ្ញុំទាំងអស់—មានយាយតា មីងពូ រស់នៅក្បែរផ្សារ xx ក្នុងទីក្រុងភ្នំពេញ។ គ្រួសារខ្ញុំភាគច្រើនជាទាហ៊ាន។ ពូរបស់ខ្ញុំជាអនុសេនីយ-ឯក ហើយឪពុករបស់ខ្ញុំជាអនុសេនីយទោ។ នៅជំនាន់លន់នល់[២០] ឪពុករបស់ខ្ញុំនិងគ្រួសាររបស់ខ្ញុំត្រូវបានជំលៀសទៅរស់នៅកំពង់ឆ្នាំង ដើម្បីវាយតតាំងនឹងទាហានខ្មែរក្រហម។ នៅពេលខ្មែរក្រហមវាយឈ្នះសង្គ្រាមស៊ីវិល គ្រួសារខ្ញុំបានប្តូរទៅរស់នៅខេត្ត xx។ កម្មាភិបាលខ្មែរក្រហមបានប្រកាសថា អ្នកដែលធ្លាប់ធ្វើទាហានលន់នល់គួរស្លៀកពាក់ជាឯកសណ្ឋានទាហាន ហើយមករោងប្រជុំ។ បានឮដូច្នេះ ឪពុករបស់ខ្ញុំបានស្លៀកពាក់រួចទៅបង្ហាញខ្លួននៅកន្លែង។ ពេលនោះហើយដែលគាត់ត្រូវបានគេយកទៅហើយសំលាប់។ ខ្ញុំមិនបានដឹងពីទីកន្លែងដែលគេសំលាប់គាត់ទេ ឬរណ្តៅណាមួយដែលគេកប់គាត់នោះទេ ពីព្រោះខ្ញុំនៅក្មេងណាស់ពេលនោះ។ ខ្ញុំប្រហែលជាអាយុ១១ឬ១២ឆ្នាំពេលខ្មែរក្រហមកាន់អំណាច ហើយខ្ញុំរស់នៅជាមួយកងកុមារ។ ខ្ញុំត្រូវបានគេចាត់ទុកជាប្រជាជន"១៧ មេសា"។[២១] ខ្ញុំមានអាយុប្រហែលជា១៤ឆ្នាំពេលខ្ញុំត្រូវបានគេបង្ខំអោយរៀបការ។

ខ្ញុំមិនបានដឹងថាខ្ញុំនឹងត្រូវគេឱ្យរៀបការនោះទេ។ មិនមាននរណាម្នាក់ប្រាប់ខ្ញុំនោះទេ។ ថ្ងៃនោះខ្ញុំកំពុងកាន់បង្គីសែងអាចម៍គោចាក់ស្រែ ហើយមិនមានអ្នកប្រាប់ខ្ញុំទេ "អ៊ូ និយាយអញ្ចឹងបន្ទាប់ពីធ្វើការរួចថ្ងៃនេះ មិត្តត្រូវរៀបការ"។ ទោះបីជាមេក្រុមក្នុងសហកររបស់ខ្ញុំក៏ហាក់ដូចជា មិនបានដឹងមុនដែរ។ ខ្ញុំបានឃើញមេក្រុមពីក្រុមបុរសមកវាលជិះសេះហើយ

២០
សូមមើលសទ្ទានុក្រម "លន់ នល់"

២១
សូមមើលសទ្ទានុក្រម "អ្នកថ្មី"

ពិភាក្សាគ្នាជាមួយមេក្រុមរបស់ខ្ញុំ "យើងមិនចាំបាច់ឱ្យគេសំរាកពេញមួយថ្ងៃដើម្បីរៀបការទេ។ អោយពួកគេធ្វើការដូចសព្វដង ហើយយើងនឹងរៀបចំពិធីរៀបការបន្ទាប់ពីធ្វើការរួច"។ គេបានឃើញខ្ញុំឮគេនិយាយ ហើយគេក៏បញ្ជាឱ្យខ្ញុំត្រឡប់ទៅធ្វើការវិញ។

ពេលមួយតាមផ្លូវទៅវាលស្រែ ខ្ញុំបានឃើញគេកំពុងសំលាប់មនុស្សម្នាក់។ បុរសនោះ ត្រូវបានគេចាក់នឹងកាំបិត ហើយខ្ញុំតក់ស្លុតណាស់ខ្ញុំខំរត់ទៅកន្លែងធ្វើការ។ បន្ទាប់មក កម្មាភិបាលបានហៅខ្ញុំពីវាលស្រែ។ គាត់បាននិយាយថា "តើមិត្តបានឃើញអ្វីខ្លះដែរ ឬទេ?" ខ្ញុំឆ្លើយតបថា "ទេ ខ្ញុំគ្រាន់តែដើរកាត់មិត្តបងតែមិនបានឃើញអ្វីទេ" គាត់និយាយថា "ខ្ញុំនឹងនាំមិត្តឯងទៅដើមឈើហើយសំលាប់មិត្តឯង ឬខ្ញុំនឹងបង្ខំមិត្តអោយរៀបការហើយសំលាប់មិត្តឯងចោល" [ប្រសិនបើមិត្តឯងបានឃើញ]!"

## តើពេលណាមីងបានដឹងថាមីងត្រូវបានគេឱ្យរៀបការ?

ថ្ងៃដែលខ្ញុំបានឃើញអ្នកគ្រប់គ្រងសហករពីរនាក់និយាយគ្នានៅវាលស្រែ។ ខ្ញុំបានធ្វើការចប់ ខ្ញុំបានទៅរោងបាយ ប៉ុន្តែមិនមានបាយសំរាប់ខ្ញុំហូបទេ។ ខ្ញុំសួរកម្មាភិបាលនៅទីនោះហេតុអ្វីបានជាមិនមានបាយសំរាប់ខ្ញុំហូប ហើយខ្ញុំត្រូវបានគេប្រាប់ថា បាយរបស់ខ្ញុំត្រូវបានគេរៀបចំនៅកន្លែងផ្សេង ពីព្រោះខ្ញុំនឹងត្រូវរៀបការ។ ខ្ញុំឃើញមនុស្សដើរចូលក្នុងរោងប្រជុំជាគូៗ ហើយខ្ញុំក៏សួរមេក្រុមរបស់ខ្ញុំថា "មិត្តបង តើមានអ្វីកើតឡើងនៅទីនោះ។" គាត់បានឆ្លើយថា "មិត្តឯងក៏ត្រូវទៅទីនោះជាមួយគេដែរ។" ពេលខ្ញុំ សួរថាហេតុអ្វី គាត់បានឆ្លើយថា "ពេលមិត្តទៅទីនោះមិត្ត នឹងមានរបស់ហូបឆ្អែត។" ខោអាវរបស់ខ្ញុំចាស់ហើយកខ្វក់ដោយសារធ្វើការពីថ្ងៃ។ មេក្រុមនៅក្នុងសហកររបស់ខ្ញុំ និយាយថា "ប្តូរខោអាវសិនទៅ" ហើយបន្ទាប់មកគាត់ដោះសំពត់ [សំពត់ប្រពៃណីខ្មែរ] ដែលគាត់កំពុងតែស្លៀកចេញហើយយកមកពាក់ឱ្យខ្ញុំ។ វាធំជាងខ្លួនខ្ញុំ ដូច្នេះខ្ញុំក៏យកខ្សែក្រវ៉ាត់ដែលម្តាយខ្ញុំទុកឱ្យខ្ញុំមកពាក់ ប៉ុន្តែពេលកម្មាភិបាលម្នាក់ទៀតបានឃើញគាត់ក៏យកខ្សែក្រវ៉ាត់នោះពីខ្ញុំ។ ខ្ញុំសុំឱ្យគាត់ប្រគល់ខ្សែ

ក្រវាត់នោះមកខ្ញុំវិញ តែផ្ទុយទៅវិញគាត់បានយកវាមកវាយខ្ញុំ ២ទៅ ៣ដង។

នៅរោងប្រជុំពេលបានឃើញមនុស្សកាន់ដៃគ្នា ខ្ញុំបានព្យាយាមរត់ចេញ តែមេកងបានបាញ់កាំភ្លើងឡើងលើ។ គេបានប្រាប់ខ្ញុំថា "ទុកក៏មិន ចំណេញដកចេញក៏មិនខាត"។[២២] ខ្ញុំត្រូវបានគេបញ្ជាឱ្យអង្គុយទល់មុខប្ដី របស់ខ្ញុំ ប៉ុន្តែខ្ញុំមិនស្គាល់គាត់ទេ គាត់ចាស់ជាងខ្ញុំច្រើន គាត់អាយុ២៨ឆ្នាំ ឬ២៩ឆ្នាំហើយមានមាឌធំ។ ខ្ញុំមិនហ៊ានមើលមុខគាត់ទេ។ គេបានបញ្ជា ឱ្យយើងមើលមុខគ្នាហើយចាប់ដៃ ពេលនោះខ្ញុំបានប្រកែក ដូច្នេះគេក៏ យកកាំភ្លើងមកគំរាមខ្ញុំម្ដងទៀត។ "ហេតុអ្វីបានជាមិត្តបំផ្លាញគំរោង របស់យើង! មិត្តនឹងមិនមានអ្វីហូបទេ!" គេបានស្រែកថាឱ្យខ្ញុំ។ ខ្ញុំយំ ហើយអង្វរគេថា "ខ្ញុំនៅក្មេងណាស់ហើយមិនទាន់គ្រប់ការនឹងរៀបការ ទេ!"[២៣] ខ្ញុំមិនបានយល់ថាអ្វីជាស្នេហានោះទេ ហើយខ្ញុំមិនមានម្ដាយ នៅជួយពន្យល់ពីអ្វីៗដល់ខ្ញុំ គ្មានឪពុកម្ដាយថែរក្សា និងការពារខ្ញុំនោះ ទេ។

ពូរបស់ខ្ញុំនៅទីនោះដែរ។ គាត់បានស្រឡាញ់ស្ត្រីម្នាក់ហើយពួកគេបាន ស្នើសុំទៅអង្គការដើម្បីរៀបការ ហើយគាត់បានរៀបការពេលជាមួយខ្ញុំ ដែរ។ ពេលដែលខ្ញុំតវ៉ាមិនព្រមរៀបការ គាត់បានក្ដិចចង្កេះរបស់ខ្ញុំរួច ខ្សឹបខ្ញុំថា "ឯងត្រូវនៅអោយស្ងៀម ហើយស្ងាត់។ ប្រសិនបើឯងតវ៉ា ឯង នឹងត្រូវគេសំលាប់ហើយ!"។ មាន១៣គូដែលរៀបការនាពេលនោះ។ កម្មាភិបាលម្នាក់ៗបានដាក់វេនគ្នានិយាយ ហើយគេបញ្ជាឱ្យយើងថា តាមគេនិយាយឱ្យសន្យានឹងគ្នាទៅវិញទៅមកនិងបង្កើតកូនជូនអង្គការ។ ខ្ញុំព្យាយាមតវ៉ាម្ដងទៀតតែមេកងបាននិយាយថា "តើមិត្តឯងចង់ឱ្យខ្ញុំ វាយមិត្តឯងនឹងកាំភ្លើងរបស់ខ្ញុំមែនទេ?" ដូច្នេះខ្ញុំក៏យល់ព្រម។

[បន្ទាប់ពីរៀបការរួច] គេបាននាំយើងទៅផ្ទះដែលមានបន្ទប់តូចមួយ—អ្វី ខ្ញុំមិនចង់និយាយពីវានោះទេ! មានបន្ទប់ជាប់ៗគ្នាហើយជញ្ជាំងស្បូវ។ រយៈពេល៣យប់ដែលប្ដីរបស់ខ្ញុំបានព្យាយាមបង្ខំឱ្យខ្ញុំរួមភេទជាមួយ

២២
ពាក្យនិយាយទូទៅ មួយរបស់ អង្គការ

២៣
គាត់មិនទាន់ចាប់ផ្ដើម មានរដូវនៅឡើយទេ [Ed.].

គាត់ ប៉ុន្តែខ្ញុំតដៃ។ គាត់បានព្យាយាមដោះសំលៀកបំពាក់ខ្ញុំ ប៉ុន្តែខ្ញុំតដៃវិញ ខ្ញុំបានធាក់គាត់ពេលគាត់បានព្យាយាមដោះសំលៀកបំពាក់ខ្ញុំ។ វិធីនេះខ្ញុំអាចការពារខ្លួនខ្ញុំបានហើយយប់ដំបូងបានរំលងផុត។ ប៉ុន្តែខ្ញុំមិនបានដេកគ្រប់គ្រាន់ទេ។ ខ្ញុំបានភ្ញាក់ម៉ោង៣ភ្លឺដើម្បីទៅធ្វើការមុនពេលប្តីខ្ញុំភ្ញាក់ពីដេក។ ពេលមេកងឃើញខ្ញុំខំប្រឹងធ្វើការ គេនិយាយថា "មិត្តឯងជាក្មេងស្រីឆ្លាតជួយ*អង្គការ*។

ពេលយប់ទី៣ ខ្ញុំរត់ទៅនៅសហករមួយទៀត ប៉ុន្តែឈ្លបបាននាំប្តីរបស់ខ្ញុំទៅរកខ្ញុំ។ អ្នកយាមបាននិយាយថា ជិតមួយអាទិត្យទៅហើយយើងនៅមិនទាន់រួមដំណេកនឹងគ្នាទៀត ដូច្នេះយប់នេះយើងត្រូវតែរួមភេទ។ ខ្ញុំមិនព្រមទេ។ ខ្ញុំបាននិយាយថាខ្ញុំមិនខ្វល់ថាខ្ញុំត្រូវគេសំលាប់នោះទេ ខ្ញុំនឹងមិនព្រមដាដាច់ខាត។ មានអ្នកយាម២នាក់ ទាំង២នាក់នោះជាស្ត្រី ហើយម្នាក់ក្នុងចំនោមគេទាំង២នៅរស់ទល់សព្វថ្ងៃ។ គេបានចាប់ចងជើងខ្ញុំហើយដៃរបស់ខ្ញុំទៅនឹងគ្រែហើយគេដើរចេញពីគ្រែ។ ហើយអាប្តីចុយម៉ាយនោះបានរំលោភខ្ញុំ វាបានហែកខោរបស់ខ្ញុំ ហើយអ្នកយាមទាំង២នោះឈរនៅទីនោះហើយមើល។ ប្តីរបស់ខ្ញុំបានរំលោភខ្ញុំ ហើយធ្វើតាមអំពើចិត្តមកលើខ្ញុំ។ គាត់បានហែកខោខ្ញុំ អាវរបស់ខ្ញុំ។ ខ្ញុំមានអារម្មណ៍ខ្មាស់ណាស់។ ពូរបស់ខ្ញុំបាននៅបន្ទប់ក្បែរខ្ញុំ គាត់បានឃើញអ្វីៗដែលបានកើតមានលើខ្ញុំ ហើយគាត់គ្រាន់តែគ្រវីក្បាលរបស់គាត់។ គាត់មិនអាចទ្រាំមើលបានទេ ប៉ុន្តែគាត់មិនអាចធ្វើអ្វីបានទាំងអស់។ បន្ទាប់ពី[ប្តីរបស់ខ្ញុំ] បានរំលោភខ្ញុំគាត់មិនព្រមដោះលែងខ្ញុំទេ គាត់នៅចង់ចងខ្ញុំទុកពីព្រោះគាត់នៅចង់រំលោភខ្ញុំម្តងទៀត។ ខ្ញុំយំស្រែកឱ្យជួយ ហើយអង្វរគាត់ "សូមកុំធ្វើដូច្នេះអី!" ប៉ុន្តែ [ប្តីរបស់ខ្ញុំ] បាននិយាយថាគាត់មិនអាចជួយខ្ញុំបានទេពីព្រោះគាត់ត្រូវតែធ្វើតាមអង្គការ។ គេបាននិយាយថារៀបការឱ្យយើងដើម្បីបង្កើតកូនអោយ*អង្គការ*។

ប្រដាប់ភេទរបស់ខ្ញុំហូរឈាមពីព្រោះតែការរំលោភនោះ។ ខ្ញុំបានរត់គេចទៅរកម្តាយឱ្យជួយ ប៉ុន្តែម្តាយរបស់ខ្ញុំមិនបានដឹងថាត្រូវជួយបែបណា

នោះទេ។ មានពេទ្យម្នាក់រស់នៅក្បែរម្ដាយខ្ញុំ គាត់បានប្រាប់ខ្ញុំឱ្យផឹកថ្នាំឫសឈើដើម្បីបញ្ឈប់ការហូរឈាម។ បន្ទាប់មកម្ដាយខ្ញុំបានសុំអោយ ខ្ញុំចាកចេញ ព្រោះគាត់ខ្លាចនាំមកនូវគ្រោះថ្នាក់ដល់ គ្រួសារទាំងមូល ពេលគេចាប់បានខ្ញុំនៅផ្ទះគាត់។ បងប្អូនរបស់ខ្ញុំនៅតូចៗ ហើយខ្ញុំខ្លាចគេនឹងសំលាប់ខ្ញុំ ដូច្នេះខ្ញុំក៏ចាកចេញ។ បន្ទាប់ពីយប់នោះមក ពូរបស់ខ្ញុំបានព្យាយាមនិយាយជាមួយប្ដីរបស់ខ្ញុំ។ គាត់និយាយថា ខ្ញុំនៅក្មេងណាស់ក្នុងការរួមភេទ ហើយប្ដីរបស់ខ្ញុំគួរតែរង់ចាំដល់ពេលខ្ញុំធំ។ គាត់បានព្យាយាមនិយាយនឹងប្ដីរបស់ខ្ញុំអោយខ្ញុំដេកជាមួយប្រពន្ធរបស់គាត់ ហើយគាត់មកដេកជាមួយនឹងប្ដីរបស់ខ្ញុំ។ ដោយសារតែខ្ញុំនៅហូរឈាមនៅឡើយ ហើយប្ដីរបស់ខ្ញុំក៏យល់ព្រម។ យប់ទាំងនោះខ្ញុំដេកលក់ស្រួលណាស់។ នៅពេលនោះខ្ញុំមិនទាន់គ្រប់ការនៅឡើយទេ ដោយសារតែខ្ញុំនៅក្មេងហើយខ្ញុំស្គមណាស់ពីព្រោះមិនមានអ្វីហូបគ្រប់គ្រាន់។ ខ្ញុំមិនមានរដូវរហូតដល់ចុងឆ្នាំ១៩៧៩។ ខ្ញុំបានរៀបការ៤ទៅ៥ខែមុនវៀតណាមចូលស្រុក។

> *"អ្នកយាមបាននិយាយថា ជិតមួយអាទិត្យទៅហើយយើងនៅមិនទាន់រួមដំណេកនឹងគ្នាទៀត ដូច្នេះយប់នេះយើងត្រូវតែរួមភេទ។ ខ្ញុំ មិនព្រមទេ។ ខ្ញុំបាននិយាយថា ខ្ញុំមិនខ្វល់ថាខ្ញុំត្រូវគេសំលាប់នោះទេ ខ្ញុំនឹងមិនព្រមជាដាច់ខាត។*

## តើយូរប៉ុណ្ណាដែលពូរបស់មីងបានជួយមីង?

បន្ទាប់ពីបានមួយអាទិត្យនៅជាមួយពូរបស់ខ្ញុំនិងប្រពន្ធគាត់ ពូរបស់ខ្ញុំបាននិយាយថា គាត់មិនអាចបន្តជួយខ្ញុំបានទៀតទេ ដូច្នេះខ្ញុំបានរត់គេចទៅនៅភូមិមួយទៀត។ ខ្ញុំបានជួប xx ហើយខ្ញុំបានសុំគាត់រករបស់ហូបពីព្រោះខ្ញុំឃ្លានណាស់។ ខ្ញុំមិនហ៊ានត្រឡប់ទៅក្រុមវិញទេ ពីព្រោះខ្ញុំខ្លាចថានឹងជួបប្ដីរបស់ខ្ញុំ។ មេកងបានមកតាមរកខ្ញុំពេលខ្ញុំរត់គេច។ ដូច្នេះខ្ញុំលាក់ខ្លួនក្នុងព្រៃពេលថ្ងៃហើយចេញមកភូមិពេលយប់។ ប្ដីរបស់ខ្ញុំតាមរកខ្ញុំ ហើយសុំឱ្យគេឯងជួយរកខ្ញុំដែរ។ ខ្ញុំខ្លាចជួបប្ដីខ្ញុំណាស់ ខ្ញុំដេកក្នុងព្រៃ ពេលខ្លះដេកជិតសាកសពហើយខ្ញុំមិនខ្វល់ពីសត្វខ្លាស៊ីខ្ញុំនោះទេ។ ខ្ញុំស្អប់ប្ដីរបស់ខ្ញុំណាស់ ហើយខ្ញុំគ្មានផ្លូវនឹងស្រឡាញ់គាត់នោះ

ទេ ពីព្រោះគាត់ធ្វើអាក្រក់ដាក់ខ្ញុំណាស់។ ពេលយប់ដែលគាត់រំលោភខ្ញុំ ខ្ញុំត្រូវបានគេចង ខ្ញុំវាយគាត់តែគាត់បានទះកំផ្លៀងខ្ញុំ។ តើគាត់ជាប្តីខ្ញុំដោយរបៀបណាដែលគាត់ធ្វើដាក់ខ្ញុំបែបនេះ? ប្រសិនបើគាត់ស្រឡាញ់ខ្ញុំ គាត់មិនធ្វើតាមឈ្លបបញ្ជាហើយរំលោភខ្ញុំនោះទេ។ ខ្ញុំមិនបានស្គាល់សូម្បីតែឈ្មោះរបស់គាត់រហូតដល់២ឬ៣ឆ្នាំមុននេះ។

### តើមីងបានដឹងថាតើហេតុអ្វីបានជាខ្មែរក្រហមបង្ខំមនុស្សឱ្យរៀបការដែរឬទេ?

ខ្ញុំមិនបានដឹងទេ ខ្ញុំមិនដឹងតើគេបានគិតអ្វីនោះទេ។ គេមិនបានឱ្យតំលៃស្ត្រីដូចជាបងប្អូនស្រីរបស់គេឬជាម្តាយរបស់គេនោះទេ គេមិនចាត់ទុកស្ត្រីជាតំលៃរបស់សង្គមនោះទេ។ មនុស្សដែលរៀបការពេលនោះ ប្រៀបបាននឹងសត្វ។ គ្មានបុរសនិងស្ត្រីណាមានតំលៃជាមនុស្សនោះទេ។ យើងមិនត្រូវបានគេអនុញ្ញាតឱ្យការពារខ្លួនប្រាណរបស់យើង [ពីការរួមភេទ] ហើយឪពុកម្តាយរបស់យើងមិនបាននៅក្បែរយើងដើម្បីការពារយើងនោះទេ។ ខ្ញុំត្រូវបានគេរំលោភហើយគេឈរមើល។ ខ្ញុំនៅតែតក់ស្លុតដោយសារតែរឿងនេះ។ ស្ត្រីត្រូវបានគេចាត់ទុកដូចឆ្កែដូចឆ្មា។ ពេលខ្ញុំចងចាំពីពេលនោះ មាត់របស់ខ្ញុំស្ងួតហើយបេះដូងរបស់ខ្ញុំលោតញាប់។

មានថ្ងៃមួយខ្ញុំទៅវត្តកាន់ម្ហូបទៅប្រគេនលោក ពេលខ្ញុំទៅបានឃើញមនុស្សដែលបានធ្វើរឿងនេះមកលើខ្ញុំ ហើយខ្ញុំបានទំលាក់ចានស្រាក់ចុះពីដៃ។ អ្នកដែលបានធ្វើអាក្រក់មកលើខ្ញុំ ឥឡូវនេះបានព្យាយាមមកធ្វើបុណ្យតាមរយៈការមកវត្ត។[២៤] ខ្ញុំខឹងខ្លាំងណាស់ ហើយខ្ញុំគេចមិនទៅវត្តនោះទៀត។ គេគឺជាប្អូនស្រីរបស់ប្តីដែលរំលោភខ្ញុំ និងឈ្លបដែលឈរមើលគេរំលោភខ្ញុំ។

### តើមីងរស់នៅជាមួយអ្នកណាបន្ទាប់ពីរបបខ្មែរក្រហម?

ខ្ញុំរស់នៅជាមួយម្តាយ។ ប្តីរបស់ខ្ញុំមិនដែលព្យាយាមរកខ្ញុំនោះទេ។ ខ្ញុំបានជួបគាត់ម្តងតាមផ្លូវ។ គាត់នៅជាមួយប្រពន្ធថ្មីរបស់គាត់។ ខ្ញុំមិនចង់ជួបគាត់ទេពីព្រោះខ្ញុំមានអារម្មណ៍ខ្មាស់ណាស់។

## ហេតុអ្វីបានជាមីងមានអារម្មណ៍ខ្មាស់?

ពេលរបបខ្មែរក្រហមចប់ បុរសម្នាក់និងខ្ញុំបានស្រឡាញ់គ្នា។ គាត់បានសុំម្ដាយរបស់គាត់ឱ្យមកនិយាយជាមួយម្ដាយរបស់ខ្ញុំដើម្បីពិភាក្សាគ្នារឿងរៀបការ។ ប៉ុន្តែពេលម្ដាយគាត់ជួបម្ដាយខ្ញុំហើយបានដឹងពីអតីតកាលរបស់ខ្ញុំ គាត់បានខ្សឹបទៅកាន់កូនប្រុសគាត់ថា "អ៊ូ នាងបានរៀបការម្ដងរួចហើយនារបបខ្មែរក្រហមកូន។ នាងគឺជាស្ត្រីមេម៉ាយ[២៥] ដូច្នេះម្ដាយមិនយល់ស្របឱ្យកូនរៀបការជាមួយនាងនោះទេ"។ គាត់បានព្យាយាមនិយាយជាមួយម្ដាយគាត់ ហើយគាត់មិនខ្វល់ថាខ្ញុំជាស្ត្រីមេម៉ាយនោះទេ គាត់ចង់រៀបការជាមួយខ្ញុំ ប៉ុន្តែម្ដាយគាត់មិនព្រម។ គាត់បានសុំខ្ញុំឱ្យពង្រត់គ្នានឹងគាត់ ប៉ុន្តែខ្ញុំគិតថាក្នុងរបបខ្មែរក្រហម ខ្ញុំបានរងការឈឺចាប់ច្រើនណាស់រួចមកហើយ ហើយឥឡូវនេះបើខ្ញុំពង្រត់គ្នា ខ្ញុំនឹងខូចកិត្តិយសគ្រួសារ។ បន្ទាប់មកគាត់បានរៀបការនឹងស្រីផ្សេងទៀត ហើយខ្ញុំបានត្រឹមតែយំម្នាក់ឯង។

ឃើញទេ ទោះបីរបបខ្មែរក្រហមបានកន្លងផុតទៅក៏ដោយ ភាពអាម៉ាស់នៅតែនៅជាមួយខ្ញុំរហូត។ បន្ទាប់ពីការចូលស្ដីរៀបការនោះមក ខ្ញុំបានសំរេចចិត្តលាក់រឿងអតីតកាលរបស់ខ្ញុំពីមនុស្សគ្រប់គ្នា។ សូម្បីតែកូនរបស់ខ្ញុំក៏មិនបានដឹងពីរឿងនេះដែរ។ ឧទាហរណ៍៖ ពេលខ្ញុំទៅលក់ត្រកួននៅផ្សារ ខ្ញុំព្យាយាមគេចមិនមើលអ្នកណាដែលឆ្លងកាត់សម័យនោះទេ។ ខ្ញុំមានអារម្មណ៍ខ្មាស់ណាស់។ ខ្ញុំស្រម៉ៃថា បើសិនខ្ញុំត្រូវបានគេសួរថា "តើប្ដីរបស់ឯងពីរបបខ្មែរក្រហមនៅទីណា?" ខ្ញុំនឹងតបថា "មិនដឹងសួរអីអញ្ចឹងទេ? ពីព្រោះវាជារឿងគួរអោយខ្មាស់ណាស់" មានមនុស្សច្រើនណាស់ដែលដឹងរឿងរបស់ខ្ញុំដោយសារតែបន្ទប់របស់យើងនាពេលនោះនៅជិតៗគ្នា [នៅក្នុងផ្ទះរៀបការ]។ ខ្ញុំគេចចេញពីផ្សារ ពីព្រោះខ្ញុំក្ដុកក្ដួលក្នុងការប្រឈមមុខនឹងពួកគេពេក ហើយខ្ញុំទៅលក់នៅផ្សារ xx វិញពីព្រោះមនុស្សនៅទីនោះមិនស្គាល់ខ្ញុំ ហើយគេមិនសួរខ្ញុំ។ ជីវិតរបស់ខ្ញុំមិនដូចអ្នកដទៃនោះទេ ហើយខ្ញុំមានអារម្មណ៍ខ្មាស់ហួសពីការពណ៌នា។ ស្ត្រីខ្លះដែលនៅក្នុងក្រុមជាមួយគ្នាមានជីវិតអាពាហ៍ពិពាហ៍

២៤ ការអនុវត្តបែបព្រះពុទ្ធសាសនាក្នុងប្រទេសកម្ពុជា ដែលមនុស្សអាចបានបុណ្យសំរាប់ជាតិមុខ តាមរយៈការធ្វើចង្ហាន់ទៅប្រគេនព្រះសង្ឃ [Ed.].

២៥ សូមមើលសទ្ទានុក្រម "មេម៉ាយ"

យ៉ាងសប្បាយរីករាយជាមួយប្តីរបស់គេពីរបបនោះ។

ពេលវៀតណាមដកទ័ពចេញពីប្រទេស[ក្នុងឆ្នាំ១៩៨៩] មានទាហ៊ាន ម្នាក់ស្រឡាញ់ខ្ញុំ។ ឪពុកម្តាយរបស់គាត់បានមកនិយាយជាមួយម្តាយ របស់ខ្ញុំ។ គាត់ជាពោះម៉ាយដែរ ហើយមានកូនម្នាក់។ ខ្ញុំព្រមរៀបការ ជាមួយគាត់ពីព្រោះខ្ញុំគិតថាយើងទាំងពីរដូចគ្នា ហើយគាត់មិមើលងាយ ខ្ញុំ។ ខ្ញុំបានឮចាស់ៗមកនិយាយជាមួយម្តាយខ្ញុំថា ខ្ញុំគួរតែមានការរៀប ការតាមប្រពៃណីដើម្បីដោះស្រាយបញ្ហារបស់ខ្ញុំ។ ប៉ុន្តែជីវិត គឺមិនបាន ប្រសើរទេជាមួយនឹងប្តីទី២របស់ខ្ញុំ។ គាត់មានស្រីច្រើនណាស់ ហើយ គាត់បានវាយធ្វើបាបខ្ញុំ ហើយគាត់បានបង្ខំអោយខ្ញុំរួមភេទជាមួយគាត់។

ពេលនោះយើងគ្មានការពន្យារកំនើតនោះទេ ដូច្នេះខ្ញុំមិនមានសិទ្ធិក្នុង ការនិយាយឬសំរេចនោះទេ ខ្ញុំមិនដឹងថាហេតុអ្វីគាត់បង្ខំខ្ញុំអោយរួមភេទ នឹងគាត់ទេ។ អ្វីដែលខ្ញុំចង់បានគឺសុភមង្គលក្នុងគ្រួសារ ដូច្នេះខ្ញុំមិន និយាយអ្វីទាំងអស់អំពីអំពើហិង្សារបស់គាត់មកលើខ្ញុំ។ ខ្ញុំព្យាយាមរក ប្រាក់សំរាប់កូនទៅសាលា។ គាត់មិនបានជួយខ្ញុំរកប្រាក់នោះទេ គាត់ ចាកចេញពីផ្ទះរយៈពេលយូរហើយត្រឡប់មកវិញមួយរយៈនៅផ្ទះបាន តែ២ទៅ៣ថ្ងៃ។ គាត់ជាទាហានហើយមានស្រីច្រើនណាស់ជុំវិញ ប្រទេស។ ប្រសិនបើចង់ដឹងសូមសួរមនុស្សនៅក្នុងភូមិអំពីការលំបាក របស់ខ្ញុំ ដែលមានក្នុងជីវិតនេះ។ វាមិនស្រួលទាល់តែសោះ។ ប្តីទី២របស់ ខ្ញុំមិនបានចាត់ទុកខ្ញុំដូចជាប្រពន្ធល្អម្នាក់ទេ។ ប៉ុន្តែខ្ញុំមានផ្ទៃពោះដើមឆ្នាំ មួយ និងចុងឆ្នាំមួយ។ ខ្ញុំធ្វើការហត់ណាស់នៅវាលស្រែរហូតដល់ស្បូន របស់ខ្ញុំស្រុត [ការស្រុតស្បូន][២៦] បន្ទាប់ពីមានកូនច្រើនពេក។

ប្តីទី២របស់ខ្ញុំបានរត់ទៅជាមួយស្រីម្នាក់ទៅទល់ដែនថៃ[២៧] ហើយមិន ត្រឡប់មកវិញទេ។ កូនៗរបស់ខ្ញុំបានឃើញក្មេងៗផ្សេងទៀតមានឪពុក មករកពួកគេ ប៉ុន្តែប្តីរបស់ខ្ញុំមិនបានត្រឡប់មករកពួកយើងទេ។ ខ្ញុំបាន បន្តរស់នៅជាមួយប្តីពីព្រោះខ្ញុំមិនចង់អោយកូនអត់ឪពុក ហើយគាត់មិន បានមករកពួកយើងវិញទេ ហើយបានរត់ទៅនៅថៃបាត់។

ច្រើនឆ្នាំបន្ទាប់មក បន្ទាប់ពីពេលយើងបានដឹងថាគាត់ស្លាប់ កូនរបស់ខ្ញុំសួរហេតុអ្វីបានជាខ្ញុំមិនរៀបការម្តងទៀត។ ខ្ញុំប្រាប់គេថា ខ្ញុំឆ្អែតជាមួយប្តីហើយ! ខ្ញុំបានរស់នៅជាស្ត្រីមេម៉ាយរយៈពេល២០ឆ្នាំ ហើយខ្ញុំមានសមត្ថភាពឱ្យកូនប្រុសរបស់ខ្ញុំចូលរៀនសកលវិទ្យាល័យដល់ឆ្នាំទី៣។ ឥឡូវនេះគាត់ធ្វើការនៅប្រទេសកូរ៉េ ពីព្រោះខ្ញុំលែងមានសមត្ថភាពអោយកូនរៀនបន្តទៀត។ ខ្ញុំមានកូនស្រីទាំងអស់ហើយមានកូនប្រុសតែមួយ។ កូនបងគេបង្អស់អាយុ៣៨ឆ្នាំ ហើយកូនពៅគេអាយុ២៣ឆ្នាំ។

សំរាប់ខ្ញុំ ប្តីរបស់ខ្ញុំទាំងពីរគឺដូចគ្នាពីព្រោះគេមិនបានបំពេញតួនាទីរបស់គេជាប្តីទេ។ ខ្ញុំគិតថាការរៀបការដំបូងរបស់ខ្ញុំគឺខុស ពីព្រោះយើងមិនបានសុំការយល់ព្រម ហើយយើងមិនបានស្រឡាញ់គ្នា។ ចំពោះការរៀបការទី២ខ្ញុំបានយល់ព្រមដោយផ្អែកទៅលើជំរើសរបស់ខ្ញុំ និងម្តាយរបស់ខ្ញុំយល់ស្របទៀត។ ប្រសិនបើលែងលះគ្នាលើកទី២វានឹងបំផ្លាញកិត្តិយសរបស់ខ្ញុំ។ ប្រសិនបើចង់រត់គេចពីគាត់ ខ្ញុំនឹងប្រឈមមុខនឹងការខ្មាស់គេម្តងទៀត។ ដូច្នេះខ្ញុំអត់ទ្រាំ។ ខ្ញុំមានកូន ដូច្នេះទោះបីជាខ្ញុំចង់ចាកចេញ តើខ្ញុំត្រូវទៅណា? ខ្ញុំមានការអាម៉ាស់ចំពោះការរៀបការក្នុងរបបខ្មែរក្រហម ដែលនៅតែនៅជាមួយខ្ញុំ ហើយបើខ្ញុំចាកចេញពីប្តីទី២ តើអ្នកដទៃនឹងវាយតំលៃខ្ញុំជាស្ត្រីដូចម្តេចដែរ? ខ្ញុំមិនបានរៀនសូត្រចេះដឹងគ្រប់គ្រាន់ទេ ប៉ុន្តែខ្ញុំបានគិតច្រើនណាស់។ ខ្ញុំបានព្យាយាមធ្វើការយ៉ាងខ្លាំងហើយអត់ទ្រាំដើម្បីកូន។ ខ្ញុំមានកូន៦នាក់ជាមួយគាត់ ហើយមានកូនចិញ្ចឹមមួយ។ ប្តីនោះគឺស្លាប់បាត់ហើយ ប៉ុន្តែស្លាប់ ឬរស់គឺដូចគ្នាសំរាប់ខ្ញុំ។ តាមពិតទៅជីវិតរបស់ខ្ញុំហាក់ដូចជាប្រសើរជាងពេលគាត់នៅរស់។

**តើប្តីទី២របស់មីងដឹងពីអ្វីដែលបានកើតមានលើមីងក្នុងរបបខ្មែរក្រហមដែរឬទេ?**

ទេ គាត់មិនបានដឹងទេហើយគាត់មិនបានសួរខ្ញុំដែរ។ ហើយខ្ញុំក៏មិនចង់ប្រាប់គាត់ដែរ។ វាគឺនៅពេលដែលកូនស្រីទាំង៣របស់ខ្ញុំបានរៀបការ

២៦
ការស្រុតស្បូន [Ed.].

២៧
ក្នុងកំឡុងពេលនោះ ចំនួននៃជនភៀសខ្លួននៃជំរុំជនភៀសខ្លួនសំរាប់អ្នករស់រានមានជីវិតពីរបបខ្មែរ ក្រហមត្រូវបានតាំងនៅតាមបណ្តោយព្រំដែនខ្មែរថៃ

ហើយចេញទៅរស់នៅក្រៅផ្ទះ នោះជាពេលដែលខ្ញុំបានប្រាប់មនុស្សម្នាក់ពេលសាលាក្តីខ្មែរក្រហមចាប់ផ្តើមស្វែងរកអ្នកដាក់ពាក្យបណ្តឹង។[២៨] ខ្ញុំត្រូវគេសួរថាតើខ្ញុំគឺជាជនរងគ្រោះដោយការបង្ខំរៀបការ ហើយខ្ញុំបានឆ្លើយថា "ទេ"។ បន្ទាប់មកខ្ញុំត្រូវគេសួរថាតើខ្ញុំចង់ដាក់ពាក្យបណ្តឹងសំរាប់សាច់ញាតិដែលស្លាប់ទៅដែរឬទេ ហើយខ្ញុំនៅតែឆ្លើយថា "ទេ" ខ្ញុំមានអារម្មណ៍ថាដាក់ពាក្យបណ្តឹងនឹងធ្វើអោយបទពិសោធន៍ទាំងនោះមានភាពថ្មីម្តងទៀត។ ពេលគេត្រឡប់មកជាលើកទីបី [មន្ត្រីមកពីអវតក] ខ្ញុំសំរេចចិត្តដាក់ពាក្យបណ្តឹង ខ្ញុំបានឃើញមនុស្សជាច្រើនបានដាក់ពាក្យបណ្តឹងដោយសារឪពុក និងយាយតារបស់ខ្ញុំត្រូវបានសំលាប់ក្នុងរបបនោះ។ ពេលនេះហើយដែលកូនខ្ញុំបានដឹងពីអតីតកាលរបស់ខ្ញុំតាមរយៈការដាក់ពាក្យបណ្តឹង។ គេមានការភ្ញាក់ផ្អើលណាស់រួចសួរខ្ញុំថា "អ៊ូម៉ែ! ម៉ែជាស្ត្រីមេម៉ាយពីរបបខ្មែរក្រហម?"

ពេលខ្ញុំរៀបនឹងមានប្តីមួយទៀត ពេលកូននៅក្មេង ខ្ញុំបារម្ភខ្លាចប្តីថ្មីនឹងធ្វើបាបពួកគេ។ ប៉ុន្តែរហូតដល់ថ្ងៃនេះ ខ្ញុំនៅតែខ្លាចអំពីរឿងនេះ ខ្ញុំនៅតែរស់នៅក្នុងភាពភ័យខ្លាចទោះបីកូនរបស់ខ្ញុំធំៗហើយក៏ដោយ។ រហូតដល់ថ្ងៃនេះ ខ្ញុំមានអារម្មណ៍ដូចជាស្លៀកសំពត់រហែក អាក្រក់ណាស់។ ខ្ញុំកម្រទៅលេងផ្ទះអ្នកដទៃណាស់។ ខ្ញុំជាទូទៅនៅផ្ទះម្នាក់ឯង ហើយខ្ញុំមិនខ្វល់ពីអ្នកផ្សេងនោះទេ។ ហើយខ្ញុំបានឃើញពីស្ថានភាពដែលប៉ះទង្គិចកូនៗរបស់ខ្ញុំ។ ខ្ញុំបានឮ នឹងត្រចៀកខ្ញុំផ្ទាល់ថាមនុស្សក្នុងភូមិបាននិយាយ គេមិនចង់អោយកូនគេរៀបការជាមួយកូនរបស់ខ្ញុំទេពីព្រោះខ្ញុំមានប្តី២។ ពេលខ្ញុំបានឮដូចនេះ ខ្ញុំខឹងណាស់ ហើយឆ្លើយត្រឡប់ទៅវិញថា "ប្រសិនបើអ្នកមានអ្វីនិយាយ និយាយវាមកតែខ្ញុំបានហើយកុំនាំវាទៅពាក់ព័ន្ធនឹងកូនខ្ញុំ"។ ដូច្នេះខ្ញុំគិតច្រើនណាស់មុនពេលខ្ញុំសំរេចចិត្តដាក់ពាក្យបណ្តឹងពីព្រោះខ្ញុំមិនចង់សើររើវាឡើងវិញទេ។ ប៉ុន្តែពេលបានចែករំលែករឿងរ៉ាវ ខ្ញុំឃើញថាមានអ្នកស្តាប់ខ្ញុំហើយយកចិត្តទុកដាក់លើខ្ញុំ។ ឥឡូវនេះពេលខ្ញុំសួរឱ្យនិយាយពីរឿងរបស់ខ្ញុំ ខ្ញុំចែករំលែកវាទាំងអស់។ ខ្ញុំមិនចង់លាក់វាទៀតទេ។ ខ្ញុំចង់ប្រាប់វាទៅពិភពលោកទាំងមូលដូច្នេះពិភពលោកបានដឹងថាតើស្ត្រីរងនូវការឈឺចាប់អ្វីខ្លះនាពេលនោះ។

# ករណីសិក្សា ៦

ហាគ ភេទស្រី អាយុ ៥៨ឆ្នាំ
សំភាសន៍នៅថ្ងៃទី ២៨ មេសា ២០១៤
នៅទីក្រុងភ្នំពេញ នៅអង្គការចិត្តសង្គមអន្តរវប្បធម៌កម្ពុជា។

**តើមីងអាចប្រាប់ខ្ញុំអំពីកុមារភាពរបស់មីងមុនរបបខ្មែរក្រហមបានដែរទេ?**
ខ្ញុំកើតនៅខេត្ត xx ប៉ុន្តែខ្ញុំបានបែកពីម្តាយតាំងពីខ្ញុំនៅជាទារក។

ម្តាយ និងឪពុករបស់ខ្ញុំបានលួចលាក់ស្រឡាញ់គ្នាមុនរៀបការ ហើយតាខាងឪពុករបស់ខ្ញុំមិនបានចូលចិត្តម្តាយរបស់ខ្ញុំនោះទេ។ តារបស់ខ្ញុំបាននិយាយថានេះជាសិទ្ធិរបស់គាត់ជាអាណាព្យាបាលក្នុងការរើសប្រពន្ធសំរាប់កូនប្រុសគាត់ទោះបីនារីនោះមានឬក្រក៏ដោយ។ ដូច្នេះគាត់បានបំបែកឪពុក និងម្តាយខ្ញុំ ទោះបីជាពេលនោះម្តាយរបស់ខ្ញុំជិតដល់ពេលឆ្លងទន្លេក៏ដោយ។ ពេលខ្ញុំកើតបានមួយសប្តាហ៍ ម្តាយរបស់ខ្ញុំបានយកខ្ញុំទៅផ្ទះតាខាងឪពុកឱ្យថែរក្សាខ្ញុំ ហើយបន្ទប់មកយើងបាត់ទំនាក់ទំនងជាមួយម្តាយខ្ញុំរហូត។ ម្តាយខ្ញុំ និងឪពុកខ្ញុំមិនបានរៀបការទេ ទោះបីជាគេទាំងពីរស្រឡាញ់គ្នា ហើយមានកូនស្រីមួយជាមួយគ្នាក៏ដោយ។ តាំងពីពេលនោះមកតាខាងឪពុកមិនទទួលស្គាល់គាត់ ម្តាយរបស់ ខ្ញុំក៏សំរេចចិត្តចេញពីជីវិតរបស់ឪពុកខ្ញុំ។ ខ្ញុំបានដឹងរឿងនេះពីព្រោះតា របស់ខ្ញុំបាននិយាយពីវាហើយខ្ញុំចាំគាត់និយាយរឿងនេះបានច្បាស់ដែរ។

ទំនាក់ទំនងរបស់ខ្ញុំជាមួយឪពុកគឺមិនជិតស្និទ្ធទេគឺដូចជាពូនិងក្មួយជាងដូចឪពុកនិងកូន។ គាត់ចង់លាក់កំបាំងថាគាត់មិនមែនជាឪពុករបស់ខ្ញុំ។ បន្ទាប់មក តារបស់ខ្ញុំបានរកប្រពន្ធម្នាក់ទៀតឱ្យឪពុកខ្ញុំរៀបការជាមួយ ហើយឪពុករបស់ខ្ញុំគិតថាប្រពន្ធថ្មីអោយខ្ញុំឈឺចាប់ ប្រសិនបើនាងដឹងថាខ្ញុំជាកូនស្រីរបស់គាត់ ។

២៨
អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អវតក) គឺជាតុលាការបង្កើតឡើងដើម្បីកាត់ទោសមេដឹកនាំ ខ្មែរក្រហមចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងការប្រល័យពូជសាសន៍។ អ្នក រស់រានមានជីវិតបានដាក់ពាក្យបណ្តឹងចំពោះការឈឺចាប់ហើយក្លាយជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងតុលាការ និងចូលរួមក្នុងដំនើរការកាត់ក្តី។ សូមមើលសេចក្តីផ្តើមសំរាប់ព័ត៌មានបន្ថែម

### តើមីងដឹងទេថាហេតុអ្វីបានជាតារបស់មីងមិនទទួលស្គាល់ម្តាយរបស់មីង?

ខ្ញុំគិតថាពីព្រោះគាត់ជឿទៅលើបុរាណគេនិយាយថា "នំមិនធំជាងនាឡិ"—នោះគឺកូនត្រូវតែស្តាប់ឪពុកម្តាយ។[២៩] ជាលទ្ធផលយាយតារបស់ខ្ញុំបានចិញ្ចឹមខ្ញុំ។ ដោយសារតែតារបស់ខ្ញុំបារម្ភថាប្រពន្ធក្រោយរបស់ឪពុកខ្ញុំអាចធ្វើបាបខ្ញុំ គាត់បានចិញ្ចឹមខ្ញុំដូចជាកូនបង្កើតរបស់គាត់។ ខ្ញុំមិនបានស្គាល់ឪពុកថាជាឪពុកនោះទេ។ តារបស់ខ្ញុំនឹងប្រាប់រឿង អំពីពេលដែលគាត់មិនមានប្រាក់គ្រប់គ្រាន់ក្នុងការទិញទឹកដោះគោអោយខ្ញុំគាត់បានទៅមណ្ឌលកុមារកំព្រាដើម្បីបានទឹកដោះគោដោយមិនអស់ប្រាក់ពេលខ្ញុំនៅជាទារក។

ពិតណាស់ ខ្ញុំបានរស់នៅជាមួយតារហូតដល់ខ្ញុំមិនអាចទៅរស់នៅជាមួយសាច់ញាតិណាទៀតទេ។ ពេលខ្ញុំនៅកុមារមានកូនកំព្រា២នាក់រស់នៅជាមួយតាខ្ញុំ ប៉ុន្តែគេនៅមានម្តាយ។ សាច់ញាតិរបស់ខ្ញុំគេបានរើសអើងខ្ញុំ ពីព្រោះខ្ញុំជាកូនស្រីរបស់ឪពុកម្តាយដែលមិនបានរៀបការដែលប្រឆាំងនឹងប្រពៃណី។ ខ្ញុំនៅក្មេងណាស់មិនយល់ពីបញ្ហានេះច្រើនទេ ប៉ុន្តែពេលខ្ញុំជំទង់ជីដូនមួយរបស់ខ្ញុំជាញឹកញាប់បានស្តីអោយខ្ញុំ និងវាយខ្ញុំ។ នៅអាយុ១៦ឆ្នាំ ខ្ញុំសំរេចចិត្តរត់ចេញពីផ្ទះទៅធ្វើការតាមផ្ទះគេនៅភ្នំពេញ។ ខ្ញុំបានប្រាប់ខ្លួនឯងថា ខ្ញុំគ្មានសាច់ញាតិទេ ហើយខ្ញុំទីពឹងខ្លួនឯង។

### តើជីវិតរបស់មីងនៅភ្នំពេញមានភាពបែបណាដែរ?

ខ្ញុំធ្វើការជាអ្នកបំរើតាមផ្ទះម្នាក់។ ថៅហ្វាយខ្ញុំគាត់ចិត្តល្អណាស់ ខ្ញុំមិនមានបញ្ហាក្នុងការរស់នៅជាមួយគាត់ទេ។ ក្រុមគ្រួសាររបស់គាត់ក៏ចិត្តបាននឹងខ្ញុំដែរ ហើយគេស្រឡាញ់ខ្ញុំណាស់ដូចជាគ្រួសាររបស់គេដែរ។ ខ្ញុំមើលថែរក្សាផ្ទះសំបែងរបស់គេដូចផ្ទះរបស់ខ្ញុំដែរ។ ម្តាយរបស់ថៅហ្វាយស្រីខ្ញុំត្រូវជាកូនប្រសាររបស់បងស្រីតារបស់ខ្ញុំ។ គាត់ចាស់ណាស់ហើយ ហើយគាត់សួរខ្ញុំប្រសិនបើខ្ញុំចង់មករស់នៅជាមួយគាត់។

ពេលជាមួយគ្នានោះ ចៅហ្វាយរបស់ខ្ញុំបានស្វែងរកអ្នកបំរើតាមផ្ទះល្អម្នាក់យូរមកហើយ។ ពេលគាត់ជួបខ្ញុំនៅផ្ទះម្តាយរបស់គាត់ គាត់បានសួរឱ្យខ្ញុំមកធ្វើការអោយគាត់។ ខ្ញុំមានអារម្មណ៍សុខស្រួលណាស់នៅទីនោះពីព្រោះគេអោយតំលៃខ្ញុំជាស្ត្រី។ ផ្ទះរបស់គាត់ស្អាត ហើយមានសណ្តាប់ធ្នាប់ណាស់ ហើយខ្ញុំរស់នៅក្នុងកន្លែងសមរម្យមួយប្រកបដោយកិត្តិយស។ ខ្ញុំគិតថាជីវិតរបស់ខ្ញុំគឺភ្លឺថ្លាណាស់ពេលនោះ។

**តើមីងនៅភ្នំពេញនៅពេលដែលខ្មែរក្រហមឡើងកាន់អំណាច?**

ចាស ខ្ញុំនៅមន្ទីរពេទ្យ។ មុននោះខ្ញុំថែរក្សាម្តាយក្មេកចាស់ជរារបស់ចៅហ្វាយខ្ញុំ។ ខ្ញុំអាចប្តូរសារ៉ូមឱ្យគាត់បានបន្ទាប់ពីពេទ្យបានបង្រៀនខ្ញុំបានម្តង។ ពេទ្យនិយាយថាខ្ញុំឆ្លាតណាស់ ហើយគាត់បានណែនាំអោយខ្ញុំទៅរៀនពីថ្នាំពេទ្យជាមួយគាត់នៅពេទ្យ។ ខ្ញុំជាញឹកញាប់បានទៅជាមួយគាត់ពេលគាត់វេនយប់ដើម្បីរៀនពីគាត់។ បន្ទាប់មកក្នុងថ្ងៃទី១៥ និង១៦ មេសា ឆ្នាំ១៩៧៥ មេដឹកនាំខ្មែរក្រហមបានផ្លោងចូលទីក្រុង។ ខ្ញុំមិនហ៊ានត្រឡប់ទៅផ្ទះវិញនោះទេ ដូច្នេះខ្ញុំបាននៅពេទ្យមួយយប់ជាមួយនឹងអ្នកបោសសំអាតក្នុងពេទ្យ។

ពេលព្រឹកឡើងនៅថ្ងៃទី ១៧ មេសា ១៩៧៥ មនុស្សនៅទីក្រុងចាប់ផ្តើមបក់ទង់ជ័យពណ៌ស។ ចាស់ៗគាត់សប្បាយចិត្តណាស់ ដោយគិតថាប្រទេសជាតិមានសន្តិភាព ហើយនិងគ្មានសង្គ្រាមទៀតទេ។ ប្រហែលជាម៉ោង៧ព្រឹក ខ្មែរក្រហមបានគ្រប់គ្រងផ្ទះរបស់លន់នល់។[៣០] កម្មាភិបាលចាប់ផ្តើមជំលៀសប្រជាជនពីទីក្រុង។ ខ្ញុំបានបែកពីមនុស្សទាំងអស់ដែលខ្ញុំស្គាល់ពីព្រោះខ្ញុំនៅពេទ្យមិនមែននៅផ្ទះ។ ហើយត្រូវបានគេជំលៀសទៅខេត្ត xx ខ្ញុំបាននៅទីនោះមួយខែ។ ខ្ញុំបានសុំមេភូមិថាតើខ្ញុំអាចទៅលេងស្រុកកំណើតបានទេ ប៉ុន្តែគាត់បដិសេធ។ ដូច្នេះខ្ញុំត្រូវបានបញ្ជូនទៅរស់នៅ xx ខ្ញុំសួរមនុស្សនៅតាមផ្លូវដើម្បីរកផ្លូវទៅ ពីព្រោះខ្ញុំមិនស្គាល់ផ្លូវទៅទីនោះ។ នៅពេលនោះខ្ញុំមិនបានដឹងថាតើកន្លែងណាគេមិនហាមឃាត់ ហើយកន្លែងណាគេហាមឃាត់ទេ។[៣១] ខ្ញុំមិនទាន់ធ្វើតាមវិធីរបស់

២៩
ក្នុងន័យមួយទៀត ឪពុកម្តាយ, មិនមែនកូនទេ, ដែលជាអ្នករៀបចំការរៀបការអនុវត្តទៅតាមប្រពៃណី

៣០
សូមមើលសទ្ទានុក្រម "លន់ នល់"

៣១
គាត់មិនបានដឹងថាតើតំបន់ណាខ្លះទេដែលត្រូវបានគ្រប់គ្រង ("បានរំដោះ") ដោយខ្មែរក្រហម បន្ទាប់ពីភ្នំពេញបានរលំ។ តាមពិតទៅ មានភាពមិនដូចគ្នាក្នុងគោលនយោបាយខ្មែរក្រហមពេញផ្ទៃប្រទេសនៅក្នុងដំនើរការបដិវត្តន៍ ហើយខេត្តខ្លះត្រូវបានគ្រប់គ្រងដោយខ្មែរក្រហមតាំងពីមុនឆ្នាំ ១៩៧៥ មកម្លេះ

អង្គការនៅឡើយទេ។ ខ្ញុំបានជីកប្រឡាយនិងធ្វើស្រែពេលរស់នៅទីនោះ។

ខ្ញុំមិនស្គាល់នរណាម្នាក់សោះនិងមិនមានមិត្តភក្តិឬសាច់ញាតិអ្វីដែរ ដូច្នេះខ្ញុំសប្បាយចិត្តដែលត្រូវបានគេជំលៀសទៅជិតស្រុកកំនើត។ [នៅក្បែរ xx] ខ្ញុំរែកដីនៅក្បែរបឹង xx ដែលនៅទីនោះមានមូសច្រើនណាស់។ ខ្ញុំធ្លាក់ខ្លួនឈឺរួចគេយកខ្ញុំទៅពេទ្យ ប៉ុន្តែវាមិនមានបន្ទប់ទេ ដូច្នេះ គេក៏បញ្ជូនខ្ញុំទៅសាលាបឋមសិក្សាដែលនៅទីនោះមានគ្រែពេទ្យនៅទំនេរ។ ខ្ញុំនៅទីនោះបាន៤ខែហើយត្រឡប់មកកាន់កន្លែងធ្វើការវិញ ទោះបីខ្ញុំនៅខ្សោយក៏ដោយ។ មានស្ត្រីចាស់ម្នាក់បានទូន្មានខ្ញុំថា "សុំមេកងទៅមើលការពារសត្វស្លាបនៅវាលស្រែទៅពីព្រោះវាមិនមែនជាការងារធ្ងន់"។

ថ្ងៃមួយខ្ញុំចង់ធ្វើអំបុក ហើយខ្ញុំបានទៅវាលស្រែទៅបួតស្រូវដែលដុះឡើងវិញពីស្រូវចាស់ៗ។ ពេលដែលខ្ញុំកំពុងចំអិនអំបុក កម្មាភិបាលខ្មែរក្រហមបានមកចាប់ខ្ញុំ។ ខ្ញុំត្រូវបានគេចាប់ឃុំនៅក្នុងមន្ទីរស្រុករយៈពេលមួយសប្តាហ៍ មុនពេលគេបញ្ជូនទៅមន្ទីរឃុំឃាំង។ មួយសប្តាហ៍ បន្ទាប់មក សមាជិកខ្មែរក្រហមបានសួរចំលើយអំពីគ្រួសាររបស់ខ្ញុំ។ ខ្ញុំឆ្លើយដោយស្មោះត្រង់ថា—ខ្ញុំជាកូនតែមួយ ឪពុកម្តាយខ្ញុំបានលែងលះគ្នា ហើយឪពុកខ្ញុំមានប្រពន្ធថ្មី។ គេបានសួរខ្ញុំថាហេតុអ្វីបានជាខ្ញុំលួចស្រូវ ហើយគេបានធ្វើឱ្យខ្ញុំសារភាព [ដូចនេះ]៖ "ខ្ញុំមិនគួរធ្វើអកប្បកិរិយាដែលបំផ្លាញបដិវត្តន៍នោះទេ។ ខ្ញុំលួចស្រូវ ពីព្រោះខ្ញុំល្ងង់ហើយចង់ធ្វើអំបុក។ ខ្ញុំមិនបានលួចពីអង្គការដោយសារ តែការឃ្លានទេ។ ប្រសិនបើខ្ញុំឃ្លានខ្ញុំនឹងសុំម្ហូបអង្គការ ហើយខ្ញុំនឹងមិនធ្វើបែបនេះទៀតទេ។"

បន្ទាប់ពីនោះមក គេហាក់ដូចជាពេញចិត្តហើយស្ត្រីកម្មាភិបាលបាននិយាយមកខ្ញុំថា "មិត្ត ប្រសិនបើមិត្តឯងស្មោះត្រង់នឹងអង្គការ មិត្តនឹងមិនស្លាប់ទេ"។

មីងរបស់ខ្ញុំក៏រស់នៅក្នុងភូមិនោះដែរ ហើយគាត់ជាប្រជាជនមូលដ្ឋាន[៣២]

ដូច្នេះគេមិនអោយយើងនៅជាមួយគ្នានោះទេ។ នៅពេលនោះ ខ្ញុំមិនបានដឹងថាគេមិនចង់ឱ្យយើងនិយាយរកគ្នាជាមួយនឹងសាច់ញាតិយើងនោះទេ។ ខ្ញុំមិនបានដឹងពីគោលការណ៍របស់អង្គការនៅឡើយទេ។[៣៣] ខ្មែរក្រហមបានជំលៀសប្រជាជនថ្មីទៅជិតភ្នំ។ តាមការពិត គេបានអោយប្រជាជនទៅទីនោះដើម្បីបង្អត់អាហារហើយអោយប្រជាជនស្លាប់។ ស្ទើរតែរាល់ថ្ងៃដែលគេបញ្ជូនប្រជាជនថ្មីទៅទីនោះរួមទាំងជនជាតិចិន ចាម វៀតណាម និងខ្មែរ។ ដោយសារតែខ្ញុំជាប្រជាជនថ្មី មីងរបស់ខ្ញុំមានការតក់ស្លុតហើយសួរខ្ញុំថា "តើឯងចង់ទៅទីនោះហើយមានជំងឺគ្រុនចាញ់ឬ?" ខ្ញុំឆ្លើយថា "បើខ្ញុំគង់តែនឹងស្លាប់ដដែល ខ្ញុំប្រហែលជានឹងស្លាប់ដែរហើយនៅទីនោះ" ខ្ញុំមិនត្រូវបានបញ្ជូនទៅភ្នំនោះទេ ប៉ុន្តែខ្ញុំដឹងថាខ្ញុំនឹងស្លាប់ប្រសិនបើខ្ញុំនៅភូមិរបស់មីងខ្ញុំយូរ។ ខ្ញុំមិនអាចធ្វើការបានច្រើនដូចអ្នកផ្សេងទេពីព្រោះខ្ញុំនឹងឈឺក្បាលខ្លាំង។ ពេលខ្ញុំត្រឡប់ចូលទីរោងសហករពេលចប់ការងារ ខ្ញុំសង្កេតឃើញថាប្រជាជនមូលដ្ឋានមានទឹកមុខមិនរួសរាយដាក់ខ្ញុំទេ។ បន្ទាប់មកខ្ញុំមិនត្រឡប់ទៅភូមិទៀតទេ ហើយខ្ញុំបានមកដេកនៅវាលស្រែពីព្រោះខ្ញុំមានអារម្មណ៍លំហែរពេលនៅម្នាក់ឯង។ មេភូមិគិតថាខ្ញុំមានបញ្ហាផ្លូវចិត្ត ហើយដូច្នេះគាត់បានដាក់ច្រវ៉ាក់ខ្ញុំទៀតផងពេលខ្លះ។

ខ្ញុំត្រូវបានគេជំលៀសទៅឃុំ xx ភូមិ xx ក្នុងខេត្ត xx ជិតភូមិកំនើតរបស់ខ្ញុំ។ ខ្ញុំបានធ្វើការនៅទីនោះក្នុងក្រុមស្ត្រីហើយចំអិនម្ហូបក្នុងរោងចំរុះមួយ។ ខ្ញុំបានរងរបួសត្រង់ជើង ហើយទៅជាដំបៅរលួយ។ ជើងរបស់ខ្ញុំត្រូវបានមុតនឹងដែកពេលខ្ញុំដងទឹក។ ខ្ញុំបានគិតថាខ្ញុំប្រហែលជាស្លាប់ហើយ ហើយខ្ញុំនៅតែមានស្នាមជំរហូតទល់សព្វថ្ងៃ។ រាល់ថ្ងៃ មនុស្សគ្រប់គ្នាគេដើរទៅស្រែ ចំណែកខ្ញុំវិញនៅភូមិម្នាក់ឯង។ ពេលជើងរបស់ខ្ញុំបានជាខ្ញុំបានទៅច្រូតស្រូវនៅស្រែជាមួយគេឯងដែរ។ ថ្ងៃមួយខ្ញុំបានកំពុងត្រឡប់ពីច្រូតវិញ កម្មាភិបាលបានសុំឱ្យខ្ញុំរៀបការជាមួយបុរសម្នាក់ដែលខ្ញុំមិនដែលបានស្គាល់។ តែខ្ញុំបានប្រកែក។

៣២
សូមមើលសទ្ទានុក្រម "អ្នកមូលដ្ឋាន"

៣៣
ពីព្រោះគាត់ត្រូវបានបំបែកចេញពីគ្រួសាររបស់គាត់រួចស្រេចទៅហើយ គាត់មិនបានដឹងពីគោលនយោបាយខ្មែរក្រហមក្នុងការរុះរើ និងកំទិចភាពឯកជនរបស់គ្រួសារ។ ក្នុងប្រយោគបន្ទាប់ទៀត ហគ បានពន្យល់ថា ដោយសារគាត់ត្រូវបានគេជំលៀសពីភ្នំពេញ គាត់ត្រូវបានគេចាត់ទុកថាជា "ប្រជាជនថ្មី" ទោះបីជាគាត់ទទួលការអប់រំក្នុងទីជនបទក៏ដោយ ("មូលដ្ឋាន") តំបន់

## តើមីងមានបានរំពឹងទុកថានឹងត្រូវបានគេស្នើរសុំរៀបការដែរទេ?

ខ្ញុំត្រូវបានគេស្នើរសុំរៀបការពីរដងរួចមកហើយ ហើយខ្ញុំនិយាយថាទេ។ គេមិនអាចគ្រាន់តែសួរខ្ញុំហើយបន្ទាប់មករៀបការនោះទេ។ វាមានដំណាក់កាលពីរៈ ដំបូងគេស្នើរសុំខ្ញុំ ប៉ុន្តែមានតែ*អង្គការ*ទេដែលអាចអនុញ្ញាតបាន។

## តើអ្វីជាការស្នើរសុំរៀបការពីរដងមុន?

ដំបូង ស្ត្រីចាមម្នាក់បានសុំឱ្យខ្ញុំរៀបការ [ជាមួយសាច់ញាតិប្រុសរបស់គាត់] ពេលខ្ញុំទៅកន្លែងរបស់គាត់ដើម្បីអាំងភ្លើងកំដៅខ្លួនពេលខែពេញបូរមី។ ខ្ញុំបានប្រាប់គាត់ថា ខ្ញុំមិនចង់រៀបការទេពីព្រោះខ្ញុំចាំដល់ពេលជួបជុំគ្រួសារវិញសិន។ ខ្ញុំត្រូវប្រកែកតែម្តងទេ ពីព្រោះគាត់ជាប្រជាជនថ្មីដូចខ្ញុំដែរ ដូច្នេះគាត់មិនអាចមានអំណាចមកគៀបសង្កត់ខ្ញុំទេ។[៣៤] ពីរសប្តាហ៍បន្ទាប់ ស្ត្រីម្នាក់ទៀតគាត់ឈ្មោះ គ បានសួរខ្ញុំអោយរៀបការជាមួយក្មួយប្រុសរបស់គាត់។ ខ្ញុំប្រកែកម្តងទៀត ហើយគាត់មិនហ៊ានមិនព្រមនោះទេពីព្រោះគាត់ជាប្រជាជនថ្មីដែរ។ វាប្រហែលជាម៉ោង៩ព្រឹក ខ្ញុំបានទៅផ្ទះបាយធ្វើការ។ បងស្រីរបស់ គ បាននៅទីនោះហើយស្នើរខ្ញុំម្តងទៀត។ ខ្ញុំក៏ប្រកែកម្តងទៀត ដោយនិយាយថាខ្ញុំមិនបានស្គាល់បុរសដែលគេស្នើរឱ្យខ្ញុំនោះទេ។ ប្រាំនាទីក្រោយមក គាត់បានត្រឡប់មកម្តងទៀត រួចនិយាយថា ការស្នើរនេះគឺរៀបចំឡើងដោយអង្គការ ហើយខ្ញុំមិនអាចប្រកែកបានទេ។ គាត់និយាយថា "ប្រសិនបើមិត្តឯងមិនព្រមមិត្តឯង នឹងត្រូវគេសំលាប់"។ ខ្ញុំបានពិចារណាថា ខ្ញុំចង់ជួបគ្រួសាររបស់ខ្ញុំម្តងទៀត ហើយមើលឃើញស្រុកទេសអភិវឌ្ឍ ហើយខ្ញុំមិនទាន់ចង់ស្លាប់ទេ។ ចុងបញ្ចប់ខ្ញុំក៏ព្រមរៀបការជាមួយប្តីរបស់ខ្ញុំពីព្រោះខ្ញុំគិតថាមនុស្សស្លាប់ងាយណាស់នាពេលនោះ ហើយខ្ញុំបានគិតថាខ្ញុំអាចរត់គេចពីប្តីរបស់ខ្ញុំបន្ទាប់ពីរបបខ្មែរក្រហម[៣៥]ចប់។

ខ្ញុំបានរៀបការនៅថ្ងៃបន្ទាប់នាឆ្នាំ១៩៧៧។ វាគឺនៅពេលរដូវចូលឆ្នាំ ទោះបីខ្ញុំមិនបានចាំថ្ងៃពិតប្រាកដ។ ខ្ញុំមានអាយុ១៩ឆ្នាំ។ ខ្ញុំរៀបការ

ពេលជាមួយគ្នានឹង២គូទៀត។ យើងជា៣គូដំបូងគេដែលរៀបការក្នុងភូមិនោះដែលរៀបចំដោយខ្មែរក្រហម។

**ហាក់ដូចជាមីងមិនបានដឹងខ្លួនមុនទេថាមីងនឹងត្រូវរៀបការ?**

ខ្ញុំមិនមានគំនិតអ្វីទេ។ ខ្ញុំទើបតែត្រឡប់មកពីរើសស្លឹកឈើដើម្បីជ្រលក់ពណ៌ក្រណាត់អោយខ្មៅ[៣៦] ពេលខ្ញុំបានជួបស្ត្រីម្នាក់ខ្ញុំក៏បានដឹង។ គាត់បានសួរថា តើខ្ញុំទើបមកពីណា ពីព្រោះជិតដល់ពេលរៀបការហើយ។ ខ្ញុំបានប្រាប់គាត់ឱ្យប្រាប់ខ្ញុំបន្ថែម ហើយក្នុងគំនិតរបស់ខ្ញុំគិតថាវាដូចជាពិធីរៀបការតាមបែបប្រពៃណី។ ខ្ញុំប្រញាប់ទៅផ្ទះ ហើយពេលទៅដល់មានស្ត្រីកម្មាភិបាលម្នាក់ឱ្យខោអាវថ្មីពណ៌ខ្មៅមកខ្ញុំ ហើយមានម្សៅលាបមុខទៀត។

ពិធីរៀបការរបស់ខ្ញុំគឺខុសពីការរៀបការផ្សេងទៀត ពីព្រោះយើងជាប្តីប្រពន្ធដំបូងគេក្នុងភូមិដែលរៀបការ។ ផ្ទះបាយគេរៀបចំចំអិនទាសំរាប់ពិធីជប់លៀងរៀបការ។ វាធ្វើនៅពេលថ្ងៃ ហើយមិនខុសគ្នាប៉ុន្មានពីពិធីរៀបការតាមប្រពៃណីនោះទេ—មានអាចារ្យ ដើម្បីដឹកនាំពិធី ហើយមានពិធីជាមួយម្ហូបពិសេស។ ខ្ញុំមានបញ្ចុកបាយឱ្យប្តីរបស់ខ្ញុំទៀតផង ដូចនៅក្នុងពិធីបែបប្រពៃណីដែរ ប៉ុន្តែយើងមិនមានពិធីកាត់សក់នោះទេ។ តាមពិតទៅខ្ញុំមិនហ៊ានមើលមុខប្តីនោះទេ។ ខ្ញុំអៀនណាស់ហើយខ្ញុំមិនស្គាល់គាត់ផង។

និយាយដោយស្មោះត្រង់ទៅ ខ្ញុំមិនចង់រៀបការទេពីព្រោះខ្ញុំនៅក្មេង។ ខ្ញុំធ្លាប់សួរចាស់ៗថា តើប្រពន្ធត្រូវធ្វើអ្វីខ្លះបន្ទាប់ពីរៀបការរួច។ គេបានឆ្លើយថា យើងត្រូវតែមើលថែរក្សាកូន ប្តី និងទទួលខុសត្រូវកិច្ចការងារផ្ទះសំបែង។ ខ្ញុំបានគិតថា បើនៅពេលមុនវិញ ខ្ញុំសូមមិនរៀបការទេពីព្រោះខ្ញុំអាចធ្វើការ និងរស់រានមានជីវិតបានដោយខ្លួនឯង ហើយអាចទៅលេងតារបស់ខ្ញុំពេលណាដែលខ្ញុំចង់។ ខ្ញុំខ្លាចបាត់បង់សេរីភាពបន្ទាប់ពីមានប្តីរួច។ ខ្ញុំគិតថាការរៀបការគឺអស្ចារ្យ និងប្រកបដោយកិត្តិយសណាស់សំរាប់មនុស្សស្រី ប៉ុន្តែខ្ញុំខ្លាចថាការមានប្តីគេអាចធ្វើឱ្យ

៣៤
សូមមើលសទ្ទានុក្រម "អ្នកថ្មី"

៣៥
សូមមើលសទ្ទានុក្រម "ប៉ុលពត"

៣៦
របបនោះតំរូវឱ្យប្រជាជនទាំងអស់ស្លៀកពាក់ខ្មៅ

ខ្ញុំឈឺចាប់។ ប៉ុន្តែក្នុងរបបខ្មែរក្រហមខ្ញុំនឹងត្រូវគេសម្លាប់ប្រសិនបើខ្ញុំមិនព្រមរៀបការ។ ខ្ញុំបានព្រមរៀបការហើយបានគិតថាខ្ញុំអាចចាកចេញពីប្ដីបន្ទាប់ពីសម័យនោះចប់។ ខ្ញុំចងចាំថាសម័យលន់នល់ ហើយអ្វីៗតែងតែផ្លាស់ប្ដូរ។ ដូច្នេះខ្ញុំនៅតែរំពឹងថាការផ្លាស់ប្ដូរនឹងមកឆាប់ៗមិនយូរទេ។

ពិធីរៀបការរបស់ខ្ញុំគឺខុសពីគេដែលរៀបពេលក្រោយៗ។ ប្រជាជនថ្មីជាឧទាហរណ៍ មិនមានអាហារពិសេសនោះទេ។ កម្មាភិបាលប្រើការរៀបការដើម្បីទាក់ទាញចំណាប់អារម្មណ៍របស់មេដឹកនាំ។ គេចាប់អារម្មណ៍ក្នុងការបង្ហាញពីចំនួនប្ដីប្រពន្ធច្រើនដែលត្រូវបានរៀបការក្នុងភូមិរបស់គេ។

## តើមានអ្វីកើតឡើងបន្ទាប់ពីពិធីជប់លៀងរៀបការរួច?

យើងត្រូវបានគេនាំទៅផ្ទះតូចៗដើម្បីរស់នៅជាមួយគ្នា។ យប់នោះប្ដីខ្ញុំបានព្យាយាមប៉ះដៃខ្ញុំ ហើយខ្ញុំមិនមានគំនិតថាគាត់ចង់ធ្វើអ្វីទេ។ ខ្ញុំមិនបានដឹងអំពីផ្លូវភេទនោះទេនាពេលនោះ។ យើងត្រូវតែត្រូវរូវគ្នា ហើយរួមភេទ បើមិនដូច្នេះទេកម្មាភិបាលនឹងសំលាប់យើង។ ដូច្នេះខ្ញុំគ្រាន់តែនៅស្ងៀមហើយបិទនូវអ្វីដែលបានកើតមានលើខ្ញុំ។ ខ្ញុំពោរពេញដោយភាពសោកស្ដាយ ហើយសន្យានឹងខ្លួនឯងថាខ្ញុំនឹងមិនរៀបការម្ដងទៀតទេ ប្រសិនបើខ្ញុំអាចបែកចេញពីប្ដីនេះបាន។

ប្ដីរបស់ខ្ញុំ និងខ្ញុំត្រូវបានឈ្លបលបយកការណ៍រាល់យប់។ ប្រសិនបើខ្ញុំមិនព្រមរួមភេទជាមួយប្ដី ខ្ញុំនឹងត្រូវគេនាំយកទៅ 'រៀនសូត្រ'[៣៧] ដូច្នេះខ្ញុំមិនដែលបដិសេធនឹងគាត់នោះទេ ហើយយល់ព្រមឱ្យប្ដីរបស់ខ្ញុំធ្វើតាមតែគាត់ចង់។ ទំនាក់ទំនងរវាងខ្ញុំហើយនិងប្ដីខ្ញុំមិនល្អនោះទេ ពីព្រោះប្ដីខ្ញុំមិនមែនជាមនុស្សបើកចិត្តទូលាយទេ ហើយគាត់មិនយល់ពីដៃគូម្ខាងទៀតនោះទេ។ ខ្ញុំរស់នៅជាមួយគាត់ដោយគ្មានសុភមង្គល ទោះបីជាយើងនៅរស់នៅជុំគ្នារហូតទល់សព្វថ្ងៃនេះក៏ដោយ។

[ក្នុងរបបខ្មែរក្រហម] ប្ដីរបស់ខ្ញុំនិងខ្ញុំបានរស់នៅ និងធ្វើការជាមួយគ្នាដោយធ្វើការកាប់ឆ្កាព្រៃសំរាប់ដាំដំណាំពោត។ ប្ដីរបស់ខ្ញុំ និងខ្ញុំបាន

ឈ្លោះប្រកែកគ្នាជាញឹកញាប់ដោយសារតែការរួមភេទ—ខ្ញុំហត់ណាស់ ហើយវាឈឺចាប់ក្នុងការរួមភេទជាមួយគាត់។ គាត់នៅតែធ្វើបែបនេះទល់សព្វថ្ងៃ ហើយគាត់ចោទថាខ្ញុំមានសាហាយ ដូច្នេះហើយបានជាខ្ញុំប្រកែកនឹងគាត់។ ជាច្រើនឆ្នាំកន្លងមកហើយវាបង្កនូវបញ្ហាការឈ្លោះប្រកែក និងការវាយដំ។ ត្រង់ចំនុចមួយក្នុងរបបខ្មែរក្រហម យើងត្រូវបានគេបញ្ជូនឱ្យទៅធ្វើការកន្លែងផ្សេងគ្នា ប៉ុន្តែកម្មាភិបាលសោកស្តាយដែលគេឃើញយើងជាប្តីប្រពន្ធថ្មីៗបែកគ្នា ដូច្នេះគេបានរៀបចំឱ្យយើងជួបជុំគ្នាវិញ។ ខ្ញុំមិនសប្បាយចិត្តទេដែលបានឮដូចនេះ ពីព្រោះខ្ញុំសប្បាយចិត្តជាងពេលបែកពីគាត់សំរាប់រយៈកាលបីខែនោះ។

## តើមីងមានកូនជាមួយគ្នាទេ?

ខ្ញុំមានផ្ទៃពោះដំបូងគេនៅឆ្នាំ១៩៧៩។ វាជារឿងធម្មតាទេដែលការមានផ្ទៃពោះមានការពន្យាពេលនាពេលនោះ ពីព្រោះយើងខ្វះខាតរបស់ហូប។ បន្ទាប់មកខែមករា ឆ្នាំ១៩៧៩ ខ្ញុំចាញ់កូនខ្លាំងណាស់ មានអារម្មណ៍ចង់ក្អួត និងវិលមុខ។ មុនពេលនោះ របបខ្មែរក្រហមស្ទើរតែដួលរលំទៅហើយ។[៣៨] ខ្ញុំរត់គេចចេញពីប្តីរបស់ខ្ញុំទោះបីជាខ្ញុំមានផ្ទៃពោះក៏ដោយ។ ខ្ញុំបានគិតថា ទីបំផុតខ្ញុំបានរួចចេញពីគាត់ហើយ។ ប៉ុន្តែប្តីខ្ញុំបានរកខ្ញុំឃើញ ហើយសុំអោយខ្ញុំរស់ជាមួយគាត់វិញ។ ខ្ញុំគិតគូរយ៉ាងយូរ និងពិបាកសម្រេចចិត្តណាស់។ បន្ទាប់មកពេលខ្ញុំមានផ្ទៃពោះបាន៥ខែ ខ្ញុំបានសំរេចចិត្តរស់នៅជាមួយគាត់។ ដោយពិចារណាទៅលើភាពជាក់ស្តែងថាខ្ញុំជិតមានកូន ហើយខ្ញុំមិនមានសាច់ញាតិនឹងគេដើម្បីពឹងពាក់ទេ ហើយខ្ញុំ និងប្តីខ្ញុំបានរៀបការរួចទៅហើយ។

ខ្ញុំក្រណាស់មិនមានធនធានក្នុងការរស់នៅដោយគ្មានប្តីនោះទេ ហើយខ្ញុំចង់ឱ្យកូនខ្ញុំមានគ្រួសារនឹងគេ។ ជាក់ស្តែងវាមិនបានដូចដែលខ្ញុំបានគិតនោះទេ។ ខ្ញុំបានរស់នៅជាមួយគាត់រហូតដល់កូនៗរបស់ខ្ញុំធំ ហើយបន្ទាប់មកខ្ញុំបានព្យាយាមរត់ចេញ។ គាត់បានអង្វរឱ្យកូនៗជួយរកខ្ញុំមកវិញហើយនាំខ្ញុំមកផ្ទះវិញ។

៣៧ សូមមើលសទ្ទានុក្រម "ការអប់រំរៀនសូត្រ"

៣៨ កងកំលាំងវៀតណាមបានចូលមកប្រទេសក្នុងថ្ងៃ ៧ មករា ឆ្នាំ ១៩៧៩

បញ្ហាចំបងក្នុងជីវិតអាពាហ៍ពិពាហ៍របស់ខ្ញុំគឺទំនាក់ទំនងផ្លូវភេទ។ ប្តីរបស់ខ្ញុំតែងតែអង្វរខ្ញុំអោយរួមភេទនឹងគាត់ ហើយប្រសិនបើខ្ញុំមិនព្រមគាត់វាយខ្ញុំ។ ពេលគាត់នៅក្មេងយើងរួមភេទមួយថ្ងៃរំលងមួយថ្ងៃ។ ក្រោយមកខ្ញុំបានចរចាជាមួយគាត់ឱ្យរួមភេទតែ៧ទៅ១០ថ្ងៃម្តង។ ប៉ុន្តែកំឡុងសប្តាហ៍ទាំងនោះ គាត់នៅមិនសុខទេ ហើយគាត់ដុតផ្ទះ។ តាំងពីឆ្នាំ២០០០ មកគាត់បានចោទថា ខ្ញុំមានសាហាយ និងស្រែកអោយខ្ញុំថា "ប្រសិនបើសាហាយរបស់ឯងអាចរួមភេទជាមួយឯងបានចុះហេតុអ្វីខ្ញុំមិនអាច?" ខ្ញុំឮអញ្ចឹងស្ទើររាល់ថ្ងៃ។

ខ្ញុំនៅជាមួយគាត់ដោយសារតែខ្ញុំអាណិតកូន។ ខ្ញុំចង់ឱ្យគេមានអនាគតល្អ។ ខ្ញុំបានឃើញអ្នកជិតខាងរបស់ខ្ញុំដែលលែងលះគ្នា ហើយកូនរបស់គេចាប់ផ្តើមផឹកស្រា ហើយបង្កបញ្ហា។ ខ្ញុំចង់ធ្វើរឿងដែលត្រូវសំរាប់កូន ដូច្នេះខ្ញុំមិនចង់ចេញពីគាត់។ ខ្ញុំបានជួបការលំបាកច្រើនណាស់កាលនៅកុមារ ពីព្រោះតែឪពុកម្តាយខ្ញុំ ហើយខ្ញុំមិនចង់ឱ្យរឿងដូចគ្នាកើតមានលើកូនខ្ញុំ។ ខ្ញុំបានគិតថាវាជាទំនួលខុសត្រូវដែលត្រូវធ្វើ ទោះបីជាវាអាចធ្វើឱ្យខ្ញុំស្លាប់ក៏ដោយខ្ញុំនឹងស្លាប់ដើម្បីកូន។

## ដូច្នេះ មីងបានរស់នៅជាមួយគ្នាតាំងពីឆ្នាំ១៩៧៧?

ចាស ពេលខ្លះខ្ញុំនិយាយអំពីបញ្ហាជាមួយអ្នកជិតខាង ហើយគេទាំងអស់ដឹងថាប្តីខ្ញុំជាមនុស្សបែបណា ប៉ុន្តែគេមិនអាចជួយខ្ញុំបានទេ។ ពេលមានប៉ូលីសមកចាប់គាត់ និងអប់រំគាត់ ពេលណាគេដោះលែងគាត់មកវិញ គាត់វាយខ្ញុំភ្លាម។ ខ្ញុំនៅមានស្លាកស្នាមនៅលើកែងដៃនាពេលមួយដែលគាត់ចាក់ខ្ញុំក្នុងឆ្នាំ២០១២ ពេលខ្ញុំកំពុងតែដេកមុខទូរទស្សន៍។ គាត់ចាក់សោរទ្វាហើយចាក់នឹងកាំបិតខ្ញុំ ហើយកូនៗរបស់ខ្ញុំស្ទើរតែមិនអាចជួយខ្ញុំបានពីព្រោះតែទ្វាត្រូវបានចាក់សោរ។ គាត់ចាក់ខ្ញុំពីព្រោះខ្ញុំបានប្តឹងគាត់លែងលះគ្នា។ គាត់បាននិយាយថាគាត់នឹងសំលាប់ខ្ញុំ ហើយគាត់សំលាប់ខ្លួនគាត់ ដូច្នេះប៉ូលីសមិនអាចចាប់គាត់បានទេ។

ពេលក្នុងរបបខ្មែរក្រហម ខ្ញុំបានទទួលយកការរៀបការ និងការរួមភេទ

ដើម្បីរក្សាជីវិត។ បន្ទាប់មកខ្ញុំសុខចិត្តនៅដោយសារតែមានកូនជាមួយគាត់។ ខ្ញុំមានកូន៧នាក់ជាមួយគាត់ កូនបងគេអាយុ៣៩ឆ្នាំហើយ។ ច្បាស់ណាស់ គេដឹងថាតើឪពុកគេធ្វើបែបណាខ្លះដាក់ខ្ញុំ ប៉ុន្តែគេមិនកាន់ជើងខាងណាទេ។ នេះជាបាបកម្ម [ប្រឆាំងនឹងព្រះពុទ្ធ] ប្រសិនបើគេជ្រើសរើសម្តាយឬឪពុក។ ទោះបីជាគេបានឃើញអ្វីៗគ្រប់យ៉ាងក៏ដោយ ខ្ញុំតែងតែប្រាប់គេឱ្យគេធ្វើល្អជាមួយឪពុក អោយគោរពឪពុក ទោះបីជាគាត់មិនមែនជាប្តីល្អក៏ដោយ។

> “*ពេលក្នុងរបបខ្មែរក្រហម ខ្ញុំបានទទួលយកការរៀបការ និងការរួមភេទ ដើម្បីរក្សាជីវិត។ បន្ទាប់មកខ្ញុំសុខចិត្តនៅដោយសារតែមានកូនជាមួយគាត់។ ខ្ញុំមានកូន៧នាក់ជាមួយគាត់ ។*

មានប្តីប្រពន្ធតិចតួចណាស់ដែលបន្តនៅជាមួយគ្នា។ មិត្តភក្តិខ្ញុំភាគច្រើន ក្នុងរបបខ្មែរក្រហមក៏បានសន្និដ្ឋានថាខ្ញុំបានបែកពីប្តីខ្ញុំដែរ ប៉ុន្តែខ្ញុំនៅតែរស់នៅជាមួយគាត់។ គាត់បានវាយខ្ញុំរហូតប៉ុន្មានឆ្នាំនោះ តែខ្ញុំមិននិយាយទេ។

## តើមីងគិតថាជីវិតមីងនឹងខុសប្លែកដែរទេប្រសិនបើមីងមិនបានបង្ខំអោយរៀបការ?

គិតថាវានឹងប្រសើរច្រើន។ តាមពិតកាលខ្ញុំនៅក្មេងហើយធ្វើការ ខ្ញុំបានគិតថាខ្ញុំនឹងមិនរៀបការនោះទេ។ តាមពិតខ្ញុំមិនចូលចិត្តមនុស្សប្រុសទេ។ ពេលខ្ញុំអាយុបាន១៤ឆ្នាំ ខ្ញុំផឹកតែសំបកឈើដើម្បីព្យាបាលគ្រុនក្តៅ។ តាំងពីពេលនោះមក ខ្ញុំមានអារម្មណ៍ថាខ្ញុំស្អប់មនុស្សប្រុស។ បន្ទាប់ពីការព្យាបាលគ្រូខ្មែរនោះបានសួរខ្ញុំថា តើខ្ញុំមានអារម្មណ៍បែបណា។ ខ្ញុំកម្រនិយាយទៅរកគាត់ណាស់ហើយដើរចេញ។ គាត់គិតថាខ្ញុំជាក្មេងស្រីអៀនច្រើន ប៉ុន្តែតាមពិតខ្ញុំមានអារម្មណ៍ស្អប់បុរសគ្រប់គ្នាដែលខ្ញុំជួបបន្ទាប់ពីការព្យាបាលរួច។

ពេលខ្ញុំគិតពីជីវិតរបស់ខ្ញុំ ខ្ញុំយំរហូតដល់ភ្នែកខ្ញុំហើមហើយក្រហម។ ពេលខ្លះខ្ញុំដេកមិនលក់ទេដោយសារតែគិតពីវា។ រឿងរបស់ខ្ញុំស្មុគស្មាញណាស់ពីមួយចំនុចទៅមួយចំនុច។ ខ្ញុំតែងតែមានការបារម្ភអំពីភាពក្រីក្រ

និងស្ថានភាពគ្រួសារខ្ញុំ។ ខ្ញុំមិនត្រូវបានអនុញ្ញាតឱ្យរស់នៅជាមួយឪពុកម្ដាយរបស់ខ្ញុំពេលនៅក្មេង។ បន្ទាប់មកជីដូនមួយរបស់ខ្ញុំ បានវាយខ្ញុំ។ បន្ទាប់មកខ្ញុំមានប្ដីសាហាវឃោរឃៅ។ ពេលដែលខ្ញុំឱ្យពរដល់កូនៗ ទឹកភ្នែកហូរមក ពីព្រោះខ្ញុំមិនដែលបានទទួលការអោយពរ ដូចនេះពីឪពុកម្ដាយរបស់ខ្ញុំទេ។ ប្រសិនបើខ្ញុំបានទទួលពរពីម្ដាយ ជីវិតរបស់ខ្ញុំនឹងសប្បាយជាងនេះ។ បន្ទាប់ពីជីវិតកំព្រាដ៏យូរ ខ្ញុំបានគិតថាការរៀបការនឹងអាចធ្វើឱ្យជីវិតរបស់ខ្ញុំងាយស្រួលជាងនេះ ប៉ុន្តែវាផ្ទុយស្រលះ។ ប្ដីរបស់ខ្ញុំមិនបានជួយខ្ញុំទាល់តែសោះ ហើយខ្ញុំមានភារកិច្ចច្រើន ខ្ញុំហត់ណាស់ក្នុងការទទួលខុសត្រូវការងារតែម្នាក់ឯង។

## តើកូនរបស់មីងរៀបការអស់ហើយមែនទេ?

កូនស្រីពីរនិងកូនប្រុសពីររៀបការរួចហើយ ហើយមានកូនស្រីពីរនាក់នៅលីវ។ កូនប្រុសម្នាក់បានស្លាប់។ ទំនាក់ទំនងរបស់ខ្ញុំជាមួយកូនប្រុសគឺល្អណាស់រហូតដល់ពេលគេរៀបការ បន្ទាប់មកគេចាប់ផ្ដើមប្រមាថខ្ញុំ ហើយធ្វើដាក់ខ្ញុំមិនល្អ មិនគោរពខ្ញុំ។ ខ្ញុំមិនចង់និយាយពីគេនោះទេ។ សំរាប់កូនស្រីរបស់ខ្ញុំ ខ្ញុំចង់ឱ្យកូនស្រីមានអនាគតល្អ។ ខ្ញុំមិនអាចសំរេចអ្វីៗបាន គ្រប់យ៉ាងដើម្បីគេនោះទេ ហើយខ្ញុំខ្លាចកូនស្រីរបស់ខ្ញុំរៀបការជាមួយបុរសដែលមិនល្អដាក់គេ ហើយខ្លាចកូនប្រុសរបស់ខ្ញុំវាយធ្វើបាបកូនប្រសាររបស់ខ្ញុំ។ ខ្ញុំស៊ើបប្រវិត្តគ្រួសារ [របស់ប្ដីឬប្រពន្ធដែលកូនខ្ញុំចង់រៀបការជាមួយ] មុននឹងខ្ញុំអនុញ្ញាតឱ្យរៀបការ។ កូនស្រីខ្ញុំម្នាក់បានប្ដីល្អណាស់។ កូនស្រីមួយទៀតតែងតែមានបញ្ហា។ កូនស្រីនោះមានបញ្ហាពីព្រោះតែគាត់ទន់ជ្រាយពេក ប្ដីរបស់គាត់លេងល្បែងហើយអស់លុយ។ ឥឡូវគាត់បានតាំងចិត្តថា ឈប់លេងហើយរកការងារធ្វើនៅប្រទេសថៃ។ ខ្ញុំមិនច្បាស់ថាគាត់នឹងផ្លាស់ប្ដូរអកប្បកិរិយាទាំងស្រុងនោះទេ។ អាពាហ៍ពិពាហ៍ខ្លះល្អ អាពាហ៍ពិពាហ៍ខ្លះមិនល្អ ប៉ុន្តែគ្មានវិធីដែលយើងអាចដឹងពីជោគវាសនានោះទេ—ជោគវាសនារបស់យើង និងរបស់កូនយើង។

# ករណីសិក្សា ៧

មសអរ អាយុ៦៥ឆ្នាំ
សំភាសន៍នៅថ្ងៃទី ២៨ មេសា ឆ្នាំ ២០១៤
នៅទីក្រុងភ្នំពេញ នៅអង្គការចិត្តសង្គមអន្តរវប្បធម៌កម្ពុជា។

**តើមីងអាចប្រាប់អំពីការរៀបការរបស់មីងមុនរបបខ្មែរក្រហមបានទេ?**

ខ្ញុំមានអាយុ១៨ឆ្នាំ ហើយប្ដីរបស់ខ្ញុំអាយុ២១ឆ្នាំនាពេលដែលយើងរៀបការ។ ប្ដីរបស់ខ្ញុំជាទាហានមានតួនាទីបង្វឹកទាហានផ្សេងទៀត ហើយខ្ញុំធ្វើជាគិលានុបដ្ឋាយិកានៅក្នុងមន្ទីរពេទ្យ។ យើងរស់នៅជុំគ្នានាទីក្រុងភ្នំពេញ ប៉ុន្តែយើងមកពីភូមិជាមួយគ្នាក្នុងខេត្តសៀមរាប ហើយរៀននៅសាលាជាមួយគ្នា។ តាំងពីយើងទាំងពីរមករស់នៅភ្នំពេញ ឳពុកម្ដាយយើងបានសំរេចពិធីមង្គលការរបស់យើង។ យើងយល់ព្រម ហើយយើងរៀបការនាឆ្នាំ១៩៧៣។

ពិធីរៀបការនោះគឺដូចនឹងពិធីរៀបការបច្ចុប្បន្ននេះដែរ។ មានការសូត្រមន្ត មានភ្ញៀវច្រើនចូលរួមពិធីជប់លៀងមង្គលការ។ យើងមានពិធីកាត់សក់ក្នុងពេលល្ងាច និងពិធីកាត់អំបោះក្រហមពីកដៃយើងនាពេលព្រឹក។ ខ្ញុំស្លៀកក្បិនទទួលភ្ញៀវ [សំពត់ប្រពៃណីរបស់ខ្មែរ]។ ការរៀបការពិតជាខុសប្លែកពីរបបខ្មែរក្រហមណាស់។

**តើមានអ្វីកើតឡើងចំពោះប្ដីរបស់មីងបន្ទាប់ពីខ្មែរក្រហមកាន់អំណាច?**

ប្ដីរបស់ខ្ញុំនិងខ្ញុំបានទៅលេងស្រុកកំនើតពេលចូលឆ្នាំខ្មែរ។[៣៩] ២ឬ៣ថ្ងៃបន្ទាប់ពីត្រឡប់ទៅភ្នំពេញវិញ ខ្មែរក្រហមបានកាន់អំណាច ហើយជំលៀសប្រជាជនចេញពីទីក្រុង។ យើងបានមកដល់ក្បែរនឹងភូមិស្រុកនៅខេត្តសៀមរាប។ ប្រហែលជា២ទៅ៣ថ្ងៃបន្ទាប់ពីមកដល់ កម្មាភិបាលខ្មែរក្រហមបានព័ទ្ធទាហានលន់នល់[៤០] និងចាត់តាំងឱ្យពួកទាហានទៅល្បាតនៅតំបន់ xx។ តាមពិតទៅ ខ្ញុំមិនបានដឹងពីអ្វីទេនាពេលនោះ ប៉ុន្តែគេយកទាហានទាំងនោះទៅសំលាប់។ គេបានទាំងឱ្យខ្ញុំរៀបចំសំភារៈ

៣៩
បុណ្យចូលឆ្នាំខ្មែរបានពន្យាហួសបីថ្ងៃក្នុងពាក់កណ្ដាលខែមេសា របបខ្មែរក្រហមបានចូលមកទីក្រុង ភ្នំពេញក្នុងថ្ងៃទី ១៧ មេសា ឆ្នាំ១៩៧៥ ក្នុងកំឡុងចូលឆ្នាំខ្មែរ។

៤០
សូមមើលសទ្ទានុក្រម "លន់ នល់"

អោយប្តីខ្ញុំទៀតផងពេលដែលគាត់នៅក្នុងព្រៃ ដូចជាថ្នាំង និងសំលៀកបំពាក់។ ខ្ញុំមានផ្ទៃពោះផងនាពេលនោះ។

សមាជិកគ្រួសាររបស់ខ្ញុំទាំងអស់ត្រូវបានចាត់ទុកជាប្រជាជនមូលដ្ឋាន ហើយអ្នកខ្លះគឺជាខ្មែរក្រហម លើកលែងតែខ្ញុំម្នាក់ចេញ ពីព្រោះពួកគេតែងតែរស់នៅក្នុងទីជនបទ។ ប្តីរបស់ខ្ញុំនិងខ្ញុំត្រូវបានគេហៅប្រជាជនថ្មី ដោយសារតែយើងត្រូវបានជំលៀសពីភ្នំពេញមកវិញ។[៤១] បន្ទាប់ពីប្តីរបស់ខ្ញុំបានទៅឆ្ងាយប្រហែលជា២ទៅ៣ខែ ខ្ញុំមានការសង្ស័យ និងបារម្ភ។ មានថ្ងៃមួយខ្ញុំបានសួរទៅប្អូនថ្លៃខ្ញុំថា ហេតុអ្វីបានជាប្តីរបស់ខ្ញុំទៅយូរម្ល៉េះ។[៤២] គាត់ដើរចេញពីខ្ញុំដោយមិនឆ្លើយនឹងខ្ញុំទេ។ បងថ្លៃនេះជាទាហានខ្មែរក្រហម ហើយនៅក្នុងចំនោមកម្មាភិបាលដែលនាំប្តីខ្ញុំទៅព្រៃ។ បន្ទាប់មក វាគឺជាក់ស្តែងណាស់ដែលប្តីរបស់ខ្ញុំត្រូវបានគេយកទៅសំលាប់។

ពេលប្តីរបស់ខ្ញុំបានទៅឆ្ងាយ ខ្ញុំចល័តពីមួយកន្លែងទៅមួយកន្លែង ដោយសារតែខ្ញុំត្រូវបានគេសង្ស័យថាជាសត្រូវទាក់ទងនឹងទាហានលន់នល់។ ខ្ញុំមិនត្រូវបានគេអនុញ្ញាតអោយរស់នៅជាមួយម្តាយ និងបងប្អូនស្រីនោះទេ ដោយសារតែខ្ញុំជាប្រជាជនថ្មី ហើយគេជាប្រជាជនចាស់។ បន្ទាប់ពីខ្ញុំសំរាលកូនប្រុសទីមួយរួច ហើយកូនខ្ញុំអាយុបាន៦ខែ បងថ្លៃរបស់ខ្ញុំ (ម្នាក់ដែលយកប្តីខ្ញុំទៅឆ្ងាយ) បានអោយខ្ញុំទៅរស់នៅភូមិ xx ជាមួយ ម្តាយរបស់ខ្ញុំហើយនិងបងស្រីធំរបស់ខ្ញុំ និងប្តីរបស់គាត់។ ប្តីរបស់គាត់ធ្វើការនៅក្រសួងសេដ្ឋកិច្ចទទួលខុសត្រូវសំភារៈក្នុងស្រុក។ ពេលខ្ញុំរស់នៅក្បែរគាត់ ខ្ញុំនិងកូនរបស់ខ្ញុំមិនដែលអត់ឃ្លានទេ។

កំឡុងពេលនោះបងស្រីរបស់ខ្ញុំបានស្លាប់នឹងជំងឺ។ យប់មួយ ពេលខ្ញុំកំពុងដេក ប្តីរបស់បងស្រីខ្ញុំបានព្យាយាមចាប់រំលោភខ្ញុំ។ ខ្ញុំសួរគាត់ថា "ហេតុអ្វីបានជាធ្វើដូច្នេះ" គាត់មិនឆ្លើយទេ។ ពេលព្រឹកឡើងខ្ញុំមិនទៅធ្វើការទេ ហើយបានប្រាប់ម្តាយខ្ញុំថាបងថ្លៃបានព្យាយាមប៉ះពាល់ខ្ញុំកាលយប់មុន។ គាត់បានឆ្លើយថា គាត់ប៉ងចង់ប៉ះពាល់ខ្ញុំដោយសារតែគាត់

ចង់រៀបការជាមួយខ្ញុំ។ ខ្ញុំបាននិយាយថា "ប្រសិនបើចង់រៀបការ ម៉េចមិនសួរខ្ញុំតាមត្រង់?" បីថ្ងៃបន្ទាប់មកគាត់បានស្នើរៀបការ "រៀបការនឹងខ្ញុំទៅឯងនឹងរស់នៅបានស្រួល"។ ខ្ញុំក៏តបថា "ហ៊ឹម ប្ដីរបស់ខ្ញុំទើបតែស្លាប់ ដូច្នេះខ្ញុំមិនអាចរៀបការបានទេ។" គាត់ក៏តបថា "ឯងនឹងប្រឈមនឹងបញ្ហាច្រើនណាស់លុះត្រាតែឯងរៀបការនឹងខ្ញុំ។" ខ្ញុំនិយាយថា "ទេ ទេ ទេ!" ពេលខ្ញុំប្រកែកខ្លាំង គាត់បានសួរថា "ឯងមិនខ្លាចស្លាប់ទេឬ?" ខ្ញុំតបថា "ខ្ញុំមិនខ្លាចស្លាប់ទេ។ ខ្ញុំមិនខ្វល់ទេ។ ប្រសិនបើខ្ញុំស្លាប់ហើយគ្មានអ្នកណាថែរក្សាកូនខ្ញុំទេ ឱ្យវាស្លាប់តាមខ្ញុំទៅ។

## តើមានអ្វីកើតឡើងពេលមីងប្រកែក?

បងថ្លៃរបស់ខ្ញុំបានស្នើខ្ញុំរៀបការចំនួនបីដង។ លើកទីបីគាត់បានសុំប្រធានឃុំឱ្យមកជាមួយគាត់ តែខ្ញុំនៅតែប្រកែកមិនទទួលយកសំនើរគាត់។ ម្ដាយរបស់ខ្ញុំបាននិយាយជាមួយខ្ញុំដោយស្ងាត់ៗ។ គាត់បាននិយាយថា "កូនស្រីឯងគួរតែរៀបការទៅដើម្បីអោយរួចជីវិតឯងនិងជីវិតកូន។" តាមការពិតទៅខ្ញុំបានគិតថាវាប្រសើរជាងបើស្លាប់ ពីព្រោះខ្ញុំរស់នៅគ្មានសិទ្ធសេរីភាពនឹងគេ។ ការស្លាប់គឺនៅចំពោះមុខខ្ញុំតាំងពីប្ដីរបស់ខ្ញុំបានគេសំលាប់ទៅ។ ខ្ញុំគ្រាន់តែដឹងថាខ្ញុំមិនរៀបការជាមួយជនល្មើសហើយខ្ញុំសុខចិត្តស្លាប់ប្រសើរជាង។ ខ្ញុំប្រកែកពីព្រោះតែគាត់ជាសមាជិកខ្មែរក្រហម ហើយវាជាទាហានខ្មែរក្រហមដែលយកប្ដីរបស់ខ្ញុំទៅឆ្ងាយហើយសំលាប់គាត់។ ហើយគាត់ជាមនុស្សល្ងង់មិនមានចំណេះដឹង ហើយធ្វើការអោយរបបនេះដែលមេដឹកនាំបញ្ជាឱ្យខ្មែរសំលាប់ខ្មែរ។

នាយប់នោះ គាត់បានបញ្ជាឱ្យទាហានក្មេងៗមកផ្ទះចាប់ខ្ញុំ។ ប្រហែលជាម៉ោង៨យប់ពេលខ្ញុំកំពុងរៀបចំដេក។ ម្ដាយរបស់ខ្ញុំបានសួរថាហេតុអ្វីបានជាយកខ្ញុំទៅ វាបានឆ្លើយថា "កូនស្រីមីងមានកំហុស"។ ម្ដាយខ្ញុំបន្តថា "តើវាមានកំហុសអី?" គេឆ្លើយថា "គាត់ប្រកែកមិនព្រមរៀបការ"។ ខ្ញុំបានដឹងយ៉ាងជាក់ថាបងថ្លៃរបស់ខ្ញុំជាអ្នកទទួលខុសត្រូវលើទង្វើនេះ។ គេចងខ្ញុំហើយគេបង្ខំអោយខ្ញុំឡើងឡានដែលមានស្ត្រី៤ទៅ៥នាក់នៅក្នុងឡាននោះដែរ។

៤១
សូមមើលសទ្ទានុក្រម អ្នក "ថ្មី" និង អ្នក "មូលដ្ឋាន"

៤២
មានសាច់ថ្លៃពីរនាក់នៅក្នុងរឿងនេះ។ ប្អូនថ្លៃជាកម្មាភិបាលខ្មែរក្រហម ដែលបានរួមចំណែកក្នុងការបាត់ដំណឹងប្ដីរបស់មសអ។ បងថ្លៃ គឺជាអ្នកដែលលេចចេញបន្ទាប់ក្នុងសាច់រឿង ដែលជាមន្ត្រីស្រុក ដែលមើលការខុសត្រូវក្នុងការផ្គត់ផ្គង់ ហើយជាអ្នកមានបំណងបង្ខំមសអ អោយរៀបការនឹងគាត់

យើងបានទៅដល់គុកនៅវត្ត xx នៅម៉ោង១០យប់ ហើយទាហានស្រែក ឱ្យខ្ញុំ ហើយស្ត្រីផ្សេងទៀតហក់ចុះពីឡាន។ ខ្ញុំត្រូវបានចង ដូច្នេះខ្ញុំដួល ពេលហក់ចុះពីឡាន។ គេស្រែកអោយខ្ញុំ "តើមិត្តឯងចង់ស្លាប់ឬ? ក្រោកឈរឡើង!" គេនាំយើងទៅក្នុងគុក ហើយដាក់ច្រវាក់យើង។ មានមនុស្សប្រហែលជា១០នាក់នៅទីនោះ មានស្រីមានប្រុសនៅកន្លែង ជាមួយខ្ញុំ។ មានទាហានក្មេងៗប្រហែលជា៧នាក់បានចូលមករំលោភ អ្នកជាប់គុកដែលទើបនឹងមកដល់រួមទាំងខ្ញុំផងដែរដោយប្រើមេជើង របស់គេ។ ទាហានទាំងនោះអាយុប្រហែលជា២០ឆ្នាំឬក្មេងជាងនេះ។ គេស្រែកឱ្យខ្ញុំ និងស្ត្រីដទៃទៀតឱ្យស្រាតសំពត់ចេញ ហើយគេចាប់ផ្ដើម រុញមេជើងរបស់គេទៅក្នុង[ទ្វារមាស] របស់យើង។ គេតែងតែធ្វើបែប នេះមកលើអ្នកជាប់គុកថ្មី។ ខ្ញុំអាយុប្រហែលជា២៨ឆ្នាំក្នុងពេលនោះ។

**មីងបាននិយាយថាមានបុរសនៅក្នុងកន្លែងនោះដែរ។ តើគេបានឃើញ ទាហានចាប់រំលោភស្ត្រីទាំងនោះដែរឬទេ?**

គេច្បាស់ជាបានដឹងហើយ ពីព្រោះគេនៅក្បែរស្ត្រីជាប់គុកនោះដែរ ហើយអាចឃើញអ្វីៗកើតឡើងទាំងអស់នៅក្នុងគុកនោះ។ ខ្ញុំមាន អារម្មណ៍ខឹងណាស់ ហើយខ្មាស់ណាស់។ ប្រសិនបើអាចតតាំងបាន ខ្ញុំនឹងតតាំងហើយ។ ខ្ញុំមិនយល់ថាហេតុអ្វីបានជាគេធ្វើដាក់ខ្មែរអាក្រក់ យ៉ាងនេះ។ ខ្ញុំមិនចង់ឃើញរឿងអាក្រក់បែបនេះកើតឡើងម្ដងទៀត នោះទេ។

**តើបុរសត្រូវបានគេរំលោភដែរមែនទេ?**

ខ្ញុំមិនបានឃើញគេរំលោភបុរសទេ ប៉ុន្តែខ្ញុំឃើញបុរសត្រូវគេវាយ និងធ្វើ ទារុណកម្មក្នុងពេលសួរចំលើយ។ យើងមិនអនុញ្ញាតឱ្យនិយាយរកគ្នា នោះទេ បើមិនដូច្នេះទេអ្នកយាមនឹងវាយយើង ប៉ុន្តែយើងនៅអាចខ្សឹប គ្នាបាន។ ខ្ញុំបានសួរទៅអ្នកជាប់គុកផ្សេងៗទៀតអំពីការចាប់រំលោភ។ គេនិយាយថា វារំលោភតែអ្នកជាប់គុកថ្មីៗហើយតែម្ដងប៉ុណ្ណោះក្នុងយប់ ដំបូង។ គេបានប្រាប់ខ្ញុំថាមនុស្សនៅក្នុងគុកនេះជាអ្នកដែលបដិសេធមិន

រៀបការ លួចបាយ និងផ្សេងៗទៀត។

ខ្ញុំត្រូវបានគេរំលោភនាយប់ដំបូង ហើយបន្ទាប់មក២ ទៅ៣ថ្ងៃ ខ្ញុំត្រូវបាន ឮគេបញ្ជូនទៅគុកធំនៅ xx។ គុកនោះគឺជាវត្តដែលព័ទ្ធជុំវិញដោយដើមឈើ ហើយស្ងាត់ណាស់។ ប៉ុន្តែមិនមានព្រះសង្ឃនៅទីនោះទេ មានតែអ្នកជាប់គុក ទាហាន និងអ្នកយាម។ អ្នកជាប់គុកស្រីៗ និងប្រុសៗត្រូវបានដាក់ក្នុងកន្លែងតែមួយ។ ពេលខ្ញុំទៅដល់គេបានសួរចំលើយខ្ញុំថា "ហេតុអ្វីបានជាអ្នកជាប់គុក?" ខ្ញុំឆ្លើយតាមត្រង់ថា "ខ្ញុំមិនព្រមរៀបការជាមួយបងថ្លៃខ្ញុំ"។ គេទុកខ្ញុំនៅទីនោះ រយៈពេល៤ថ្ងៃ ហើយបន្ទាប់មកគេដោះលែងខ្ញុំអោយទៅធ្វើការជាមួយមនុស្សដទៃទៀតនៅ xx។ មានមនុស្សរាប់រយនាក់កំពុងធ្វើការទាំងអ្នកមូលដ្ឋាន និងអ្នកថ្មី ជីកប្រឡាយសំរាប់ធ្វើទំនប់។ រាល់យប់បន្ទាប់ពីបបរពេលល្ងាចរួចយើងឃើញកម្មាភិបាលនាំមនុស្ស១០នាក់ ឬច្រើនជាងនេះទៅសំលាប់។ ពេលខ្ញុំទៅដល់ខ្ញុំសួរអ្នកជាប់គុកផ្សេងទៀត "តើទាហានលន់នល់ត្រូវបានគេយកទៅណា?" អ្នកជាប់គុកម្នាក់—គាត់ជាអតីតខ្មែរក្រហម—និយាយថា "កុំរំពឹងថា គេនឹងអាចត្រឡប់មកវិញឱ្យសោះ"។ បន្ទាប់មក ខ្ញុំកាន់តែច្បាស់ថែមទៀតថាប្តីរបស់ខ្ញុំបានស្លាប់ហើយ។

> *មានអារម្មណ៍ខឹងណាស់ ហើយខ្មាស់ណាស់។ ប្រសិនបើអាចតតាំងបានខ្ញុំនឹងតតាំងហើយ។ ខ្ញុំមិនយល់ថាហេតុអ្វីបានជាគេធ្វើដាក់ខ្មែរអាក្រក់យ៉ាងនេះ។*

គេបានអោយខ្ញុំជញ្ជូនគ្រឿងទៅអាគារមួយដែលកំពុងតែរៀបចំសំរាប់ស្តេចសីហនុ។ ខ្ញុំជញ្ជូនកំរាលពូកនិងវាំងននហើយបោសសំអាតជញ្ជាំង។ ខ្ញុំធ្វើការងារនេះរាល់ថ្ងៃរហូតដល់អ្វីទាំងអស់រួចរាល់។ សព្វថ្ងៃនេះ កន្លែងនោះក្លាយទៅជាសណ្ឋាគារ។

ខ្ញុំដេកនៅក្នុងគុកពេលយប់ហើយចេញទៅធ្វើការពេលថ្ងៃ។ ថ្ងៃមួយទាហានខ្មែរក្រហមបានសួរថា "តើមានអ្នកណាចេះច្រូតស្រូវ?" ខ្ញុំបានប្រាប់គេថាខ្ញុំអាចធ្វើបាន ហើយខ្ញុំក៏ត្រូវបានឱ្យទៅគុកផ្សេងទៀតជាមួយអ្នកជាប់គុកដទៃទៀតដើម្បីអោយច្រូតស្រូវ។ វាលស្រែដែលខ្ញុំ

ធ្វើការគឺចំងាយ មួយគីឡូម៉ែត្រពីកន្លែងដែលម្តាយ និងកូនប្រុសខ្ញុំរស់នៅ។ ខ្ញុំចង់ទៅលេងពួកគេណាស់ ប៉ុន្តែខ្ញុំដឹងថាខ្ញុំមិនអាចទៅបានទេ បើមិនដូច្នេះទេ ខ្ញុំនឹងបង្កបញ្ហាអោយពួកគេ។ ដូច្នេះខ្ញុំនៅឆ្ងាយពីពួកគេ ទោះបីជាខ្ញុំនៅជិតយ៉ាងណាក៏ដោយ។ កំឡុងពេលនោះខ្ញុំបានជួបប្អូនប្រុសថ្លៃរបស់ខ្ញុំដែលគាត់ជាទាហាន។ គាត់បានប្រាប់ម្តាយខ្ញុំថាខ្ញុំនៅរស់ ហើយម្តាយខ្ញុំភ្ញាក់ផ្អើលណាស់ពីព្រោះគាត់ដាក់ច្បាស់ថាខ្ញុំបានស្លាប់ហើយ។

ការងារនៅគុកថ្មីគឺពិបាកណាស់។ អ្នកជាប់គុក៧នាក់ត្រូវបានបញ្ជាឱ្យច្រូតស្រូវមួយហិចតាក្នុងមួយថ្ងៃ។ បន្ទាប់មកវាកាត់បន្ថយមនុស្សមកត្រឹម៥នាក់មួយហិចតាមួយថ្ងៃ។ ថ្ងៃមួយខ្ញុំបានដឹងថា ខ្ញុំត្រូវបានគេកំណត់ពេលសំលាប់ខ្ញុំនៅ៣ថ្ងៃបន្ទាប់។ ខ្ញុំនៅបន្តច្រូតរាល់ថ្ងៃ ហើយ ២ឬ៣ថ្ងៃបន្ទាប់មកខ្ញុំបានឮសំលេងគ្រាប់បែកផ្ទុះឡើង។ បុរសចាស់ម្នាក់គាត់ជាអ្នកមូលដ្ឋានដែលជាអ្នកមើលគោដើរមកជិតកាន់វិទ្យុ។ គាត់បានអោយខ្ញុំស្តាប់វិទ្យុជាមួយគាត់ ហើយពត៌មាននោះគឺវៀតណាមដណ្តើមបានភ្នំពេញ កំពង់ធំ និងសៀមរាបហើយ។ ខ្ញុំមិនអាចស្តាប់ជិត និងបានយូរទេ ពីព្រោះខ្ញុំខ្លាចអ្នកយាមសំលាប់ ប៉ុន្តែខ្ញុំបានឮ "ប្រជាជនកម្ពុជាកុំខ្លាច ជយោ ជយោ កម្ពុជាត្រូវបានរំដោះហើយ!" ខ្ញុំគិតថាយើងត្រូវបានគេសង្គ្រោះហើយ ហើយបុរសចាស់នោះមានការភ័យខ្លាចណាស់ គាត់រត់ចោលគោរបស់គាត់។

ខ្ញុំឈប់ធ្វើការក្នុងស្រែហើយទៅសហករវិញ—វាច្របូកច្របល់ណាស់។ ទាហានខ្មែរក្រហមខ្លះរត់គេចដោយគ្មានអាហារ ពីព្រោះពួកគេខ្លាច។ ខ្ញុំបានសំរេចចិត្តថាខ្ញុំនឹងចាកចេញ ហើយធ្វើដំនើរទៅភូមិស្រុកវិញ។ នៅ តាមផ្លូវខ្ញុំបានឃើញចាមវាយក្នុងសមរភូមិជាមួយនឹងខ្មែរក្រហមដោយប្រើដាវ និងកាំបិតពេលខ្ញុំបានឃើញខ្ញុំបានគ្រវែងចោលរបស់របរដែលខ្ញុំបានយកមកពីសហករ [ក្នុងករណីដែលគេតាមខ្ញុំ]។ ទីបំផុតខ្ញុំបានទៅដល់ផ្ទះ ហើយបានជួបម្តាយនិងកូនប្រុស។ កូនប្រុសរបស់ខ្ញុំ

មិនបានស្គាល់ខ្ញុំទេ ពីព្រោះយើងបានបែកគ្នាយូរពេក។

**មីងបាននៅជាប់គុកបីកន្លែងដោយសារតែមីងប្រកែកមិនរៀបការ។ តើមីងបានគិតដល់ ថាមីងនឹងត្រូវទទួលគេពិន័យបែបនេះដែរឬទេ?**

ចាស ខ្ញុំបានដឹងយ៉ាងច្បាស់ថាខ្ញុំអាចនឹងស្លាប់ឬអាក្រក់នឹងកើតមាន។ ខ្ញុំបានគិតថា ប្រសិនបើខ្ញុំរស់ឬស្លាប់វាមិនជាបញ្ហាទេសំរាប់ខ្ញុំ។ ការស្លាប់ប្រហែលជាមានន័យជាង ពីព្រោះខ្ញុំគ្មានសិទ្ធសេរីភាពទេនាពេលនោះ។ ពេលខ្មែរក្រហមចង់សំលាប់ គេសំលាប់ ហើយមិនមានហេតុផលអ្វីទាំងអស់។ កាលពីមុន ពេលខ្ញុំនឹកឃើញដល់រឿងពីមុនខ្ញុំមិនធ្វើអ្វីបានទេ គឺមានតែយំ។ ឥឡូវនេះខ្ញុំបានទទួលការគាំទ្រផ្លូវចិត្តនិងអាចគ្រប់គ្រងអារម្មណ៍បាន។ ពេលដំបូងដែលខ្ញុំនិយាយពីបទពិសោធន៍របស់ខ្ញុំ [ជាមួយនឹងអ្នកវិជ្ជាជីវៈចិត្តសាស្ត្ររបស់ធីភីអូ] ខ្ញុំយំភ្លាម ប៉ុន្តែបន្ទាប់មកបានមានអារម្មណ៍រំភើបនឹងការរស់នៅក្នុងជំនាន់មួយថ្មីទៀតពីព្រោះជីវិតរបស់ខ្ញុំមានតំលៃ ហើយខ្ញុំមានសិទ្ធអាចធ្វើការកន្លែងដែលខ្ញុំចង់ធ្វើនិងធ្វើអ្វីដែលខ្ញុំចង់ធ្វើ។ ចាស ម្យ៉ាងវិញទៀតខ្ញុំមានអារម្មណ៍ថា ជីវិតរបស់ខ្ញុំភ្លឺថ្លាណាស់ឥឡូវនេះ ហើយម្យ៉ាងមួយទៀតខ្ញុំគិតថាខ្ញុំ ប្រហែលជាធ្វើអំពើល្អពីជាតិមុនហើយ ដូច្នេះហើយបានជាខ្ញុំអាចរស់រានមានជីវិតបានរហូតដល់សព្វថ្ងៃ។ ទោះបីជាការស្លាប់គឺនៅនឹងមុខខ្ញុំទៅហើយ ខ្ញុំមិនខ្លាចការស្លាប់ទេ។

ឥឡូវនេះបងថ្លៃប្រុសរបស់ខ្ញុំ ដែលជាប្ដីរបស់បងស្រីខ្ញុំបានស្លាប់ហើយដោយសារជំងឺ។ មុនពេលគាត់ស្លាប់ គាត់បានសុំឱ្យខ្ញុំថែរក្សាកូនប្រុសរបស់គាត់ដែលត្រូវជាក្មួយរបស់ខ្ញុំ។ គាត់ចង់អោយកូនប្រុសរបស់គាត់បានរៀនសូត្រនៅវិទ្យាល័យនៅក្នុងភូមិរបស់ខ្ញុំ។ ខ្ញុំមិនចង់ឱ្យកូនប្រុសបងថ្លៃខ្ញុំរស់នៅជាមួយខ្ញុំនោះទេដោយសារតែខ្ញុំចាត់ ទុកគាត់ជាកូនរបស់សត្រូវខ្ញុំ។ ប៉ុន្តែម្ដាយរបស់ខ្ញុំយំហើយបានអង្វរខ្ញុំឱ្យអាណិតចៅកំព្រារបស់គាត់។ បងថ្លៃខ្ញុំបាននាំកូនមកផ្ទះខ្ញុំ៤ទៅ៥ដង ហើយខ្ញុំមិនបានចាប់អារម្មណ៍ក្នុងការជួបគាត់ឬនិយាយជាមួយគាត់នោះទេ ហើយខ្ញុំ

តែងតែគេចចេញពីផ្ទះរាល់ពេលទាំងនោះ។ ខ្ញុំបានប្រកែកមិនទៅបុណ្យសពរបស់បងថ្លៃខ្ញុំ ប៉ុន្តែម្តាយខ្ញុំបាននិយាយឲ្យធ្វើរឿងត្រឹមត្រូវវាប្រសើរជាង ដូច្នេះទីបញ្ចប់ខ្ញុំក៏ទៅចូលរួមបុណ្យសពនោះ។ គាត់បានរៀបការម្តងទៀត ហើយមានកូន២នាក់ជាមួយនឹងប្រពន្ធថ្មីរបស់គាត់។

តាមពិតទៅ ខ្ញុំបានចាត់ទុកថាក្មួយរបស់ខ្ញុំដែលជាកូនរបស់បងស្រីខ្ញុំមិនទាក់ទងនឹងអ្វីដែលបានកើតលើខ្ញុំក្នុងរបបខ្មែរក្រហមនោះទេ ដូច្នេះខ្ញុំបានសំរេចចិត្តឱ្យគាត់រស់នៅជាមួយខ្ញុំ។ ពេលគាត់មកដំបូង គាត់មានកន្ទបខោអាវកខ្វក់។ ដូច្នេះខ្ញុំបានថែរក្សាគាត់ ហើយជួយឱ្យគាត់រៀនចប់អនុវិទ្យាល័យ។ គាត់បានក្លាយជាប៉ូលីស ហើយខ្ញុំបានជួយគាត់ឱ្យសំរេចបំណងរបស់គាត់។ ចំណែកឯកូនប្រុសរបស់ខ្ញុំវិញ គាត់បានស្លាប់នៅអាយុ២០ឆ្នាំដោយសារជំងឺរលាក់ខួរក្បាល។

**តើមីងបានជួយខ្លួនឯងដោយវិធីណាបន្ទាប់ពីរបបខ្មែរក្រហមបានបញ្ចប់? តើមីងបានរៀបការម្តងទៀតទេ?**

ចាស ខ្ញុំបានរៀបការម្តងទៀតហើយមានកូន២នាក់។ មានគេផ្តល់ការងារនៅមន្ទីរពេទ្យខេត្តឱ្យខ្ញុំធ្វើនៅ xx ប៉ុន្តែម្តាយរបស់ខ្ញុំខ្លាចថាមានខ្មែរក្រហម ត្រឡប់មកវិញម្តងទៀតគាត់មិនចង់អោយខ្ញុំធ្វើការនោះទេ។ ដោយសារតែគាត់ត្រូវចិញ្ចឹមកូនប្រុសខ្ញុំតែម្នាក់ឯង ខ្ញុំសំរេចចិត្តមិនធ្វើ។ ខ្ញុំបានធ្វើការមួយនៅក្នុងពេទ្យ xx ជាមួយនឹងអតីតចៅហ៊ាយរបស់ខ្ញុំ ហើយម្តាយរបស់ខ្ញុំយល់ព្រម។ ខ្ញុំអាចរកបានបាយម្ហូប និងប្រាក់ចំណូលគ្រប់គ្រាន់សំរាប់ឧបត្ថម្ភក្នុងគ្រួសារបានដោយរួមបញ្ចូលទាំងម្តាយខ្ញុំកូនប្រុសខ្ញុំ និងកូនប្រុសបងថ្លៃខ្ញុំដែលធ្លាប់ជាទាហាខ្មែរក្រហម។ ខ្ញុំត្រូវដើរចំងាយប្រហលជា៧គីឡូម៉ែត្រពីផ្ទះទៅមន្ទីរពេទ្យ។ ខ្ញុំធ្វើការជាគិលានុបដ្ឋាយិកា។

ខ្ញុំរៀបការនៅឆ្នាំ១៩៨០។ ប្តីថ្មីរបស់ខ្ញុំក៏ធ្វើការនៅមន្ទីរពេទ្យដែរ។ មុនដំបូងខ្ញុំមិនចង់រៀបការទៀតទេពីព្រោះខ្ញុំខ្លាចប្តីរបស់ខ្ញុំធ្វើបាបកូនប្រុសខ្ញុំ។ បន្ទាប់មកម្តាយក្មេករបស់ខ្ញុំបានមកបញ្ចុះបញ្ចូលខ្ញុំថាកូនរបស់គាត់

ជាមនុស្សល្អចិត្តបាន។ ម្តាយរបស់ខ្ញុំក៏ចង់អោយខ្ញុំរៀបការដែរ។ ខ្ញុំនៅស្ទាក់ស្ទើរដោយសារតែកូនប្រុសរបស់ខ្ញុំ ហើយខ្ញុំលើកហេតុផលថា ខ្ញុំអាចចិញ្ចឹមគ្រួសាររបស់ខ្ញុំបានទៅលើចំណាយក្នុងគ្រួសារ ដូច្នេះខ្ញុំមិនចាំបាច់រៀបការម្តងទៀតទេ ប៉ុន្តែមានសំពាធខ្លាំងណាស់ពីគ្រួសារ ហើយទីបំផុតខ្ញុំបានសំរេចចិត្តរៀបការជាមួយគាត់។ ខ្ញុំបានស្វែងយល់ខ្លួនឯងយល់ឃើញថាគាត់គឺជាបុរសល្អម្នាក់។ ពេលធ្វើការជាមួយគ្នា យើងនិយាយគ្នាអំពីបទពិសោធន៍ក្នុងរបបខ្មែរក្រហម។ ខ្ញុំបានប្រាប់គាត់ពីរឿងរ៉ាវរបស់ខ្ញុំ គាត់បាននិយាយថាមានករណីធ្ងន់ធ្ងរជាងករណីរបស់ខ្ញុំនេះច្រើនណាស់។ គាត់បាននិយាយថា មានបញ្ហាធ្ងន់ធ្ងរសំរាប់ស្ត្រីនៅក្នុងគុក។ រហូតដល់ពេលនោះខ្ញុំមិនដែលបានប្រាប់ម្តាយរបស់ខ្ញុំពីបទពិសោធន៍រំលោភរបស់ខ្ញុំនោះទេ ប៉ុន្តែខ្ញុំបានប្រាប់ប្តីខ្ញុំ។ គាត់ទទួលយកអតីតកាលរបស់ខ្ញុំ។ ខ្ញុំមានកូនប្រុសមួយ និងកូនស្រីមួយជាមួយគាត់។

“ *រហូតដល់ពេលនោះខ្ញុំមិនដែលបានប្រាប់ម្តាយរបស់ខ្ញុំពីបទពិសោធន៍រំលោភរបស់ខ្ញុំនោះទេ ប៉ុន្តែខ្ញុំបានប្រាប់ប្តីខ្ញុំ។ គាត់ទទួលយកអតីតកាលរបស់ខ្ញុំ។ ខ្ញុំមានកូនប្រុសមួយ និងកូនស្រីមួយជាមួយគាត់។*

**តើកូនរបស់មីងដឹងរឿងអតីតកាលរបស់មីងដែរឬទេ?**

ទោះបីជាខ្ញុំបានប្រាប់គេពីរឿងរ៉ាវនារបបខ្មែរក្រហម ប៉ុន្តែខ្ញុំមិនបានប្រាប់គេពីការរំលោភនោះទេ។ ខ្ញុំតែងតែនិយាយថា "កូនសំណាងហើយដែលកើតក្នុងជំនាន់ក្រោយ ជីវិតវាលំបាកណាស់ក្នុងរបបខ្មែរក្រហម។ គួរតែធ្វើអ្វីដែលល្អៗក្នុងជីវិតទៅ!" ខ្ញុំមិនបានខ្មាស់អៀនចំពោះអ្វីដែលបានកើតឡើងក្នុងជីវិតរបស់ខ្ញុំនោះទេ ប៉ុន្តែខ្ញុំមិនចង់ប្រាប់ពួកគេអោយដឹងពីព្រោះខ្ញុំខ្លាចគេសងសឹក។ សព្វថ្ងៃនេះកូនប្រុសរបស់ខ្ញុំអាយុ៣១ឆ្នាំ ហើយកូនស្រីរបស់ខ្ញុំអាយុ២៨ឆ្នាំ។ គេទាំងពីរបានរៀបការ ហើយមានកូនម្នាក់មួយ។

# ករណីសិក្សា ៨

គណ ភេទស្រី អាយុ ៥៧ឆ្នាំ
សំភាសន៍នៅថ្ងៃទី ២៨ មិថុនា ២០១៤
នៅផ្ទះរបស់គាត់។ គាត់ជាជនជាតិខ្មែរចាម (អ៊ីស្លាម)

**តើមីងអាចប្រាប់ខ្ញុំអំពីជីវិតរបស់មីងមុនខ្មែរក្រហមកាន់អំណាចបានដែរឬទេ?**

ពេលខ្ញុំនៅជាក្មេងស្រី ខ្ញុំមិនបានទៅរៀនទេ។ ខ្ញុំជួយម្តាយខ្ញុំលក់ត្រី។ យើងរស់នៅក្នុងសហគមន៍ចាម។ ខ្ញុំមានអាយុ១៧ឆ្នាំពេលខ្មែរក្រហមឡើងកាន់អំណាច ហើយខ្ញុំនៅក្នុងកងចល័តក្នុងភូមិ xx ។

**មីងបាននិយាយនៅក្នុងការស្រង់មតិថា មីងត្រូវបានគេបង្ខំអោយរៀបការ។ តើមីងអាច រៀបរាប់បានទេ?**

ចាស ខ្ញុំត្រូវបានគេបង្ខំឱ្យរៀបការនៅឆ្នាំ១៩៧៨ពេលខ្ញុំមានអាយុ២១ឆ្នាំ។ គេបានសុំអោយខ្ញុំរៀបការពីរដងតែខ្ញុំប្រកែក ដល់លើកទី៣គេបានប្រាប់ខ្ញុំថា ប្រសិនបើខ្ញុំមិនព្រម ខ្ញុំនឹងត្រូវគេសំលាប់។ ដូច្នេះចុងបញ្ចប់ខ្ញុំក៏យល់ព្រម។ ខ្ញុំបានដឹងនៅពេលសំរាកថ្ងៃត្រង់ពេលធ្វើការនៅវាលស្រែថាខ្ញុំនឹងត្រូវ "ប្តេជ្ញា" បន្ទាប់ពីធ្វើការរួច។ កម្មាភិបាលបាននិយាយថា "ល្ងាចនេះបន្ទាប់ពីធ្វើការរួចមិត្តត្រូវតែទៅប្តេជ្ញា"។ ខ្ញុំបានយល់ថាគេមានន័យថាការរៀបការ ប៉ុន្តែខ្ញុំមិនបានដឹងថាអ្នកណាទេ។ នោះវាធ្វើឱ្យខ្ញុំក្តុកក្តួល និងភ័យខ្លាចណាស់។

ពិធីធ្វើឡើងនៅម៉ោងប្រហែលជា៧យប់នៅផ្ទះប្រធានភូមិ។ មាន២០គូ កម្មាភិបាល ជាអ្នករៀបចំពិធីឱ្យ។ គេបានប្រាប់យើងថាឱ្យចូលជាក្រុមដោយគោរពតាមពណ៌*ក្រមា* [កន្សែងប្រពៃណី]។ មានគូច្រើននៅក្នុងពិធីប្តេជ្ញា ហើយមនុស្សខ្លះបានច្រឡំគូគ្នា។ កម្មាភិបាលបានហៅឈ្មោះយើងឱ្យឡើងមក ហើយប្រាប់យើងអោយនិយាយ២ទៅ៣ពាក្យដើម្បីប្តេជ្ញាទៅកាន់ដៃគូ។ ខ្មែរនិងចាមត្រូវបានគេចាប់ឱ្យគូគ្នា ដូចករណីរបស់

ខ្ញុំអញ្ចឹង។ ប្តីរបស់ខ្ញុំនិងខ្ញុំជាមនុស្សចំលែកមិនស្គាល់គ្នា គាត់មានស្បែកខ្មៅហើយស្គម។ ពិធីទាំងមូលមានរយៈពេលប្រហែលមួយម៉ោង មិនយូរទេ (សើច)។ ខ្ញុំសើចពីព្រោះវាចំលែកក្នុងរបបនោះ។ ខ្ញុំខ្លាចពីព្រោះខ្ញុំមិនស្គាល់ប្តីរបស់ខ្ញុំ ហើយខ្ញុំក្តុកក្តួលពីព្រោះខ្ញុំជាស្រ្តី ប៉ុន្តែខ្ញុំយល់ព្រមពីព្រោះខ្ញុំមិនចង់ឲ្យគេសំលាប់។

**តើការរៀបការដូចម្តេចដែរនៅក្នុងសហគមន៍ចាម? តើមីងអាចរៀបការជាមួយនឹងខ្មែរដែលកាន់សាសនាព្រះពុទ្ធបានដែរ ឬក៏ខ្មែរអ៊ីស្លាមគួរតែត្រូវរៀបការតែជាមួយនិងខ្មែរអ៊ីស្លាម?**

ចាស ជាទូទៅរៀបការតែជាមួយខ្មែរអ៊ីស្លាមទេ ប៉ុន្តែប្រសិនបើអ្នកណាម្នាក់ចង់រៀបការក្រៅសាសនា យើងក៏មិនបន្ទោសគេដែរ។ ស្រ្តីខ្លះរៀបការហើយប្តីរបស់គេនឹងចូលប្រតិបត្តិសាសនាអ៊ីស្លាម និងប្រពៃណីអ៊ីស្លាម។ អ្នកខ្លះទៀតរៀបការជាមួយនឹងខ្មែរ ហើយបន្ទាប់មកធ្វើតាមប្តី ហើយបោះបង់អត្តសញ្ញាណជាចាម។ វាអាស្រ័យទៅលើគូនិមួយៗប៉ុណ្ណោះ។

**តើមានអ្វីកើតឡើងបន្ទាប់ពីពិធីប្តេជ្ញា?**

បន្ទាប់ពីពិធី គេបានឱ្យបន្ទប់យើងមួយនៅក្នុងរោងស្រូវ។ គេបានសង់បន្ទប់សំរាប់ពួកយើង។ វាធ្វើពីឈើហើយជាប់នឹងបន្ទប់ផ្សេងៗទៀត ប៉ុន្តែមិនជិតនោះទេអាចមើលគ្នាឃើញ។ ប្តីរបស់ខ្ញុំបានសួរខ្ញុំថា "ឯងបានប្តេជ្ញាជាមួយនឹងខ្ញុំហើយ ដូច្នេះតើមានស្រឡាញ់ខ្ញុំដែរឬទេ?" ខ្ញុំបាននិយាយថា "ទោះបីខ្ញុំមិនស្រឡាញ់ ហើយមិនសប្បាយចិត្តនឹងការរៀបការនោះ ខ្ញុំមិនអាចធ្វើអ្វីបានទេ។" គាត់បានឆ្លើយថា "វាជាបញ្ជារបស់អង្គការ ដូច្នេះយើងត្រូវតែធ្វើតាម"។

យើងបានពិភាក្សាគ្នានាយប់នោះ ហើយយល់ព្រមរវាងគ្នានិងគ្នា [មានទំនាក់ទំនងផ្លូវ ភេទ] ពីព្រោះកម្មាភិបាលបានគំរាមយើងថាប្រសិនបើយើងមិនចុះសំរុងគ្នាទេ គេនឹងយកយើងទៅសំលាប់។ ប្តីរបស់ខ្ញុំបាននិយាយថា "ប្រសិនបើយើងមិនត្រូវរ៉ូវគ្នា យើងនឹងត្រូវសំលាប់ ពេលនោះ

ឈ្លបកំពុងតែលបស្តាប់យើង។" គាត់មិនបានបង្ខំខ្ញុំទេ ហើយខ្ញុំខ្លាចក្នុងការរួមភេទ ដោយសារតែខ្ញុំមិនបានដឹងថាតើវាធ្វើយ៉ាងម៉េចនោះទេ។ យើងបានរស់នៅជាមួយគ្នាបានមួយសប្តាហ៍ ហើយគេបានបំបែកយើងទៅធ្វើការនៅកន្លែងផ្សេងៗ បន្ទាប់មកយើងអាចជួបគ្នាមួយខែម្តង។

## តើមីងមានកូនក្នុងកំឡុងពេលរៀបការដែរឬទេ?

យើងមិនមានអ្វីហូបទេ ប៉ុន្តែខ្ញុំបានដឹងថាប្រសិនបើយើងរួមភេទ ខ្ញុំអាចនឹងមានផ្ទៃពោះ ហើយខ្ញុំមិនបានដឹងពីវិធីការពារនោះទេ ឬការរំលូតនោះដែរ។ គ្មានថ្នាំនិងគ្មានពេទ្យទេ ហើយប្រសិនបើ*អង្គការ*ដឹង [អំពីការចង់រំលូតកូន] ខ្ញុំគិតថាខ្ញុំនឹងមានបញ្ហាហើយ។ ខ្ញុំមានកូនបីនាក់ពីពេលនោះមក។

## មីងបាននិយាយថាប្តីរបស់មីងគឺខ្មែរ?

ចាស គាត់ជាខ្មែរ។ គាត់បានស្តាប់តាមខ្ញុំមិនដូចបុរសផ្សេងដែលខ្ញុំធ្លាប់បានឃើញនោះទេ។ ខ្ញុំបានដឹងថា ខ្ញុំខុសដែលបានរៀបការនឹងគាត់ ដោយសារតែខ្ញុំជាចាម ហើយព្រះអាឡោះបង្រៀនថាយើងគួរតែរៀបការជាមួយនឹងមូស្លីម ប៉ុន្តែពេលនោះតើយើងអាចធ្វើអ្វីបាន? គេបានបង្ខំខ្ញុំ ហើយខ្ញុំក៏អត់ទ្រាំទៅ។ ដំបូងប្តីរបស់ខ្ញុំគាត់មិនអីទេ គាត់ស្តាប់ខ្ញុំ ប៉ុន្តែយើងមិនមានទំនាក់ទំនងល្អទេហើយវាពិបាកក្នុងការនិយាយជាមួយគ្នាណាស់ក្រោយមក។

ខ្ញុំបានតាំងចិត្តថា ខ្ញុំនឹងមិននៅជាមួយគាត់នោះទេបន្ទាប់ពីរបបនេះចប់។ ខ្ញុំចង់ទៅសហគមន៍ចាមរបស់ខ្ញុំវិញ ហើយគាត់មិនមែនចាមទេ។ ប្រសិនបើខ្ញុំតាមគាត់ ខ្ញុំនឹងត្រូវលះបង់អត្តសញ្ញាណរបស់ខ្ញុំក្នុងសហគមន៍។ ប៉ុន្តែគាត់បានតាមខ្ញុំត្រឡប់ទៅភូមិវិញ ហើយបានប្តូរទៅជាសាសនារបស់ខ្ញុំ ខ្ញុំអាចនឹងបែកពីគាត់ទៅហើយ ដោយសារតែគ្មាននរណាម្នាក់ក្នុងសហគមន៍ទុកចិត្តគាត់ទេ ហើយខ្ញុំបានតាំងចិត្តរស់នៅជាចាម។ ប្រសិនបើយើងតាមព្រះអាឡោះ មិនថាយើងស្លាប់ឬរស់ សហគមន៍ចាមនឹងថែរក្សាយើង ហើយយើងនៅជាសមាជិកក្នុងសហគមន៍ជារៀងរហូត។

ប្រសិនបើខ្ញុំតាមប្តី ហើយលះបង់សហគមន៍ចាម ម្តាយរបស់ខ្ញុំនឹងមិនទុកខ្ញុំជាកូនស្រីរបស់គាត់ទៀតទេ ហើយគាត់នឹងមិនមានកត្តិយសល្អក្នុងសហគមន៍ចាមទៀតដែរ។ ម្តាយរបស់ខ្ញុំមិនបានដឹងពីការរៀបការនេះទេ រហូតដល់របបនោះរលំ។ ពេលប្តីរបស់ខ្ញុំយល់ព្រមតាមសាសនារបស់យើង គាត់មិនបាននិយាយអ្វីពីការរៀបការនេះទេ។ គាត់និងចាស់ទុំបានរៀបចំពិធីសំរាប់ប្តីខ្ញុំដើម្បីក្លាយជាចាមដូចខ្ញុំ ហើយទទួលស្គាល់ការរៀបការរបស់យើង។ ខ្ញុំចង់មានការរៀបជាប្រពៃណី ប៉ុន្តែខ្ញុំមានអារម្មណ៍ថាវាយឺតពេលសំរាប់ខ្ញុំ—ខ្ញុំខ្មាស់គេដោយសារ តែយើងមានកូនរួចទៅហើយ។ យើងរស់នៅសប្បាយរហូតដល់ឆ្នាំ១៩៩៣។

## តើរឿងវាផ្លាស់ប្តូរបែបណាដែលក្នុងឆ្នាំ១៩៩៣?

គាត់ចាប់ផ្តើមផឹក ហើយវាយខ្ញុំ។ គាត់បានធ្វើការនៅកន្លែងនេសាទជាមួយនឹងប្រុសៗផ្សេងទៀត។ ជាញឹកញាប់ គាត់ផឹកក្នុងភូមិ ហើយមកផ្ទះវិញ ទារលុយពីខ្ញុំ។ ក្នុងឆ្នាំ ២០០៦ ខ្ញុំបានសំរេចចិត្តលែងលះជាមួយគាត់។ ខ្ញុំជាអ្នកសំរេចចិត្តម្នាក់ឯង។ ខ្ញុំបានប្តឹងទៅប្រធានឃុំឱ្យជួយពីព្រោះខ្ញុំមានការលំបាកណាស់រស់នៅជាមួយនឹងគាត់។ ពេលប្តីរបស់ខ្ញុំបានដឹងពីការលែងលះ គាត់បានគំរាមខ្ញុំដោយកាំបិត ហើយខ្ញុំបានរត់ទៅផ្ទះមេភូមិដើម្បីពួន។ កូនៗរបស់ខ្ញុំសប្បាយចិត្តនឹងការលែងលះនេះ។ វារយៈពេល៨ឆ្នាំហើយ ដែលយើងបានបែកគ្នា ហើយខ្ញុំមិនរៀបការទៀតទេ។

សហគមន៍របស់ខ្ញុំមិនបានបន្ទោសខ្ញុំទេ ដោយសារខ្មែរក្រហមជាអ្នករៀបការឱ្យខ្ញុំជាមួយនឹងបុរសនោះ។ វាដោយសារតែការបង្ខំឱ្យរៀបការបានជាខ្ញុំមិនអាចរៀបការជាមួយបុរសល្អម្នាក់បាន។ ខ្ញុំមិនរៀបការម្តងទៀតទេបន្ទាប់ពីលែងលះរួច ពីព្រោះខ្ញុំខ្លាចថាប្តីក្រោយរបស់ខ្ញុំអាចនឹងធ្វើបាបខ្ញុំម្តងទៀត ហើយមិនធ្វើល្អដាក់កូនខ្ញុំ។ ខ្ញុំបាន ដឹងថាប្រសិនបើខ្ញុំរៀបការម្តងទៀត ខ្ញុំនឹងអាចជ្រើសរើសខ្លួនឯង ហើយម្តាយរបស់ខ្ញុំនឹងរៀបចំមង្គលការឱ្យ។ ខ្ញុំមិនសប្បាយចិត្តពីព្រោះខ្ញុំមិនអាចមានពិធីដូចគេ

ឯងសព្វថ្ងៃ ប៉ុន្តែខ្ញុំកាន់តែមិនសប្បាយចិត្តទៀតនោះគឺប្តីរបស់ខ្ញុំប្រែទៅជាសាហាវ។ ក្នុងករណីដូចខ្ញុំនេះ ខ្ញុំមិនអាចខឹងនឹងម្តាយខ្ញុំនោះទេ ពីព្រោះគាត់មិនមែនជាអ្នករៀបចំអោយខ្ញុំ។[៤៣] ខ្ញុំខឹងនឹងប៉ុលពត[៤៤] ហើយខ្ញុំគិតថាការបង្ខំឱ្យរៀបការក្នុងរបបខ្មែរ ក្រហមគឺអំពើឧក្រិដ្ឋកម្មឃោរឃៅណាស់។

ខ្ញុំបានស្គាល់ស្ត្រីខ្លះៗ គេអាចជួបបុរសល្អៗពីការបង្ខំឱ្យរៀបការក្នុងរបបនោះ ហើយនោះគឺជាសំណាងរបស់គេ។ ខ្ញុំនឹងដឹងគុណរបបនោះ ប្រសិនបើបានជ្រើសរើសប្តីល្អម្នាក់អោយខ្ញុំ។ ប៉ុន្តែដោយសារតែការបង្ខំឱ្យរៀបការជីវិតរបស់ខ្ញុំបានផ្លាស់ប្តូររហូត។ ខ្ញុំបានគិតថា ខ្ញុំនឹងរស់នៅដោយមានភាពសុខដុមប្រកបដោយសុភមង្គលដូចគ្រួសារផ្សេងៗទៀត ដែលមិនដែលមានបញ្ហាអ្វី។ បុរសជាដើមហេតុនៃបញ្ហាក្នុងផ្ទះ យើងជាស្ត្រីសុភមង្គលរបស់យើងគឺស្ថិតនៅលើបុរស។

**តើមីងគិតថាវាមានភាពខុសគ្នារវាងការរៀបការនារបបខ្មែរក្រហម និងការរៀបការដែលរៀបចំដោយឪពុកម្តាយតាមប្រពៃណីដែរឬទេ?**

ចាស ខុសគ្នាខ្លាំងណាស់ ពីព្រោះក្នុងរបបខ្មែរក្រហមយើងមិនបានជ្រើសរើស ហើយយើងទទួលយកដោយស្ថិតនៅក្រោមសំពាធដើម្បីរស់រានមានជីវិត។ ក្នុងការរៀបការតាមបែបប្រពៃណី ឪពុកម្តាយរបស់យើងបានរៀបចំទុកដាក់ឱ្យយើង ប៉ុន្តែទាល់តែកូនយល់ព្រមដែរ។ ប្រសិនបើការរៀបការនេះមិនបានល្អ សហគមន៍នឹងនៅតែគាំទ្រយើង ពីព្រោះការរៀបការ គឺជាសំណាង វាមានសំណាងល្អនិងសំណាងមិនល្អ។ ដូចកូនរបស់ខ្ញុំអញ្ចឹង នាងឥឡូវនេះអាយុ២៥ឆ្នាំហើយហើយលែងលះគ្នា ហើយនាង និងចៅប្រុសរបស់ខ្ញុំបានរស់នៅជាមួយខ្ញុំសព្វថ្ងៃនេះ។

# សទ្ទានុក្រម

| | |
|---|---|
| *អាចារ្យ* | ឧបាសិកាផ្នែកសាសនាក្នុងពិធីមង្គលការប្រពៃណីខ្មែរដែលកំណត់ពីថ្ងៃជោគសំរាប់ការរៀបមង្គលការ និងធ្វើជាអធិបតីក្នុងពិធី |
| *អំបុក* | បង្អែមប្រពៃណីខ្មែរ |
| *អង្គការ* | តាមន័យរបស់ពាក្យ អង្គការយោងទៅលើអង្គភាពដែលធ្វើសេចក្ដីសម្រេចចិត្តខ្ពស់ជាងគេក្នុងរបបខ្មែរក្រហម |
| *អ្នក១៧មេសា* | សូមមើល "មនុស្សថ្មី" ខាងក្រោម |
| *មនុស្សមូលដ្ឋាន* | សំដៅលើអ្នកដែលរស់នៅជនបទ រឺក្នុងតំបន់ដែលគ្រប់គ្រងដោយខ្មែរក្រហមមុនពេលការដួលរលំរាជធានីភ្នំពេញនៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ រឺហៅម្យ៉ាងទៀតថា អ្នកចាស់ ពួកគេត្រូវបានប្រគល់សិទ្ធិជាពលរដ្ឋនៅក្រោមរបបខ្មែរក្រហម។ សូមមើលអ្នកថ្មីដូចខាងក្រោម |
| *បង* | តាមន័យរបស់ពាក្យ បងប្អូនបង្កើត ត្រូវបានប្រើប្រាស់ក្នុងការនិយាយបែបសុជីវធម៌ទៅកាន់នរណាម្នាក់ដែលមានអាយុច្រើនជាង រឺមានឋានៈខ្ពស់ជាងអ្នកនិយាយ។ សូមមើលពាក្យ មីង និងពូដូចខាងក្រោម |
| *បង្ខំរៀបការ* | ការបង្ខំរៀបការ |
| *ឈ្លប* | កងឈ្លបក្នុងមូលដ្ឋានដែលធ្វើការអោយអ្នកស៊ើបការណ៍ខ្មែរក្រហម |

៤៣ ទាំងប្រពៃណីខ្មែរ និងចាម ការរៀបការត្រូវរៀបចំដោយឪពុកម្ដាយសំរាប់កូនដែលម្ដាយជាអ្នកដើរតួដឹកនាំក្នុងការរកគូផ្គូរផ្គង

៤៤ សូមមើលសទ្ទានុក្រម "ប៉ុលពត"

*អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា* ជាតុលាការកូនកាត់កម្ពុជា អង្គការសហប្រជាជាតិដែលនាំមកនូវយុត្តិធម៌ដល់អ្នកដឹកនាំជាន់ខ្ពស់ និងអ្នកដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងប្រល័យពូជសាសន៍ខុសច្បាប់ដែលបានប្រព្រឹត្តិក្នុងរបបខ្មែរក្រហម។

*ហូបស្លា* ផ្លែស្លាត្រូវបានគេបរិភោគក្នុងពិធីរៀបមង្គលការបែបប្រពៃណី

*កម្មពៀរ* ជំនឿបែបព្រះពុទ្ធសាសនាដែលអំពើពីអតីតជាតិកំណត់នូវស្ថានភាពរបស់បុគ្គលម្នាក់ក្នុងជីវិតបច្ចុប្បន្ន

*ក្បិន* សំពត់សំរាប់ស្ត្រីស្លៀកក្នុងពិធីរៀបការបែបប្រពៃណី (សំរាប់ស្រី)

*ខ្មាំង* តាមន័យរបស់ពាក្យ "សត្រូវ" សំដៅលើអ្នកដែលមិនធ្វើតាមបទបញ្ជារបស់អង្គការ ហើយអាចប្រើវាសំរាប់អ្នកដែលមានការពាក់ពន្ធ័ជាមួយ ឬសមាជិកគ្រួសារណាដែលគេចាត់ទុកថាជាខ្មាំង

*ខ្មែរក្រហម* ឈ្មោះដែលត្រូវបានគេផ្តល់អោយដោយសម្តេចនរោត្តមសីហនុក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ជាសម័យដែលរដ្ឋាភិបាលស្ថិតក្រោមការគ្រប់គ្រងរបស់ប៉ុលពត ដែលកាន់កាប់ទឹកដីកម្ពុជាពីថ្ងៃទី ១៧ មេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៧ មករា ឆ្នាំ១៩៧៩

*ក្រមា* ក្រមាបែបប្រពៃណីខ្មែរ

*កាត់ខាន់ស្លា* ពិធីរៀបការបែបប្រពៃណីខ្មែរ

*លន់នល់* ប្រធានាធិបតីនៃសម័យសាធារណរដ្ឋខ្មែរគាំទ្រដោយសហរដ្ឋអាមេរិច ពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥ នៅពេលរដ្ឋាភិបាលត្រូវបានផ្តួលរំលំដោយខ្មែរក្រហម

| | |
|---|---|
| *មេបា* | ឳពុកម្តាយទាំងខាងកូនកំលោះ និងកូនក្រមុំក្នុងពេលរៀបចំពិធីមង្គលការ |
| *មីង៍ ពូ* | តាមន័យរបស់ពាក្យ "មីង/ពូ" ត្រូវបានប្រើប្រាស់ក្នុងការឆ្លើយបែបគួរសមទៅកាន់មនុស្សម្នាក់ដែលមានអាយុច្រើនជាង ឬមានឋានៈខ្ពស់ជាងអ្នកនិយាយ |
| *មិត្ត មិត្តបង៍* | សមមិត្ត សំដៅទៅលើសមមិត្តដែលមានអាយុច្រើនជាង ឬមានតួនាទី ឬឋានៈធំជាងអ្នកនិយាយ សូមមើលពាក្យថា បងខាងលើ |
| *អ្នកថ្មី* | ចំពោះអ្នកដែលត្រូវបានគេបង្ខំអោយចាកចេញពីទីក្រុងទៅរស់នៅក្នុងទីជនបទបន្ទាប់ពីរបបខ្មែរក្រហមកាន់កាប់នៅថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ ឬ ហៅម្យ៉ាងទៀតថា "មនុស្ស ១៧ មេសា" និង ស្ថិតក្រោមការសង្ស័យសំរាប់អ្នកមាននិន្នាការចក្រពត្តិនិយម ពួកគេមិនត្រូវបានផ្តល់សិទ្ធិស្មើគ្នាដូចអ្នកក្នុងមូលដ្ឋានទេ។ |
| *អ្នកចាស់* | សូមមើលពាក្យអ្នកមូលដ្ឋានខាងលើ |
| *ប្តេជ្ញា* | ការតាំងចិត្ត ហើយវាត្រូវបានប្រើប្រាស់ដើម្បីពិពណ៌នាពីការរៀបការដោយបង្ខំក្នុងរបបខ្មែរក្រហម |
| *ផ្កាស្លា* | ផ្កាដែលកូនជូនដល់ឳពុកម្តាយក្នុងពិធីរៀបមង្គលការបែបប្រពៃណី |
| *ប៉ុលពត* | ឈ្មោះកំណើត សាឡុតស ប៉ុលពត ដឹកនាំរបបខ្មែរក្រហមពីឆ្នាំ១៩៦៣ ដល់ឆ្នាំ១៩៩៧ ហើយបានដឹកនាំរបបប្រល័យពូជសាសន៍កម្ពុជាចន្លោះឆ្នាំ១៩៧៥ ដល់១៩៧៩ ហើយអ្នកដែលនៅមានអាយុជីវិតតែងតែហៅរបស់នេះថា សម័យប៉ុលពត |

*អប់រំកសាង* ពាក្យដែលត្រូវបានខ្មែរក្រហមប្រើប្រាស់ដើម្បីបង្ហាញប្រាប់ពីការអប់រំនៃបទបញ្ញត្តិរបស់អង្គការ ជាញឹកញាប់ពាក់ពន្ធ័នឹងទំរង់នៃការស្តីបន្ទោសដោយពាក្យសំដី ឬការដាក់ទណ្ឌកម្មខាងរាងកាយ

*សំពត់* សំពត់ប្រពៃណីខ្មែរដែលត្រូវបានគេស្លៀកពាក់ទាំងក្នុងពិធីធម្មតា និងពិធីផ្លូវការ

*រៀបការ* ពិធីរៀបការបែបប្រពៃណី ឬសំដៅទៅលើការរៀបការទូទៅ

*មេម៉ាយ/ពោះម៉ាយ* អាចសំដៅទៅលើពាក្យសំដីមិនផ្លូវការចំពោះជនណាដែលធ្លាប់បានរៀបការម្តងរួចហើយ ប៉ុន្តែមិនមានដៃគូដោយសារការស្លាប់ ការបោះបង់ ការចែកផ្លូវគ្នា ឬការលែងលះ